# រឿង

# អប្សរា

## រាជធិតាមហានគរ

ប្រលោមលោកមនោសញ្ចេតនា

ដោយ   អ្នកស្រី កែវ ចន្ទ៍បូរណ៍
P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

ខែតុលា១៩៩៩

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

សូមឧទ្ទិសស្នាដៃនេះចំពោះ

- លោកឪពុក ប៊ុន ថង និង អ្នកម្តាយ កែវ យឿង
- លោកឪពុកក្មេក មេង សួង អ្នកម្តាយក្មេក កូវ សារ៉ាន់
- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធី ធម្មិកា បារមីបុណ្យ ជាបុត្រីទោល
- អ្នកស្រី មេង សុមាលី លោកទូសារិត និងគ្រួសារ
- លោក មេង ស៊ីថា ព្រមទាំងភរិយា និង បុត្រ
- អ្នកស្រី មេងចិន្តាមណី លោកមិន សុផល និង គ្រួសារ
- អ្នកស្រី មេងពៅធិតា លោក វិចិត្រ វុទ្ធី និង គ្រួសារ
- លោក មេង សុជាតិ
- កញ្ញា ប៊ុន រចនា
- លោក តាន់ ឈុនអេង
- សាស្ត្រាចារ្យ និង គ្រូបង្រៀនរបស់នាងខ្ញុំគ្រប់រូប
- រៀមច្បង មិត្តភក្តិ និង មិត្តគន្ថការីទាំងឡាយ
- សាច់ញាតិទាំងអស់នៅក្នុងស្រុកខ្មែរនិងក្រៅប្រទេស ។

CHANBOKEO.COM

អ្នកស្រី កែវ ចន្ទ័បូរណ៌

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

www.angkorwat.com

ស្នាដៃខ្លះៗរបស់អ្នកនិពន្ធកែវចន្ទបូរណ៏

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្មឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នែកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សាភាណីយមាតា
១៤- រឿង ទារុណាដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្អែក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្នើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិជេន្ទភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្ជួងមាលា
៣៦- រឿង វាយោដួងចិត្ត

CHANBOKEO.COM

# វាចាអ្នកនិពន្ធ

រឿងអប្សរានេះបានត្រូវអ្នកនិពន្ធប្រតិស្ឋឡើង ក្នុងគោលបំណងគោរពរក្សា តម្លៃសម្បត្តិរតនភណ្ឌជាតិ ដែលជាតំណែលបុព្វបុរសយើងផង ដើម្បីរំលឹកនូវ អរិយធម៌ខ្មែរដ៏រុងរឿង ក្រោមឥទ្ធិពលនៃព្រហ្មញ្ញសាសនានិងពុទ្ធិសាសនា លាយ ឡំគ្នាផង ដើម្បីគោរពរំលឹកដល់វិញ្ញាណក្ខន្ធ័វិរបុរសនិងវិរនារីខ្មែរអ្នកស្នេហាជាតិ ផង និង ដើម្បីរំលឹកបច្ឆាជនជំនាន់ក្រោយ ឱ្យមានសទ្ធាកុសលចំពោះពិធីបង្សុកូល ជូនបុព្វជនរបស់ខ្លួន កុំឱ្យឃ្លាឃ្លាតផងដែរ ។

អាស្រ័យហេតុនេះ សូមមិត្តអ្នកអានទទួលនូវការកំសាន្តសប្បាយរីករាយ អារម្មណ៍ជាមួយនឹងសាច់រឿងរបស់យើង និងសូមឱ្យមិត្តបានស្វែងរកឃើញភាព ក្សេមក្សាន្តនៅក្នុងដួងចិត្តជាមួយដំណើររឿងរបស់យើងនេះកុំបីខាន ។ ចំពោះកំហុសអក្ខរាវិរុទ្ធដោយអចេតនា សូមមិត្តអ្នកអានទាំងឡាយ មេត្តាជួយកែសំរួល ឱ្យសមរម្យតាមវេយ្យាករណ៍ខ្មែរដោយប្រពៃផង ។ នាងខ្ញុំអ្នកនិពន្ធសូមទទួលនូវ មតិយោបល់ពីប្រិយមិត្តអ្នកអាន តាមរយៈអស័យដ្ឋានដូចខាងក្រោមនេះ :

P.O.Box 600279
Saint Paul, MN 55119
USA
Khmervissal@yahoo.com
www.angkorwat.com

សូមប្រិយមិត្តបានជួបប្រទះតែវឌ្ឍនសុខ និងសុវត្ថិភាពរាល់ទិវារាត្រី ។

អ្នកនិពន្ធ
អ្នកស្រី កែវ ចន្ទ័បូរណ៍
ថ្ងៃទី ១០កញ្ញា ១៩៩៩

CHANBOKEO.COM

# សង្ខេបរឿង

បុរសសង្ហារខេមឫទ្ធិបានវង្វេងវិញ្ញាណទៅក្នុងពិភពពីរផ្សេងគ្នា ខុស ស្រលះ មួយជាពិភពសម័យទំនើប មួយជាជីវិតបុរេរាជកាល ជីវិតមួយជា បុរសសាមញ្ញ មួយទៀតជាមេទ័ពមហាសេនា... ហើយនៅក្នុងជីវិត និមួយៗ នាយមានគូកំណាន់ចិត្តដែលរង់ចាំទាមទារសន្យា ដែលនាយបាន ប្រគល់ដល់គេម្នាក់ៗ ប៉ុន្តែមាណពមិនអាចមានឱកាសសំរាប់ជ្រើសយក ជីវិតទាំងពីរក្នុងពេលជាមួយគ្នាបាន ។ តើគេត្រូវសំរេចចិត្តជ្រើសរើស យកជីវិតមួយណា... បើគូកំណាន់ម្នាក់ជារាជធិតាមហានគរ តែម្នាក់ទៀត ជានារីធម្មតាៗ ហើយបើគេធ្វើតាមសន្យាសំរាប់នារីម្នាក់ គេនឹងត្រូវព្រាត់ ពីគូកំណាន់ចិត្តម្នាក់ទៀត ។

ដូច្នេះ សូមអញ្ជើញប្រិយមិត្តអ្នកអានតាមដានដូចតទៅ...

CHANBOKEO.COM



អ្នកស្រីកែវ ចន្ទ័បូរណ៏

អ្នកនិពន្ធ

# វគ្គទី១

# រាជធិតាមហានគរ

នៅក្បែរក្លោងទ្វារប្រសាទដ៏ល្អមហាសាល ខេមឫទ្ធិឈរសំលឹងរូបចំលាក់ទាំង ឡាយលើជញ្ជាំងប្រាសាទយ៉ាងពិនិត្យពិច័យ ។ នៅដៃ នាយមានកាន់សៀវភៅ កំណត់ហេតុនិងប៉ាកកាមួយ ព្រមជាមួយសំពៀតនៅលើស្មា ទំនងហាក់ដូចជាកំពុង ស្រាវជ្រាវប្រវត្តិក្បាច់រចនាផ្សេងៗរបស់ប្រាសាទយ៉ាងភ្លន់ភ្លឹកអារម្មណ៍ ។ រំពេច នោះស្រាប់តែនាយឮសូរស្នូរចង្រ្កង់ជើងរ៉ឹកៗល្វើយៗក្បែរនោះ ។ មាណពបែរ មុខរកមើលម្ចាស់ចង្រ្កង់តែក៏មិនឃើញអ្វីសោះ ។ នាយក៏បែរមកមើលរូបនៅ ជញ្ជាំងប្រាសាទវិញ ។ លុះនាយដាក់កន្ទុយភ្នែកចំរូបចំលាក់អប្សរាដែលឈរនៅ ក្បែរក្លោងទ្វារ ស្រាប់តែនាយឃើញមុខនាងញញឹមពព្រាយដាក់នាយយ៉ាងស្រស់ ចំលែក ហាក់បីនាងជារូបមនុស្សពិតៗមិនមែនគ្រាន់តែជារូបចំលាក់បុរាណតែ ប៉ុណ្ណោះឡើយ ។ ខេមឫទ្ធិយកដៃឈ្លីភ្នែកយ៉ាងញាប់ហើយងើបមុខសំលឹងម្តង ទៀត តែម្តងនេះ នាយឃើញគ្រាន់តែឃើញរូបចំលាក់អប្សរាធម្មតាប៉ុណ្ណោះ មិនមានវិញ្ញាណអ្វីទេ ។ បុរសយើងក៏ចាប់ទាញកាម៉ារ៉ាថតរូប ធ្វើកំណត់ហេតុបន្ត ទៀតព្រមទាំងរអ៊ូក្នុងមាត់តិចៗថា ៖

- ប្រហែលយើងនេះអត់ងងុយច្រើនពេកទេដឹង បានចេះតែស្រម័យផ្តេសផ្តាស!!

ភ្លាមនោះ ខេមឫទ្ធិមានអារម្មណ៍ហាក់ដូចក្រអូបក្លិនផ្កាម្លិះសាយភាយមកពី នាយ ធ្វើឱ្យអារម្មណ៍នាយរំភើបចំលែកអស្ចារ្យ ហើយស្នូរចង្រ្កង់ជើងក៏លាន់ឮរ៉ឹកៗ តិចៗសាជាថ្មី ។ មាណពនឹកពិភាល់ក្នុងចិត្តយ៉ាងម៉េចមិនដឹង ក៏ស្ទុះយ៉ាងប្រញាប់ សំដៅទិសសំលេង ។ លុះឆ្លងផុតទ្វារប្រាសាទ ចូលទៅដល់វាលឧទ្យានដ៏ខៀវ ប្រណិតមួយ ខេមឫទ្ធិមានអារម្មណ៍ថាខ្លួនបានឃើញស្រមោលនារីមួយរូបចាំងឆ្លុះ ទៅក្នុងទឹកស្រះដ៏ថ្លាឆ្វង់ លំអដោយផ្កាឈូករីកស្រស់រហង់យោលយោគតាមវាតា គួរភិសម័យក្រៃលែង ។ មិនអស់ចិត្ត បុរសយើងក៏បោះជំហានកាន់តែលឿន សំដៅទៅរកម្ចាស់ស្រមោលក្នុងទឹកស្រះនោះឥតបង្អង់ ។ មែនហើយ ទិដ្ឋភាពទី នោះស្រស់វិចិត្រណាស់ មិនខុសពីឧទ្យានសួគ៌ស្រីង្គានិមិត្តក្នុងសុបិនឡើយ ។ សព្ទ សៀ បក្សាបក្សីខៀវខ្ចា លាយឡំនិងសំលេងស្លឹកឈើស្រោកៗបក់បោកតាមជំនោរ វាតា ក្រោមស្បៃមេឃាដ៏ខៀវបំព្រង បានញុំាងឱ្យវិញ្ញាណបុរសយើងអណ្តែតវង្វេង លង់ស្មារតីភ្លេចអ្វីៗទាំងអស់ក្នុងជីវិត ។ ពេលនេះ នាយយើងពុំមានគិតពីអ្វីឡើយ ក្រៅ ពីតាមរកម្ចាស់ក្លិនដ៏ក្រអូបអំបាញ់មិញនេះ ថាតើគេជានរណា ។

- ហ៊ូ!!! ៗៗៗៗ ហ៊ូ!!!! ៗៗៗៗ .......

ខេមឫទ្ធិភ្ញាក់ព្រើតកាលបើបានឮសូរសំនៀងច្រៀងល្វើយៗ ពីត្រើយម្ខាង ស្រះឈូកដ៏រុងរឿង យ៉ាងពិរោះគាប់សោតា ។ មាណពផ្ទៀងស្តាប់បណ្តើរ ដើរបណ្តើរ សំដៅទៅរក លួចមើលម្ចាស់សំនៀងដ៏គ្រលួចមួយរូបនោះ ។

CHANBOKEO.COM

ដែនរមណី

អរុណរៀងរះជះរស្មី          ស្រមោលព្រឹក្សព្រៃឆ្លុះគង្គា
ហ្វូងត្រីពួនក្រោមបទុមា          រីកសាយគន្ធាក្រអូបក្រៃ ។
នៅលើស្លឹកឈូកកញ្ចាញ់ចេក          ក្រលាប់ក្រលេកសំលឹងត្រី
គង្គាថ្លាយង់យល់បាតដី          ចុងត្រែងវែងខ្ចីរេតាមខ្យល់ ។
ព្នដ៏វេហាសីបក្សាសត្វ          ហោះហើរឆ្វៃលឆ្វាត់ឥតកង្វល់
សូរសៀងធម្មជាតិពិតមង្គល          លាយក្លិននិមលបុប្ផាព្រៃ ។
សោភ័ណឧទ្យានសែនមនោរម្យ          ផ្ការោយប្រស់ព្រំលោមហឫទ័យ
ថ្នាក់ថ្នមចិន្តាសែនភិសម័យ          ត្រអាលបេតីភាពក្សេមក្សាន្ត.....

ខេមឫទ្ធិអែបខ្លួនប្របគុម្ពផ្កាលួចសំលឹងម្ចាស់សំនៀងយ៉ាងភ្លឹកស្មារតី ។ ពុទ្ធោ អើយ! ធិតាស្រស់ស្អាតអ្វីម្ល៉េះទេ គ្រាន់តែក្រលេកយល់ភក្ត្រាដ៏របស់នាងភ្លាម បេះដូងនាយយើងលោតឱបឆាក់ៗស្ទើរតែធ្លាយទ្រូងមកក្រៅ ។  ម្តងនេះខេមឫទ្ធិ ឈ្លីភ្នែកហើយឈ្លីទៀត ថែមទាំងលួចក្តិចដៃខ្លួនឯងទៀតផង ថាតើរូបគេកំពុងតែ សុបិន ឬស្រម័យ ឬក៏កំពុងប្រទះការពិតមួយ ។ តែចំលែកណាស់ ម្ចាស់សូរសៀង ដ៏សោភាមួយរូប មានសំលៀកពស្ត្រាស្រស់ស្អាតដូចចំលាក់ទេពទេវីអប្សរានៅ លើ ក្លោងទ្វារប្រាសាទអំបាញ់មិញនេះឥចឹង ។ មើលហ្ន៎ ! គ្រឿងអលង្ការក៏ប្រណិត សមនឹងពស្ត្រាជារាជធិតា លំអដោយកំរងផ្កាម្លិះលើកាយា ធ្វើឱ្យសោភណ័នារីយើង រិងរិតតែស្រស់ស្អាតចំលែកនេត្រាក្រៃលែង ។ ខេមឫទ្ធិលួចគយគន់សឹងភ្លេចដង្ហើម ទៅហើយ ។ រំពេចនោះ រាជធិតាក៏ដាក់ក្រសែនេត្រាចំខេមឫទ្ធិដែលកំពុងឈរអែប គុម្ពផ្កាស្រាប់តែញញឹមដាក់នាយយ៉ាងស្រស់ត្រកាល ។ មាណពភ្ញាក់ព្រើតបែរមើល ជុំវិញខ្លួនមិនឃើញនរណាសោះ ក៏មានអារម្មណ៏ថាធិតាកំពុងញញឹមរកនាយតែ ម្តង ។ គ្រានេះ នាយយើងហាក់ដូចជានឹករអៀសខ្លួនណាស់ ដោយមកឈរលួច មើលគេ ម្យ៉ាងហាក់ដូចជាខ្មាស់យ៉ាងណាមិនដឹង ដែលមកលង់ស្នេហ៏សំនៀងដ៏ ពិរោះរបស់ធិតា ហើយជាពិសេសលង់ស្នេហ៏លើរូបសោភ័ណរបស់ទេពទេវីតែម្តង ។ កំពុងតែភ្លន់ភ្លឹកអារម្មណ៏ ស្រាប់តែមានមនុស្សម្នាក់មកគោះស្មានាយ ព្រមទាំង ស្រដីថា ៖

- បងខេមឫទ្ធិ! លោកឪពុកមានប្រសាសន៏ឱ្យទៅជួបមួយគាត់ឥឡូវនេះ!

មាណពងាកផាំង ឃើញក្មេងស្រីជំទង់ម្នាក់ស្លៀកពាក់ទំនងជាភិលៀងក្នុងវាំង កំពុងស្រដីមកនាយថែមទាំងញញឹមផង ។ នាយនឹកឆ្ងល់ក្នុងចិត្តណាស់ហេតុអ្វីបាន ជានាងស្គាល់ឈ្មោះនាយ ហើយថែមទាំងនិយាយហាក់បីដូចជានាងជាប្អូនស្រីរបស់ នាយបង្កើតទៀត កាលបើនាយមិនដែលស្គាល់នាងម្តងណាសោះ ។ ប៉ុន្តែទោះបី នាយមានចំងល់យ៉ាងណាក្តី ក៏មាណពមិនរាថយនឹងស្វែងយល់ដែរថាជីវិតរបស់ នាយកំពុងប្រទះហេតុការណ៏ចំលែកអ្វីខ្លះទៀត ។ ខេមឫទ្ធិក៏បោះជំហានដើរតាមពី ក្រោយកុមារី ។ យូរៗនាយយើងងាកក្រោយម្តង បែររកមើលធិតាឧទ្យាននិមិត្ត ឃើញនាងនៅតែអង្គុយញញឹមសំលឹងមករកនាយដដែល  ថែមទាំងលើកដៃស្តាំរា ចុះរាឡើងជាសញ្ញា ថាលាសិនហើយទៀតផង ។

- ហ៊ឹ! តើធិតាដ៏ស្រស់សោភានោះជានរណាទៅហ្ន៎?

CHANBOKEO.COM

ខេមឫទ្ធិលួចស្ទួរតែក្នុងចិត្តម្នាក់ឯង ។ បន្តិចក្រោយមក កុមារីបាននាំបុរស យើងមកដល់លំនៅឈើដ៏ស្កកស្កម្មមួយខ្នង ដែលមានផ្ទាំពីរនាក់នៅឈរយាមនៅ សងខាងក្បាលជណ្ដើរទៀតផង ។ លុះនាយដើរឡើងទៅដល់ខាងលើផ្ទះ ក៏ប្រទះ នឹងបុរសចំណាស់មួយរូបក្នុងសំលៀកទំនងជានាយទាហានសឹកប្រចាំនគរ កំពុង ដើរទៅដើរមកក្នុងលំនៅ ដោយមានទឹកមុខព្រួយអន្ទះសាបំផុត ។ កាលបើ ក្រលេកឃើញនាយភ្លាម បុរសចំណាស់ក៏បន្លឺវាចារឹងឡើងយ៉ាងប្រញាប់ថា ៖

- ខេមឫទ្ធិ កូនសំលាញ់! ឪពុកមានរឿងអាសន្នធំណាស់កូន ត្រូវផ្ដាំកូនមុននឹងឪពុក ចេញទៅសមរភូមិ ។

- លោកឪពុក? (ខេមឫទ្ធិលាន់មាត់ខ្សិបៗតែម្នាក់ឯង ហើយកាន់តែនឹកឆ្ងល់ថែម ទៀត ថាខ្លួនជាមនុស្សកំព្រាឪពុកម្ដាយតាំងពីតូច ចុះហេតុអ្វីថ្ងៃនេះបែរជាមកមាន ឪពុកដែលជាមេទ័ពប្រចាំនគរទៅវិញ ?

- មែនហើយកូន! សត្រូវឈ្លានពានចូលបុរីមហានគរយើងហើយ ។ ឪពុកត្រូវ ទទួលការតែងតាំងជាមេដឹកនាំទ័ពទៅការពារព្រំព្រទល់ភាគខាងលិច ហើយត្រូវ ចេញដំណើរឥឡូវនេះ ។

ខេមឫទ្ធិឈរភាំង គិតមិនចេញ មិនដឹងថាត្រូវឆ្លើយយ៉ាងណា ។ ម្យ៉ាងទៀត មហានគរខេមរតន៍បានទទួលសុខសន្តិភាពយូរឆ្នាំមកហើយ ហេតុអ្វីក៏បែរជាមាន សឹកសង្គ្រាមទៅវិញ? រំពេចនោះ មានសេនាពីររូបឈានចូលមកដល់ ៖

- កងទ័ពត្រៀមចេញដំណើររួចរាល់ហើយទានប្រោស!

បុរសចំណាស់បែរសំលឹងមកខេមឫទ្ធិដោយក្រសែភ្នែកយ៉ាងមុត :

- ជាកូនប្រុសត្រូវតែក្លាហានជានិច្ចណាកូន !! ចូរកូនមើលផ្ទះថែរក្សាម្ដាយហើយ និងខេមរី ប្អូនស្រីរបស់ឯងផង ។

មានប្រសាសន៍ចប់ លោកក៏ឡើងបំផាយសេះនាំទ័ពចេញទៅ ទុកឱ្យមាណព យើងឈរមើលភាំងស្មារតីសំលឹងតាមពីក្រោយ ។ ភ្លាមនោះស្រាប់តែ នាយយើង ឮស្នូរសំលេងស្រែកទ្រហោរយំយ៉ាងខ្លាំង ។ បុរសយើងក៏ស្ទុះរឹងទៅយ៉ាងលឿន ស្រាប់តែប្រទះនឹងក្មេងស្រីៗពីរនាក់ កំពុងតែគក់ច្របាច់ស្ត្រីចំណាស់មួយរូបដែល ដួលសន្លប់ស្តូកស្តឹង នៅលើក្ដារផ្ទះ ។ នាងតូចខេមរី ក៏ឱទានឡើង ៖

- អ្នកម្ដាយៗ!! បងខេមឫទ្ធិ ជួយអ្នកម្ដាយយើងផង ប្រហែលជាគាត់ភិតភ័យ ខ្លាំងហើយ បានជាបាត់ស្មារតីយ៉ាងនេះ។

ពុទ្ធោ! ពេលនេះ នាយក៏មានម្ដាយទៀត... ប៉ុន្តែ ទោះជាឆ្ងល់យ៉ាងណាក៏ ដោយ ក៏នាយនៅស្ងៀម ហើយស្រវាបីស្រីចំណាស់យកទៅដាក់លើគ្រែក្នុងបន្ទប់ ដំណេករបស់គាត់យ៉ាងរហ័ស ខេមឫទ្ធិឈរញីភ្នែកហើយញីទៀត តែក៏នៅមិនជ្រះ ស្រលះក្នុងចិត្តសោះ ថាបើនាយស្ថិតនៅក្នុងផ្ទះជួបជុំជាមួយក្រុមគ្រួសាររបស់ខ្លួន ពិតមែន ហេតុអ្វីក៏នាយមិនស្គាល់មិនចាំនរណាម្នាក់យ៉ាងនេះ។ ក្នុងចិត្តនឹកថាចង់ បកក្រោយទៅផ្ទះវិញម្ដងៗហើយ តែលុះនាយក្រលេកឃើញស្ត្រីចំណាស់មាន សុខភាពទ្រុឌទ្រោម ឃើញកុមារីខេមរីកំពុងភិតភ័យ នាយមិនដាច់ចិត្តដើរចេញ សោះ ត្បិតហាក់ដូចជាអត់សន្តានចិត្តពេក ។ បន្តិចក្រោយមក នាយក៏ដាក់ខ្លួន អង្គុយចុះហើយស្រវារកប៉ាកកានិងសៀវភៅបំរុងនឹងកត់ហេតុ ស្រាប់តែនាយ បាត់សំពាយរបស់ខ្លួនតាំងពីអង្កាល់ក៏មិនដឹង ។ ឯរូបនាយវិញបែរស្ថិតក្នុងសំលៀក របៀប កំលោះជំនាន់បុរាណមួយរូបទៅវិញ ។ ខេមឫទ្ធិ ភើតពោះធ្លុង :

- ព្រះអើយ! ហេតុអ្វីក៏យ៉ាងនេះ? តើខ្ញុំកំពុងស្ថិតនៅទីណា កន្លែងណាហ្នឹង?

ខេមឫទ្ធិប្រគល់នាទីឱ្យទៅអ្នកផ្ទះ ថែរក្សាស្ត្រីចំណាស់ហើយ ក៏ស្ទុះចុះទៅដី

CHANBOKEO.COM

គិតថាបំរុងត្រលប់ទៅកន្លែងដើមរបស់ខ្លួន ។ លុះដើរមកដល់ក្បែរឧទ្យានដែល មានស្រះឈូកដ៏ស្អាតប្រណិត នាយក៏នឹកភ្នកដល់រាជធិតាសោភាស្រាប់តែទុច ជំហានង៉ក់ហើយបែរខ្លួនដើរត្រលប់សំដៅទី ដែលរាជធិតាប្រថាប់លេងក្រោមម្លប់ ឈើត្រឈៃមួយ ។ ចៃដន្យនាងមិនបាននៅទីនោះទៀតឱ្យនាយបានឃើញទៀត ឡើយ ។ ខេមឫទ្ធិមានអារម្មណ៏ថាខកចិត្តណាស់ ។ នាយឈ្ងោកមុខសំលឹងទឹកថ្លា ហើយបែបន់ក្នុងចិត្តថា ៖

- ឱគុណបារមីវត្ថុសក្តិសិទ្ធិទាំងឡាយ ! សូមព្រះអង្គជួយណែនាំផ្លូវឱ្យទូលបង្គំបាន ជួបរាជធិតាដ៏សោភានោះសាជាថ្មីទៀតកុំខាន.....

ឯណាម្ចាស់សំនៀង

| | |
|---|---|
| ឯណា? ឯណា ម្ចាស់សំនៀង? | ឮតែចំរៀងលាន់ល្វើយៗ |
| ពិរោះរណ្ដំពីម្ខាងត្រើយ | ស្ដាប់សំនៀងហើយស្បើយក្នុងប្រាណ។ |
| តើម្ចាស់សូរសៀងជាអ្នកណា | ឱ្យប្រុសរៀមរ៉ាខ្វល់រំខាន |
| ចង់ស្គាល់ចង់ជួបភក្ត្រកល្យាណ | ព្រោះស្នេហ៍កុំផានពេញដួងចៃ ។ |
| គ្រានេះម្ចាស់សៀងច្រៀងទៀតទេ | ពន្លកមាសមេ បងខ្វល់ខ្វាយ |
| ចង់ស្ដាប់សំនៀងកែវឆោមឆាយ | លួងលោមហឫទ័យឱ្យស្បើយអង្គ ។ |
| សូមផ្ដាំតាមឈូកទៅម្ចាស់សៀង | បន្លឺសំនៀងស្រស់ឆោមយង់ |
| ឱ្យរៀមបានស្ដាប់សៀងគ្រលង់ | គ្រលួចមានទ្រង់លង់អារម្មណ៏.... |

រំពេចនោះ ស្រាប់តែមាណពឃើញដៃតូចស្រលូនមួយកាន់ផ្កាឈូកក្រពុំមួយ មកហុចប្រគល់ឱ្យនាយ ។ ខេមឫទ្ធិងើបមុខឡើងយល់ភក្ត្រាដ៏ស្រស់បំព្រងសោភា មួយដែលនាយកំពុងទន្ទឹងរង់ចាំនោះ នៅឈរចំពោះរូបនាយតែម្តង ។ បុរសយើងភ្ញាក់ស្រលាំងកាំង ៖

- ព្រះអើយ! បារមីព្រះអង្គមហានគរសក្តិសិទ្ធិដល់ម្លឹង? គ្រាន់តែបន់ភ្លាមមកដល់ ចំពោះមុខភ្លែតតែម្តង !!!

មែនហើយ នោះគឺរាជធិតាដែលបេះដូងនាយកំពុងបួលហៅពិតមែន ។ ព្រះនាងញញឹមយ៉ាងស្រទន់ ព្រមទាំងមានសវនីយ៏យ៉ាងពិរោះមកមាណពយើងថា ៖

- បង ខេមឫទ្ធិ ! មល្លិកានៅរង់ចាំបងទីនោះយូរថ្ងៃហើយ តែបងបែរជាមកដល់ ខុសថ្ងៃសន្យាទៅវិញ ។

- ព្រះជាម្ចាស់ !（មាណពលាន់មាត់）រាជធិតាស្គាល់ឈ្មោះទូលបង្គំដែរ?

រាជធិតាញញឹមសាជាថ្មី ហើយសួរទៅនាយយើងទៀតថា :

-តើថ្ងៃនេះ បងមានរឿងអ្វីបានជាមានអាកប្បកិរិយាដូចជាប្លែកជាងសព្វដងម្ល៉េះ?

ខេមឫទ្ធិលេបទឹកមាត់ឱ្យបាត់ស្ងួតបំពង់ក ត្បិតនាយប្រទះហេតុការណ៏ចំលែក ពេក។ នាយនឹកឆ្ងល់ណាស់ថាហេតុអ្វីបានជារាជធិតាស្គាល់រូបនាយយ៉ាងស្និទ្ធស្នាល តែនាយបែរជាមានអារម្មណ៏ថាមិនដែលស្គាល់ពីមុនម្តងណាសោះទៅវិញ ។ ប៉ុន្តែ បុរសយើងក៏មានចិត្តរំភើបមិនតិចដែរ កាលបើខ្លួនបានទទួលនូវភាពរាក់ទាក់រួស រាយយ៉ាងជិតដិតពីរាជធិតា ។ បន្ទាប់មក មាណពក៏បន្ទន់កាយវន្ទាដល់ព្រះនាង :

- ទូលបង្គំមានចិត្តរំភើបខ្លាំងពេកក្រាបទូល បានជា....

- ហេតុដូចម្ដេចបានជាបង និយាយមករកអូនបែបនេះ? យើងជាកំណាន់ចិត្តនឹងគ្នា យូរហើយ គ្រាន់តែបែកគ្នាប៉ុន្មានថ្ងៃ បងផ្លាស់ប្ដូរប្លែកម្ល៉េះ ឬក៏បងខឹងអីនឹងអូន?

រាជធិតាវាចាផង ស្រវាទាញដៃបុរសទៅកាន់ផង ហើយក៏មានសវនីយ៍បន្តថា ៖

- ដឹងទេ ថាអូនកំពុងនឹករលឹកបងក្រៃលែង ស្ទើរតែបែកឱរាម្ដង១ទៅហើយ...

ខេមឫទ្ធិញ័រដៃទទ្រើក ។ មែនហើយ គ្រាន់តែបានប៉ះហត្ថារបស់រាជធិតាដ៏ សោភានោះភ្លាម នាយយើងមានអារម្មណ៍ហាក់ដូចជាខ្លួនកំពុងអណ្តែតនៅលើ វេហាស៍យ៉ាងធំធេងបំផុត ។ នាយស្រវាកាន់វិញយ៉ាងណែន ក្នុងចិត្តរំភើបរកថា មិនត្រូវសោះ គ្រាន់តែដឹងថា នាយកំពុងធ្លាក់ក្នុងរណ្ដៅស្នេហាមួយដ៏មានវិសាល ភាពទូលំទូលាយមិនអាចថ្លែងបាន ។ រាជធិតា សំលឹងមុខខេមឫទ្ធិដោយក្រសែ ភ្នែកយ៉ាងស្រទន់ ហើយក៏ផ្ដេកកេសាកើយទ្រូងបុរសយើងដោយដួងចិត្តបេតីឥតព្រំ ដែន ធ្វើឱ្យខេមឫទ្ធិរិតតែរឹងខ្លួនឡើង រំភើបក្នុងចិត្តឡើងស្ទើរតែគាំងបេះដូងម្ដង១ ទៅហើយ ។ មិនថានិមិត្តភាពទាំងឡាយដែលខ្លួនកំពុងប្រទះជាការពិត ឬក៏ជា សុបិនទេ មាណពយើងលែងខ្វល់ហើយកាលបើខ្លួនបានស្ថិតនៅក្បែររាជធិតាសោភា មួយរូបដែលកំពុងបង្ហាញនូវដួងចិត្តមេត្រីរបស់ព្រះនាងចំពោះនាយយ៉ាងស្និទ្ធស្នាល ទោះបីត្រូវ ស្លាប់ក៏មិនរាថយឡើយ ។

កំពុងតែស្លុងអារម្មណ៍ ស្រាប់តែមានសំលេងស្រែកខ្លាំង១មួយលាន់ឮឡើង ៖

- ថ្លើមពាសមេឃ !! ងារត្រឹមតែជាកូនមេទ័ពកំប៉ិកកំប៉ុក ហេតុអីហ៊ានប្រាថ្នា ឈោងរាជធិតាមហានគរ ដូច្នេះ? ដឹងទេហ៏ថាអ្នកនឹងត្រូវមានទោសដល់ស្លាប់?

ទាំងពីរនាក់ងាកក្រោយយ៉ាងរហ័ស ក៏ប្រទះឃើញស្ត្រីចាស់ម្នាក់ដើរចូលមក ដល់ ធ្វើទឹកមុខមាំតែក៏មានលួចញញឹមតិច១ផង ។ នៅពេលដែលខេមឫទ្ធិ កំពុងតែភ័យភើតពោះព្រោះមិនដឹងថាគាត់ជានរណា រាជធិតាបែរជាសើចខឹក១ ទៅវិញ ព្រមទាំងមានសវនីយ៍តបថា ៖

- ព្រះអើយ ម៉ែចាស់! ធ្វើយ៉ាងនេះ មល្លិកាលោះព្រលឹងអស់រលីង !

- ម៉ែចាស់? តើគាត់ជានរណា? (ខេមឫទ្ធិលាន់មាត់)

- ម៉េចក៏ធ្វើជាមិនស្គាល់ម៉ែចាស់ដូច្នេះទៅវិញ បងខេមឫទ្ធិ? គឺមានតែម៉ែសង្វារ នេះទេដែលនៅថែរក្សាមល្លិកាជិតដល់រហូតមក តាំងពីព្រះមាតាសោយទីវង្គតទៅ រីឯព្រះបិតាក៏ប្រឈួនព្រះកាយជាយូរឆ្នាំមកហើយ....

- ដូច្នេះទើបបានជានគរជិតខាងឆ្លៀតឱកាសចូលលុកលុយនគរយើង មែនទេ? (មាណពសួរ)

- ជាការពិតណាស់បង ! ម្យ៉ាងមល្លិកាជានារីភេទ មិនដឹងជាអាចទទួលភារៈ ការពារនគរបានត្រឹមត្រូវប៉ុណ្ណាទេ.....

រាជធិតាមល្លិកាទំលាក់ទឹកមុខក្រៀមក្រំ ។ ស្ត្រីចាស់ក៏មានវាចាឡើង ៖

- រាជធិតា សុរភីមល្លិកា!! ព្រះវរបិតាមានអាការៈធ្ងន់ធ្ងរណាស់ សូមព្រះនាង យាងចូលវាំងវិញជាប្រញាប់ ព្រះមែម្ចាស់ ។

ពុទ្ធោអើយ! ព្រះរាជធិតាមានព្រះនាមពិរោះអ្វីម្ល៉េះ ! ខេមឫទ្ធិឮហើយគួច ចិត្តបេតីព្រះនាមនេះណាស់ ។ មុននឹងយាងត្រលប់ទៅវិញ រាជធិតាបែរមើលមក ខេមឫទ្ធិជាចុងក្រោយ ហើយមានវាចាថា ៖

- បងខេមឫទ្ធិជួយផ្ដល់កំលាំងចិត្តឱ្យអូនផង ។ ក្រៅពីព្រះវរបិតាចេញ មល្លិកា គ្មាននរណាជាបង្អែកទេ ក្រៅពីរូបបងតែម្នាក់...

CHANBOKEO.COM

រាជធិតា ក៏ប្រញិបប្រញាប់ស្ទុះស្ទារធ្វើដំណើរចូលរាជដំណាក់ទាំងនេត្រារលីង រលោង ធ្វើឱ្យបេះដូងបុរសយើងក្រៀមក្រំសោកសៅបំផុត ។ ហេតុអ្វីទៅហ្ន៎ បាន ជារូបនាយមកជំពាក់នឹងរឿងចំលែកបែបនេះ រួចហើយចង់ដកចិត្តវិញក៏ដកមិនរួច ទាល់តែសោះ? លុះរាជធិតាចេញទៅបាត់ ទើបខេមឫទ្ធិភ្ញាក់ស្មារតីព្រើត ចង់ស្ទុះ រត់ទៅតាម តែក៏មិនដឹងថាចេញទៅតាមផ្លូវណាទើបតាមរកនាងឃើញ :

- រាជធិតាសុរភីមល្លិកា... ព្រះនាងនៅឯណា? រាជធិតា... (ខេមឫទ្ធិកូកហៅ)

គួរអាណិតមាណពខេមឫទ្ធិណាស់! នាយរត់ទៅរត់មកមួយយប់ទល់ភ្លឺ ហើយ ចំលើយនៅតែស្ងាត់ជ្រៀប ។ នាយយើងដើរចុះដើរឡើងក៏នៅតែវិលវល់ មួយកន្លែងដដែល តែរកផ្លូវទៅដំណាក់របស់រាជធិតាមិនឃើញសោះ ឃើញតែ ឧទ្យានដ៏ស្ងាត់ឈឹង គ្មានមនុស្សម្នាអ្វីទាំងអស់សោះក្រៅពីបុរសយើងម្នាក់....

ស្តាយក្លិនស្នេហ៍...

១. ស្តាយបានស្គាល់ស្នេហ៍ត្រឹមតែក្លិន សុបិនស្រម័យ អាល័យអាលោះម្ចាស់
បុប្ផដែនសួគ៌ខ្ពស់កប់អាកាស នឹកស្តាយខ្លាំងណាស់ ស្តាយណាស់
ឈោងមិនដល់ ។

២. ស្តាយស្គាល់ម្ចាស់ក្លិនត្រឹមតែនាម ឱរាក្រាំក្រៀម ថ្ងូររៀមរែងអំពល់
បេះដូងស្រែកហៅរកកែវនិមល អារម្មណ៍វិលវល់ អំពល់នឹកតែអូន ។

៣. ស្តាយត្បិតរៀមបងគ្មានលទ្ធភាព ដៃខ្លីតូចទាប សែនទាបមិនសមសួន
ឈោងចន្ទមិនដល់ហឫទ័យស្រពោន អាធ្រាតស្ងាត់សូន្យ បងពូននឹកធិតា ។

៤. បើសិនជាតិនេះមាននិស្ស័យ ស៊ូប្តូរសង្ខ័យ ភក្តីជូនស្នេហា
បេះដូងតែមួយកាត់ជូនបុប្ផ បងលាមរណា បើរៀមរ៉ាគ្មានពៅ..... !!!!

00 00

00

CHANBOKEO.COM

# វគ្គទី២

# ចំណារជីវិត

តុក! តុក! តុក! ស្នូរគោះទ្វាររន្ទើនឡើង លាយឡំជាមួយស្នូរសំលេង នារីម្នាក់ស្រែកហៅ ៖

- បង ខេមឫទ្ធិ! ប៉ាមាក់មានគ្រោះថ្នាក់រថយន្ត.....

នៅមន្ទីរពេទ្យ.... បង!!

ខេមឫទ្ធិភ្ញាក់ស្មារតីព្រើត ស្ទុះងើបទៅបើកទ្វារឃើញនារីសំបុរស្រអែមម្នាក់ អើតមុខមក ព្រមទាំងស្រដីបន្តទាំងរន្ទើនផង ៖

- បង ! ជូនខ្ញុំទៅពេទ្យមួយភ្លែត...

- រចនា ! ចុះលោកទាំងពីរយ៉ាងណាដែរហើយអូន?

- ខ្ញុំមិនដឹងទេបង គ្រាន់តែមានគេទូរស័ព្ទមកប្រាប់ថា លោកមានរបួសធ្ងន់ណាស់!

រចនាឆ្លើយផង យកដៃជូតទឹកភ្នែកផង ។ ខេមឫទ្ធិទាញសោរឡាន ហើយ ស្ទុះទាញដៃរចនាសំដៅរថយន្តហើយក៏បរចេញទៅយ៉ាងលឿន ។ តាមផ្លូវ នាយ យើងមិនស្រដីអ្វីមួយម៉ាត់ទេ គឺគិតតែពីប្រឹងយ៉ាងណាឱ្យឆាប់ដល់មន្ទីរពេទ្យដោយ សុវត្ថិភាពតែប៉ុណ្ណោះ ។ រចនាភិតភ័យខ្លាំងពេក គិតតែពីក្តោបមុខយំ មិនបានចាប់ ភ្លឹកអ្វីទេ ។ លុះទៅដល់មន្ទីរពេទ្យ លោកវេជ្ជបណ្ឌិតមានប្រសាសន៍ប្រាប់អ្នកទាំងពីរថា លោកវ៉ាដេតជាឪពុករបស់រចនាបានបាត់បង់ជីវិតទៅហើយ ទោះបីគ្រូពេទ្យ ទាំងក្រុមបានខិតខំអស់ពីសមតសភាពទៅហើយក្តី ។ រីឯអ្នកស្រីមណីវិញក៏នៅ សន្លប់ស្តូកស្តឹងនៅឡើយ ។ រចនាឈរទ្រោបមុខលើស្មាខេមឫទ្ធិសោកសង្រេងមិន អស់មិនហើយ ចំពោះឧប្បត្តិហេតុដែលបណ្តាលឱ្យនាងបាត់បង់ឪពុកជាទីស្រលាញ់ ដោយមិនបានលាមួយម៉ាត់ ។ ណាមួយក្នុងចិត្តខ្វាយខ្វល់អំពីអាការៈរបស់ម្តាយ នាងមិនដឹងយ៉ាងណា ។ រីឯខេមឫទ្ធិឃើញតែគ្រវីក្បាលខាំមាត់ ទំនងហាក់ដូចជាសោកស្តាយរូបលោកវ៉ាដេតណាស់ ។ យូរៗម្តង យើងឃើញគេដកដង្ហើមធំៗ សំលឹងទៅពិដាន លួចលេបទឹកភ្នែកមិនឱ្យហូរធ្លាក់ចុះមក ។ មែនហើយ! ការពិត ខេមឫទ្ធិគ្រាន់តែជាក្មេងអនាថាមួយរូបដែលត្រូវរស់តាមវត្តវ៉ា យ៉ាងវេទនាយ៉ាប់ យ៉ឺនបំផុត ។ បើកុំតែបានត្រូវលោកវ៉ាដេតសង្គ្រោះយកមករស់នៅជាមួយគ្រួសារ របស់លោក ពេលនេះជីវិតរបស់នាយមិនដឹងជាក្លាយទៅជាអ្វីទេ។ ជាងម្ភៃឆ្នាំកន្លង មកនេះជីវិតនាយបានទទួលការកក់ក្តៅបំផុតពីសំណាក់គ្រួសារលោកវ៉ាដេត។ កាល ណោះ លោកវ៉ាដេតនិងភរិយាគ្មានបុត្រសោះ ក៏នាំគ្នាទៅវត្តធ្វើបុណ្យផ្សងសុំកូន មួយនិងគេ។ លុះប្រទះឃើញក្មេងតូចមួយគេងឈឺក្រោមកុដិលោក ក៏សង្គ្រោះយក ទៅព្យាបាលរហូតបានជាសះស្បើយ ហើយក៏ដាក់នាមថ្មីឱ្យថាខេមឫទ្ធិ។ ហេតុតែ ក្មេងម្នាក់នោះមានអំណោយទាន មានសេចក្តីព្យាយាម ឧស្សាហ៍រៀនសូត្រ ហើយ មានចរិតស្លូតបូត លោកក៏ថែរក្សាចិញ្ចឹមជាកូនជាចៅរហូតមក ។ ពីរឆ្នាំ ក្រោយពីទទួលយកខេមឫទ្ធិមកចិញ្ចឹម អ្នកស្រីមណីក៏ប្រសូត្របានបុត្រីមួយ យ៉ាង ស្រស់ស្អាត គឺរចនានេះឯង ។

0000000000000000

ខេមឫទ្ធិឈរកាន់កោដិនៅក្នុងដៃ ឈ្ងោកមុខភាវនាឧទ្ទិសកុសលដល់លោក វ៉ាដេតជាចុងក្រោយ នៅមុខចេតិយប្រចាំគ្រួសារមួយ ។ រចនានៅអង្គុយក្បែរ នោះធ្វើមុខស្រងូតស្រងាត់ ។ កាលបើរៀបចំទុកដាក់អដ្ឋិធាតុរបស់លោកវ៉ាដេត រួចហើយ

CHANBOKEO.COM

ខេមឫទ្ធិក៏ដឹកដៃប្អូនត្រលប់មកផ្ទះវិញ ។ តាមផ្លូវ នាយលួចមើលមុខ រចនាជាញយៗ ឃើញនាងមានអាការៈស្រកស្រុតច្រើនណាស់ តាំងពីមរណភាព របស់លោកវ៉ាដេតមក ត្បិតនាងមិនគេង មិនបរិភោគពីរបីថ្ងៃហើយ ។ ពេលចូល មកដល់ផ្ទះ មាណពក៏ជូនរចនាដល់បន្ទប់គេង ហើយក៏ស្ទុះរៀបចំដណ្ដាំបបរ ធ្វើម្ហូប ចិបចុបយ៉ាងរហ័ស ។ មួយស្របក់ក្រោយមក នាយក៏រៀបចំស្លាកអាហារយកទៅ ឱ្យរចនាដល់បន្ទប់នាង ៖

- រចនាអូន ! បងសុំចូលបានទេហ៎?

- ចាំ ចូលមកបង!

រចនាស្រវាក្រោកអង្គុយ គ្រាដែលឃើញខេមឫទ្ធិលើកថាសបបរចូលមក ៖

- ស្លាប់ហើយ ! ខ្ញុំមិនទាន់ឃ្លានទេណាំបង ! បំរើខ្ញុំយ៉ាងនេះ រចនាមុខជាធ្លាប់ខ្លួន មិនខានទេ ។

ខេមឫទ្ធិញញឹមលើកទឹកចិត្តមាណវី ៖

- ឱ្យតែអូនបានធូរស្បើយចិត្ត ត្រឹមកិច្ចការប៉ុណ្ណឹងមិនជាធ្ងន់ស្រាលអ្វីទេ ។ មោះ! ក្រោកញុំបន្តិចទៅអូន ដើម្បីឱ្យមានកំលាំង នឹងអាលទៅសួរសុខទុក្ខអ្នកម្ដាយ ឯមន្ទីរពេទ្យ ។

- បងខានធ្វើការប៉ុន្មានថ្ងៃហើយហ្នឹង? បើបងរវល់ បងទៅធ្វើការសិនចុះ ។ ចាំដល់ខ្ញុំសំរាកមានកំលាំង ខ្ញុំនឹងជិះម៉ូតូទៅមើលម៉ាក់ដោយខ្លួនឯងក៏បានដែរណាំ បង កុំឱ្យពិបាកបង ជូនខ្ញុំទៅមកៗ....

- ម៉េច? ចង់ដេញបងហើយហ្អែស ក្រមុំតូច? ការពិតបងសុំឈប់ដល់ទៅមួយ អាទិត្យឯណោះ ។ ហ៎កណេះ! ញុំាបបរសិនទៅណាំអូន ។

ឃើញខេមឫទ្ធិមានកិរិយាព្រួយបារម្ភពីនាងពន់ពេក រចនាក៏ស្រវាចានបបរ មកបរិភោគស្ងៀមស្ងាត់ ទុកឱ្យខេមឫទ្ធិអង្គុយសំលឹងនាង ទាំងទឹកមុខញញឹម ។ រំពេចនោះ ស្រាប់តែមានស្នូរទូរសព្ទ័មួយចូលមក ។ រចនាស្រវាឆ្លើយតបយ៉ាង ប្រញាប់ ។ បន្ទាប់ពីដាក់ទូរសព្ទ័ នាងក៏បែរមកខេមឫទ្ធិហើយស្រែកថា ៖

- ជយោ! ម៉ាក់ដឹងស្មារតីវិញហើយ បង ខេមឫទ្ធិ!!

ទាំងពីរនាក់ស្រវាអោបគ្នាយ៉ាងណែនដោយក្ដីត្រេកអរក្នុងចិត្តកាលបើបានដឹង ថាអ្នកស្រីមណីដឹងស្មារតីវិញ ។ គេក៏នាំគ្នារូតរះយ៉ាងប្រញិបប្រញាប់សំដៅមន្ទីរ ពេទ្យឥតបង្អង់ ។

000000000000000000

នៅលើគ្រែ អ្នកស្រីមណីបើកភ្នែកព្រឹមៗសំលឹងកូនទាំងពីររូប ៖

- រចនា ! ខេមឫទ្ធិ ! កូនសំលាញ់ម្ដាយ.......

ទាំងពីរនាក់ស្រវាក្ដាប់ដៃម្ដាយយ៉ាងណែន ។ ខេមឫទ្ធិ និយាយទៅកាន់អ្នក ស្រីមណីវិញថាទាំងទឹកមុខត្រេកអររំភើប :

- កូនសប្បាយចិត្តណាស់ កាលបើអ្នកម្ដាយ បានផុតគ្រោះភ័យ...

តុក! តុក!ៗ

លោកវេជ្ជបណ្ឌិតគោះទ្វារហើយក៏ដើរចូលមក ។ រចនាងើបឡើងជំរាបសួរ ៖

- លោកដុកទ័រ ! តើអាការៈម្ដាយរបស់ខ្ញុំយ៉ាងណាដែរ?

- អ្នកស្រីផុតគ្រោះថ្នាក់មែន តែត្រូវពិការត្រឹមចង្កេះចុះក្រោម ។ អ្នកទាំងពីរត្រូវ ថែរក្សាលោក ឱ្យបានល្អផង ។

ខេមឫទ្ធិបែរសំលឹងមុខម្ដាយដោយក្ដីស្រលាញ់គោរព ៖

CHANBOKEO.COM

- សូមអ្នកម្ដាយ កុំបារម្ភថ្វី ! កូនប្រុសមួយរូបនេះសន្យាថានឹងថែរក្សាអ្នកម្ដាយឱ្យ បានប្រពៃបំផុត ។ សូមអ្នកម្ដាយបានជាសះស្បើយឆាប់ៗនេះ ។

លោកវេជ្ជបណ្ឌិតក៏ញញឹមឡើងលើកទឹកចិត្ត ៖

- គួរឱ្យមានមោទនភាពណាស់ ដែលអ្នកស្រីមានបុត្រប្រកបដោយគុណធម៌យ៉ាង នេះ ។

អ្នកស្រីមណី សំលឹងមុខកូនហើយប្រឹងញញឹមទាំងអាការៈឈឺចាប់ ៖

- អរគុណកូនណាស់ ខេមឫទ្ធិ ម្ដាយពិតជាមានសំណាងណាស់ដែលនៅមានជីវិត ឃើញកូនទាំងពីរសាជាថ្មី ។

មិនយូរប៉ុន្មាន ជំងឺអ្នកស្រីក៏បានធូរស្រាល ហើយក៏ត្រូវបានទទួលការ អនុញ្ញាតិឱ្យចេញមកថែរក្សាសុខភាពនៅផ្ទះវិញ។ សព្វថ្ងៃរចនាសំរាកឈប់ពី សាលាដើម្បីនៅថែរក្សាម្ដាយពិការ ទុកឱ្យខេមឫទ្ធិធ្វើការម្នាក់ឯង ផ្គត់ផ្គង់ក្រុម គ្រួសារ ។ ថ្វីត្បិតតែថវិកាក្នុងផ្ទះហាក់ដូចជាស្រុតថយបន្តិច តែក្រុមគ្រួសាររបស់ គេមានសុភមង្គលណាស់ ។ មើលចុះ ! គេសប្បាយនឹងការជួបជុំជាគ្រួសារតែមួយ គ្មានហ្មង ។ រចនាក៏ជានារីដែលមានទឹកចិត្តស្លូតបូតហើយស្រលាញ់គោរពខេមឫទ្ធិ បំផុត ទោះបីជានាងដឹងថានាយមិនមែនជាបងប្អូនបង្កើតជាមួយនាងក៏ដោយ ។ រីឯអ្នកស្រីមណីវិញ លោកស្រលាញ់អ្នកទាំងពីរមិនមានលំអៀងខាងណាទេ ។ រាល់ ថ្ងៃអ្នកស្រីសប្បាយចិត្តណាស់ កាលបើឃើញខេមឫទ្ធិចេញមុខចេញមាត់ជាមេគ្រួសារ ទំនុកបំរុងអ្នកទាំងពីរមិនឱ្យមានខ្វះអ្វីឡើយ ។

oooooooooooooooooooooo

រសៀលថ្ងៃមួយ....

ខេមឫទ្ធិបររថយន្តមកដល់ផ្ទះភ្លាម ក៏ស្ទុះចេញដើរសំដៅទៅរកម្ដាយ ដែល នៅអង្គុយលើរទេះជនពិការ ជជែកលេងជាមួយរចនា ៖

- អ្នកម្ដាយ ! កូនមានការត្រូវជំរាបបាទ !

- មានរឿងអ្វីទៅកូន?

- កូនប្រហែលជាត្រូវឃ្លាតពីភ្នំពេញមួយពេលហើយ

- ម៉េចអីចឹងបងឫទ្ធិ? (រចនាសួរ)

- គឺបងបានទទួលការងារពីក្រសួង NGO ឱ្យទៅធ្វើការនៅសៀមរាបមួយពេល

- ព្រះអើយ ! ទៅយូរប៉ុណ្ណាទៅកូន? ម្ដាយច្បាស់ជានឹកកូនស្លាប់ហើយ ។

- មិនដឹងយូរប៉ុន្មានទេបាទ គឺខ្ញុំទទួលភារៈស្រាវជ្រាវប្រវត្តិនិងក្បាច់ចំលាក់ ដើម្បី ចងក្រងជាសៀវភៅសំរាប់កម្មវិធីអភិវឌ្ឍន៍សង្គម ។

រចនាធ្វើមុខស្មើ រួចក៏ស្រដីថា :

- បើសិនទៅយូរ បងឫទ្ធិនឹករចនាដែរទេហ៎?

មាណពសំលឹងមុខនាង ហើយសើចខឹកៗ :

- រួចចុះ ស្រីពៅចង់ឱ្យបងនឹកអូនប៉ុណ្ណាដែរ?

រចនាសំលឹងមុខនាយដោយក្រសែភ្នែកភ្លឺថ្លាផ្អែកៗ :

- គឺឱ្យបងនឹកតែខ្ញុំរាល់ថ្ងៃ មិនឱ្យនឹកអ្នកណាទៀតទេ...

CHANBOKEO.COM

- ហ្នឹងហើយ ! បងសូមសន្យាណា៎.... ថាបងនឹងនឹកតែប្អូនឱ្យរាល់តែថ្ងៃតែម្តង !!

ឮដូច្នោះ រចនាក៏ញញឹមពព្រាយឡើង :

- បងសន្យាហើយ មិនឱ្យលេបសំដីវិញទេ! រចនានឹងចងចាំសន្យារបស់បង ទុកហើយ ។

ខេមឫទ្ធិយកដៃអង្អែលក្បាលនាងបន្ថើរដោយក្តីស្រលាញ់ ។ ឃើញកូនទាំង ពីរស្គាល់ចិត្ត ស្គាល់ទុក្ខធុរៈគ្នាទៅវិញទៅមក អ្នកស្រីមណីសប្បាយចិត្តក្រៃលែង ។ រំពេចនោះ មានរថយន្តមួយបរមកចតនៅមុខផ្ទះ ។ អ្នកទាំងបីបែរមើលដោយ ងឿងឆ្ងល់ ស្រាប់តែខេមឫទ្ធិលាន់មាត់ឡើង :

- អូ៎អើ ! គឺនាយតាងរ៉ាងតើហ៎ ! អីសំលាញ់ សុខសប្បាយទេហ៎?

មែនហើយ នាយតាងរ៉ាងគឺជាមិត្តជិតដិតម្នាក់របស់ខេមឫទ្ធិ ។ បុរសនេះមាន នាមពិតប្រាកដថា សម សុរាង្គ តែដោយគេមានមាឌធំខ្ពស់សង្ហារគ្រាន់តែស្គមបន្តិច ទើបខេមឫទ្ធិចូលចិត្តនិយាយលលេងហៅថាតាងរ៉ាងទៅវិញ។ ថ្ងៃនេះ តាងរ៉ាង ស្លៀកពាក់ស្អាតបាត ចុះពីឡាន ដោយមានកាន់ផ្កាមួយបាច់យ៉ាងស្រស់ស្អាតមក ជាមួយ ផង ។ ខេមឫទ្ធិស្ទុះរត់ទៅទទួលយ៉ាងរហ័ស ហើយនិយាយលលេងថា :

- តាងរ៉ាង ! មកលេងម្តាយគ្នាម្តង ចាំបាច់ទិញផ្កាមកធ្វើអី ?

តាងរ៉ាងក្រលេកមើលទៅនាយយើងហើយសើចខឹក១ រួចតបថា ៖

- អ្នកណាថាខ្ញុំយកផ្កាមួយបាច់នេះមកជូនមនុស្សចាស់? ខុសហើយ!!

- បើមិនជូនមនុស្សចាស់ មានតែ....

ស្រាប់តែខេមឫទ្ធិទុចង៉ក់ សំលឹងទៅរចនា ហើយសំលឹងទៅតាងរ៉ាងវិញ ស្រាប់តែថ្លោះទឹកមុខភ្លាម ។ អ្នកស្រីមណីសង្កេតឃើញដូច្នោះ ក៏មានប្រសាសន៍ បន្លប់បរិយាកាសថា :

- តាងរ៉ាង ! សុខសប្បាយទេក្មួយ?

- បាទ ! សុខជាទេអ្នកមីង? ចុះអ្នកមីងវិញយ៉ាងណាដែរ?

ទោះបីតាងរ៉ាងកំពុងសន្ទនាឆ្លើយឆ្លងជាមួយអ្នកស្រីមណីក៏ពិតមែន តែក្រសែ ភ្នែករបស់នាយដោតភ្ជាប់តែលើរចនាតែម្នាក់ប៉ុណ្ណោះ ។ ខេមឫទ្ធិសង្កេតឃើញ ឫកពាររបស់មិត្តហើយ ក៏ស្ទុះយ៉ាងប្រញាប់ទាញបាច់ផ្កាពីនាយហើយស្រដីថា :

- សង្ស័យតែបាច់ផ្កានេះសំរាប់ជូនដំណើរខ្ញុំហើយ ត្បិតអីខ្ញុំត្រូវចេញទៅធ្វើការនៅ សៀមរាបថ្ងៃស្អែកនេះ....

ឮមាណពយើងពោលដូច្នេះ តាងរ៉ាងញញឹមស្ងួត សើចហែស១ដូចមិនទំនង តែដោយទើសទាល់ ក៏បណ្តោយឱ្យខេមឫទ្ធិអូសទាញបាច់ផ្ការបូតពីដៃទៅបាត់ ទុកឱ្យអ្នកស្រីមណីនិងរចនាសំលឹងធ្វើភាំងទាំងពីរនាក់ ។ ខេមឫទ្ធិឆក់យកបាច់ផ្កាហើយក៏ចោលកន្ទុយភ្នែកដាក់រចនា លួចញញឹមដាក់នាង រួចដើរចូលទៅ ក្នុងផ្ទះបាត់ទៅ ។ អ្នកស្រីមណី ក៏បោយដៃហៅតាងរ៉ាង :

- តោះ ! ក្មួយ ! ចូលទៅក្នុងផ្ទះ អង្គុយលេងសិនណា៎ !

- បាទ !

បន្ទាប់មក តាងរ៉ាង ក៏ឈានដើរពីក្រោយរចនាដែលកំពុងរុញរទេះផ្ទុកអ្នកស្រី មណីចូលទៅក្នុងផ្ទះដែរ ។

ព្រលប់ថ្ងៃនោះ តាងរ៉ាងបាននៅបរិភោគបាយរួមតុជាមួយអ្នកទាំងបីរូបយ៉ាង សប្បាយស្និទ្ធស្នាលបំផុត ។ ព្រមជាមួយគ្នានេះដែរ ខេមឫទ្ធិលួចចោលកន្ទុយ ភ្នែកសំលឹងរចនា សំលឹងតាងរ៉ាងមិនឈប់ឈរសោះ ទំនងហាក់ដូចជាមិនចង់ ឱ្យនាងមានចំណងសម្ពន្ធ័ផ្លូវចិត្តជិតដិតនឹងតាងរ៉ាងទាល់តែសោះ ។ អ្នកស្រីមណីក៏

CHANBOKEO.COM

សង្កេតឃើញដែរថាកូនប្រុសហាក់ដូចជាមានអារម្មណ៍ទើសទាល់ក្នុងចិត្ត ។ ទោះបី ជានាយខំប្រឹងធ្វើពើជារីករាយយ៉ាងណាក៏ដោយ ក៏មិនអាចលាក់ជិតនឹងក្រសែភ្នែក របស់អ្នកស្រីបានដែរ ។ លុះបរិភោគបាយហើយ តាងវ៉ាងក៏ជំរាបលាអ្នកទាំងបី ត្រលប់ទៅវិញ ។ បន្តិចមក រចនាក៏ប្រមូលចានក្បានរៀបទុកដាក់នៅក្នុងផ្ទះបាយ ទុកឱ្យ បងប្រុសនិងម្ដាយនៅជជែកគ្នាលេងតែពីរនាក់ ។ នៅក្នុងបន្ទប់ទទួលភ្ញៀវ អ្នកស្រីហៅកូនមក សួរថា :

- កូនប្រុសម្ដាយ! កូននិយាយប្រាប់ម្ដាយឱ្យត្រង់មកមើល តើកូនមានអារម្មណ៍ យ៉ាងណាចំពោះរចនា និងតាងវ៉ាង?

ខេមឫទ្ធិភ្ញាក់ព្រើតត្បិតមិនបានត្រៀមខ្លួនថាម្ដាយនឹងសួរនាយដូច្នោះទេ :

- គឺ.... គឺ... ខ្ញុំគិតថាអូនរចនានៅក្មេងណាស់... ទើបតែមានវ័យ២០ឆ្នាំ មិនគួរ បណ្ដោយឱ្យនាងឆាប់គិតគូរពីរឿងគូស្រករទេ តែគួរផ្ដល់ឱកាសឱ្យនាងបានរៀន សូត្របានខ្ពង់ខ្ពស់សិនណាំអ្នកម្ដាយ....

- តែ តាងវ៉ាងគេជាមនុស្សបពៃម្នាក់ មានការងារធ្វើ ហើយមានការសិក្សាខ្ពង់ខ្ពស់ យើងក៏មិនគួរបណ្ដោយឱ្យមនុស្សល្អរបូតពីដៃដែរមែនទេកូន?

ខេមឫទ្ធិព្រួយហើយឈ្ងោកមុខ :

- ប៉ុន្តែ.... ខ្ញុំអាចគ្រប់គ្រងទំនុកបំរុងក្រុមគ្រួសារយើងបានយ៉ាងគ្រប់គ្រាន់ មិនចាំបាច់ថែមកំលាំងបុរសម្នាក់ទៀតឡើយ...

- តែស្អែកនេះ កូននឹងចេញទៅធ្វើការនៅសៀមរាបហើយ... យើងទាំងពីរដែល នៅផ្ទះ ពិតជាត្រូវការបង្អែកខ្លះណាំកូន ។

ខេមឫទ្ធិដកដង្ហើមយូរ រួចលុតជង្គង់ចុះហើយស្រវាអោបចង្កេះម្ដាយយ៉ាង ណែន ព្រមទាំងរាំចាថា :

- ពិតមែនតែកូនឃ្លាតអ្នកម្ដាយ និងរចនាទៅពិត តែបេះដូងកូននៅផ្ញើក្នុងផ្ទះ របស់យើងជានិច្ច ។ កូនសន្យាថានឹងមកលេងផ្ទះឱ្យបានញឹកញាប់បំផុត ។ ចំពោះ រឿងតាងវ៉ាង កូននឹងសុំឱ្យគេទៅមកជួយដោះទុក្ខធុរៈអ្នកម្ដាយនិងប្អូនខ្លះៗ តែ...

- តែ យ៉ាងម៉េចទៅកូន? (អ្នកស្រីមណីសួរ)

- គឺ.... គឺ... សូមកុំឱ្យគេមានអ្វីជិតដិតនឹងអូនរចនាពេក...

- ហេតុអ្វីទៅ...? ឬក៏.... ?

អ្នកស្រីចាប់ចង្កាកូនប្រុសភ្ញើយឡើងសំលឹងមុខនាយ រួចសួរបន្ថែម :

- កូនប្រចណ្ឌនឹងតាងវ៉ាង ព្រោះកូនមានចិត្ត... ចំពោះប្អូនមែនទេ?

ខេមឫទ្ធិឈ្ងោកមុខចុះមួយស្របក់រួចហើយឆ្លើយខ្សិបៗថា :

- អ្នកម្ដាយ ! តើកូនមានកំហុសដែរទេហ៎ដែលកូនមានអារម្មណ៍ចំលែកបែបនេះ ចំពោះរចនា? សូមអ្នកម្ដាយជួយបំភ្លឺផ្លូវជីវិតដល់កូនផង...

ខេមឫទ្ធិផ្ដេកក្បាលលើជង្គង់ម្ដាយដែលអង្គុយក្នុងសាឡុង ។ អ្នកស្រីមណី យកដៃអង្អែលក្បាលកូន បន្ដើរៗរួចឆ្លើយថា :

- ម្ដាយដឹងតាំងពីយូរហើយថាកូនមានអារម្មណ៍យ៉ាងនេះ...

បុរសយើងភ្ញាក់ព្រើត :

- អ្នកម្ដាយជ្រាប?

- មែន! តែការដែលយើងស្រលាញ់នរណាម្នាក់នោះ មិនជាកំហុសទេកូន កាលបើ កូនស្រលាញ់ដោយដួងចិត្តស្មោះ និងមានគុណធម៌ចំពោះអ្នកដែលយើងស្រលាញ់ ។

- ចុះ.... ហេតុអ្វីអ្នកម្ដាយមិនខឹងនឹងកូន?

CHANBOKEO.COM

- ហេតុអ្វីម្ដាយត្រូវខឹងនឹងកូនផង កាលបើកូនមិនដែលធ្វើអ្វីឱ្យខុសឆ្គងគុណធម៌ នោះ ? ម្យ៉ាងទៀត ម្ដាយក៏ដឹងដែរថា រចនាច្បាស់ជាមានសេចក្ដីសុខពេញលេញ កាលបើបានទទួលការកក់ក្ដៅពីកូន ។ ចំពោះម្ដាយវិញ ម្ដាយមានសេចក្ដីសុខធំធេងណាស់ពេលដែលម្ដាយបានឃើញកូនៗមានសុភមង្គល...

- អ្នកម្ដាយ !.... កូនស្រលាញ់អ្នកម្ដាយណាស់ !! លោកជាព្រះសង្គ្រោះប្រណីដល់ ជីវិតកូនជានិច្ច !!!

ខេមឫទ្ធិត្រេកអរវរំភើបចិត្តរហូតអួលដើមក ហើយលូកដៃស្រវាអោបចង្កេះម្ដាយយ៉ាងណែនសាជាថ្មី ។ អ្នកស្រីមណីអង្អែលក្បាលកូនហើយក៏សួរបន្ថែមថា :

- តើកូនដឹងទេថា រចនាគេមានអារម្មណ៍យ៉ាងម៉េចដែរ ចំពោះកូន?

ខេមឫទ្ធិនៅស្ងៀមមួយស្របក់ទើបស្រដីតបថា:

- កូនមិនទាន់ដឹងទេ តែសូមអ្នកម្ដាយទុកឱកាសឱ្យនាងស្គាល់ចិត្តកូនតាមសំរួល ដោយគ្មានការបង្ខំចិត្តបន្តិចណាហើយកូនសន្យាថានឹងទទួលបានជានិច្ចនូវចំលើយ ដែលចេញពីដួងចិត្តនាងផ្ទាល់ ទោះបីជាចំលើយនោះ វិជ្ជមានឫអវិជ្ជមានក៏ដោយ ។

អ្នកស្រីឮដូច្នេះក៏ញញឹមឡើង :

- ប្រពៃណាស់កូន ! ស្នេហាពិតគឺត្រូវតែកើតឡើងដោយដួងចិត្តដែលស្ម័គ្រមេត្រី មិនមែនដោយសារការបង្ខំចិត្តនោះឡើយ ។

បន្តិចមក មាណពក៏ជូនម្ដាយចូលដំណេក ហើយក៏ដើរត្រលប់មកបន្ទប់របស់ ខ្លួន ស្រាប់តែប្រទះឃើញរចនានៅទីនោះ :

- រចនា ! អូនកំពុងធ្វើអីហ្នឹង ?

រចនាញញឹមបែរមករកនាយហើយតបវិញថា :

- ចាំសបង ! កំពុងរៀបឥវ៉ាន់ជូនបង សំរាប់ចេញដំណើរស្អែកនោះអី !

- ស្លាប់ហើយ ! ចាំបងរៀបខ្លួនឯងក៏បានដែរ ។ យប់ហើយណាំ អូនទៅគេងចុះ ។

- តែខ្ញុំ អត់ទាន់ងងុយទេ ចង់នៅនិយាយលេងជាមួយបង... ព្រោះស្អែកបងចេញ ទៅហើយ... ខ្ញុំច្បាស់ជាអផ្សុកណាស់!

ខេមឫទ្ធិ ដាក់ខ្លួនអង្គុយចុះលើគ្រែ ក្នុងឱកាសដែលរចនាកំពុងលុតជង្គង់នៅលើកំរាលបន្ទប់ បត់ខោអាវរៀបដាក់វ៉ាលីស ។ បុរសយើងសំលឹងមុខនាង ហើយក៏ពោលឡើងថា :

- រចនា ! ពេលបងមិននៅ អូនសរសេរសំបុត្រឫទូរស័ព្ទទៅលេងបងផងណាំ ។

មាណវីឮដូច្នោះ ក៏សើចញញឹម :

- រួចចុះបង នឹងតបមករចនាវិញទេ?

- តប ! គឺច្បាស់ជាតបហើយ ហើយឱ្យគ្រប់សំបុត្រទៀតផង

- តែរចនា សុំផ្ដាំណាំ ! បងកុំលួចមានសង្សារ ភ្លេចប្អូនឱ្យសោះ មិនបានទេ?

- បងសូមស្បថ... ថាបងមិនភ្លេចរចនាតែមួយរបស់បងឡើយ !

ខេមឫទ្ធិនិយាយផង លើកដៃស្បថផង ។ ឃើញហើយ រចនាញញឹមបញ្ចេញ ថ្ពាល់ខួចយ៉ាងស្រស់ រួចវាចាបន្តថា :

- សូមរក្សាពាក្យបងឱ្យពិតណាំ ! ពេលបងមិននៅ អូនច្បាស់ជានឹកបងណាស់ ។

- បាទ ! ហើយបងក៏នឹងឆ្លៀតមកលេងផ្ទះឱ្យបានញឹកញាប់ដែរ ពេលណាបងទំនេរ ពីការងារ ។

រាត្រីនោះ អ្នកទាំងពីរនៅជជែកលេងជាមួយគ្នាសើចរអឺករហូតពាក់អាធ្រាត ទើបលាទៅដំណេករៀងៗខ្លួន ។

ព្រឹកស្អែកឡើង...

CHANBOKEO.COM

ខេមឫទ្ធិកំពុងលើកវ៉ាលីសដាក់រថយន្តស្រាប់តែឃើញតាងរ៉ាងមកដល់ :

- Good Morning សំលាញ់ ! មកជូនដំណើរខ្ញុំមែនទេ? ( ខេមឫទ្ធិសួរ)

តាងរ៉ាងសើចហែស១ :

- បើមិនចឹ.... កុំសួរច្រើនមើស៍ !! តិចឈប់ធ្វើពួកម៉ាកជាមួយឥលូវ !!

ពិតមែនតែនាយស្រដីឆ្លើយឆ្លងជាមួយខេមឫទ្ធិមែន តែក្រសែភ្នែកតាងរ៉ាង សំលឹងទៅក្នុងផ្ទះឯណោះ ។ ឃើញហើយ ខេមឫទ្ធិសួរផ្ទាន់ :

- សង្ស័យតែរូបខ្ញុំនេះគ្រាន់តែជាស្ពានជ្រោយចង្វារតែប៉ុណ្ណោះឯងទេដឹងហ្ន៎???...

តាងរ៉ាងងាកមកវិញ សើចខឹក១ តបថា :

- នរណាថា? យី ! ឯងនេះយ៉ាប់មែន ។

ភ្លាមនោះ រចនាក៏រុញរទេះនាំម្តាយមកដល់ ។ តាងរ៉ាងក៏លើកដៃសំពះសួរអ្នក

អ្នកស្រីមណី ជូនចំពេលដែលរចនាពោលឡើងដែរ :

- បងតាងរ៉ាង ទៅសៀមរាបជាមួយបងឫទ្ធិដែរមែនទេហ៏?

- នរណាថា? ពុទ្ធោ... តាងរ៉ាងស្លាប់រស់នៅលើដីភ្នំពេញតែម្តុំគត់ ( ខេមឫទ្ធិញាក់ ស្មានិយាយចំអន់ឱ្យមិត្ត)

- ហែស១ ថាម៉េចក៏បាន តាងរ៉ាងមិនចេះប្រកែកទេ ( តាងរ៉ាងឆ្លើយតបវិញ)

ខេមឫទ្ធិក៏ឈ្ងោកមុខទៅជិតរចនា ហើយពោលខ្សិប១ដាក់នាងថា :

- ពេលបងមិននៅ ហាមផ្តាច់មិនឱ្យអូនទៅណាមកណាជាមួយតាងរ៉ាងទេណា៎

- ម៉េចអញ្ចឹង? ( រចនាធ្វើមុខឆ្ងល់)

- គឺបងប្រចណ្ឌ័ណា៎ ( មាណពខ្សិបតប)

ឮដូច្នោះ ស្រាប់តែរចនាខ្មាសឡើងក្រហាមមុខងាំង :

- និយាយតែផ្តាស បងឯងនេះ !

តាងរ៉ាងស្តាប់មិនឮថាអ្នកទាំងពីរនិយាយអ្វីទេ ក៏គ្រហែមបន្លប់ :

- មានគ្នាដល់ទៅបួននាក់ តែមានគេភ្លេចពីរនាក់ចោលបាត់ហើយ... ពុទ្ធោ!!!

អ្នកស្រីមណី ឮហើយក៏ញញឹម :

- គ្មាននរណាភ្លេចនរណាទេ... យ៉ាងហោចក៏គេនៅនឹកយើងក្នុងចិត្តរបស់គេដែរណា៎

តាងរ៉ាងឮហើយ ក៏សើច :

- អ្នកមីងពិតជាមានទឹកចិត្តទូលំទូលាយមែន ។

លុះរៀបចំឥវ៉ាន់រួចហើយ ខេមឫទ្ធិក៏សំពះលាម្តាយ អង្អែលក្បាលរចនា ហើយទះស្មាមិត្ត រួចក៏ឡើងរថយន្តបរចេញទៅ

ទុកបណ្តោយឱ្យអ្នកទាំងបីឈរ សំលឹងមើលពីក្រោយរហូតដល់ផុតកន្ទុយភ្នែក......

CHANBOKEO.COM

## លាមួយគ្រាសិន

១. បងសូមលាស្រីត្រឹមមួយគ្រា ណាំស្រស់សោភា ដើម្បីការងារភារកិច្ច
តែចិត្តបងនឹកស្រីគ្មានភ្លេច បុប្ផាទងពេជ្របណ្ដូលស្នេហ៍ ។

២. ថ្ងៃខ្លួនណាំអូនពេលបងឃ្លាត ឱ!ពៅវរនាថ មិនបាននៅបៀតថ្នមមាសមេ
ពេលគេងកុំភ្លេចសៀងបំពេរ ដែលបងធ្លាប់តែលួងលោមពៅ ។

៣. សុបិនឃើញបងផងណាំថ្លៃ មុំមាសចរណៃ កណ្ដាលរាត្រីយន់សែនជ្រៅ
រាលយប់បងផ្ដាំចន្ទ័ឆោមឆ្លៅ ឱ្យបំពេរពៅលក់ក្សេមក្សាន្ត ។

៤. ចាំបងណាំស្រីមាសពន្លក កុំឡើយសោយសោក រៀមនឹងវិលមករកកល្យាណ
ចាំពាក្យសន្យាណាំភុំផាន បងវិលមិនខានរួមស្នេហ៍យើង។

00 00

00

CHANBOKEO . COM

# វគ្គទី៣
# នគរចលាចល

ព្រឹកនេះ ខេមឫទ្ធិធ្វើដំណើរជាមួយសហការីពីរបីរូបទៀត សំដៅទៅ ប្រាសាទនគរវត្ត ។ ពីរបីម៉ោងក្រោយមក គេក៏បំបែកគ្នាទៅតាមមុខនាទីរៀង ខ្លួន ។ ខេមឫទ្ធិឈរកាន់កាម៉ារ៉ាមួយនៅដៃ ហើយមានស្ពាយសំពាយនៅស្មារយីង រយោងទៀតផង ។ មកដល់ចំពោះរូបចំលាក់អប្សរាមួយ ក្បែរខ្លោងទ្វារទិសខាង កើត មាណពមានអារម្មណ៍ថា ទេវីអប្សរានោះកំពុងបោយដៃហៅនាយរវិច១ ។ ខេមឫទ្ធិភ្ញាក់ព្រើតយកដៃឈ្លីភ្នែកម្តងហើយម្តងទៀត នៅតែឃើញត្រឹមរូបអប្សរា ចំលាក់ធម្មតាប៉ុណ្ណោះ មិនឃើញអ្វីប្លែកសោះ ។ នាយក៏លើកយកកាម៉ារ៉ាដាក់ជាប់ នឹងភ្នែកបំរុងនឹងថត ស្រាប់តែរូបចំលាក់អប្សរានោះក្លាយជាទេពនារីយ៉ាងសោភា មានជីវិតជាមនុស្សរស់កំពុងញញឹមដាក់នាយយ៉ាងស្រស់ទៀតផង ។ ខេមឫទ្ធិដាក់ កាម៉ារ៉ាចុះ ឈ្លីភ្នែកសំលឹងរូបចំលាក់ម្តងទៀតសាជាថ្មី តែលើកនេះ នាយបែរជា មិនឃើញអ្វីសោះដដែល ក្រៅពីរូបចំលាក់នឹងថ្មល់ជាប់នឹងជញ្ជាំង ។ បន្តិចមក នាយយើងគ្រវីក្បាលហើយ ក៏លាន់មាត់ថា :

- ហេតុអ្វីក៏ទេវីមួយរូបនេះមានរូបរាងសោភ័ណដូចគ្នាបេះបិត នឹងរូបរាជធិតាដែល នាយបានជួបកាលពីប៉ុន្មានថ្ងៃមុននោះម្លេះ? តើថ្ងៃនេះយើងសុបិន ឬក៏យើងកំពុង តែជួបការពិតមួយទៅហ្ន៎...?

ភ្លាមនោះ ខេមឫទ្ធិហាក់ដូចជាក្រអូបក្លិនផ្កាម្លិះភាយ១មកពីនាយ ថែមទាំងឮ ស្នូរចង្រ្កង់ជើងរ៉ឹក១ទៀតហើយ ។ បុរសយើងនឹកពិភាល់ក្នុងចិត្តណាស់ ក៏បោះ ជំហាន ដើរសំដៅទៅរកទិសសំលេង ដោយឆ្លងកាត់ក្លោងទ្វារចូលទៅដល់ខុទ្យាន ដ៏ត្រកាលមួយ ដូចដែលនាយធ្លាប់បានប្រទះម្តងរួចមកហើយកាលពីថ្ងៃមុន ។ កំពុងតែលង់អារម្មណ៍នឹងការងឿងឆ្ងល់ ស្រាប់តែមានសំលេងពោលពីក្រោយខ្នង របស់នាយថា :

- លោកវរសេនាខេមឫទ្ធិ ! ព្រះរាជករុណាទ្រង់មានបន្ទូលឱ្យចូលគាល់ឥឡូវនេះ !!

ខេមឫទ្ធិងាកផាំង ឃើញបុរសម្នាក់ក្នុងសំលៀកកងទ័ពពីបុរាណ មុខដូច តាងរ៉ាងបេះបិត ។ នាយក៏លាន់មាត់ :

- តាងរ៉ាង ? ម៉េចក៏ឯងចំលែកម្លេះ? មកសៀមរាបថតកុនរឿងអ្វីហ្នឹង បាន ជាឯងស្លៀកពាក់ចំលែកយ៉ាងនេះ? (ខេមឫទ្ធិស្រដីផងសើចរលាក់ខឹក១ផង)

- ប្របាទទាន ! លោកវរសេនាមានប្រសាសន៍អ្វីដែរ? បាវមិនយល់ទេ!!

- គឺ... ខ្ញុំកំពុងសួរឯងថា ហេតុអ្វីក៏ឯងក្លាយជាមនុស្សបុរាណយ៉ាងនេះទៅវិញ? រួចហើយវាម៉េចបានជាហៅខ្លួនឯងថា បាវ បាវ... យ៉ាងនេះ?

- បាវមិនយល់ទេ ទានប្រោស !! តែយ៉ាងណា សូមតេជគុណមេត្តាចូលគាល់ ព្រះអង្គឥលូវនេះជាប្រញាប់ ។

ភ្លាមនោះ ស្រាប់តែ មានបុរសបីបួនរូបមកស្រវាចាប់លើកខេមឫទ្ធិដាក់ទៅ លើទីនាំងមួយយ៉ាងល្អប្រណិតបំផុតក្នុងជីវិត ដែលមាណពយើងមិនដែលឃើញពី មុនមកសោះក្នុងជីវិតរបស់នាយ ។ លុះហែនាយទៅដល់ដំណាក់មួយ ពួកគេក៏ចាប់ ខេមឫទ្ធិផ្លាស់ប្តូរសំលៀកជាមេទ័ពយ៉ាងសង្ហារមួយរូប ។ ខេមឫទ្ធិមានអារម្មណ៍ ចំលែកក្នុងចិត្តណាស់

CHANBOKEO.COM

ប៉ុន្តែពួកគេធ្វើការស្រុសគ្នាហើយរហ័សមើលមិនទាន់រកតែ នាយសួរអ្វីនិយាយអ្វីក៏មិនទាន់ដែរ។ កំពុងតែស្លុងអារម្មណ៍ សួរសំលេងចង្រ្កង់ជើងរ៉ឹក១បានឈានចូលមកដល់មាត់ទ្វារ ។ នាយយើងភ្ញាក់ព្រើតបែរក្រសែភ្នែកទៅ ស្រាប់តែប្រទះឃើញទេពធិតាដ៏ផូផង់មួយរូប។ ខេមឫទ្ធិក៏លាន់មាត់ខ្សិប១ :

- រាជធិតា សុរភីមល្លិកា...

កាលបើឮនាយលាន់មាត់ហៅចំព្រះនាមរបស់ព្រះនាង រាជធិតាក៏ញញឹម យ៉ាងស្រស់ឡើង ព្រមទាំងមានសវនីយ៍តបវិញយ៉ាងពិរោះ :

- បងខេមឫទ្ធិ ! អូនសប្បាយចិត្តណាស់ពេលឃើញបងវិលត្រលប់មកវិញ ។ បាត់រូបបងប៉ុន្មានថ្ងៃ អូនបារម្ភពីសុខទុក្ខរបស់បងពន់ពេកក្រៃ ។ ម្យ៉ាងទៀត ថ្ងៃនេះជាថ្ងៃជ័យមង្គលរបស់បងផង បានបងវិលវិញ ព្រះបិតាពិតជាសប្បាយ ព្រះទ័យ ធូរស្រាលពីរោគាពាធមិនខានទេ ។

ខេមឫទ្ធិឈរសំលឹងទេវីយ៉ាងភ្លន់ភ្លឹកសឹងភ្លេចដកដង្ហើម ។ នាយមិនបានឮ ព្រះនាងមានសវនីយ៍ថា យ៉ាងណាទេ ព្រោះនាយកំពុងលង់ស្មារតីលង់អារម្មណ៍នឹង សោភ័ណដ៏ត្រកាលរបស់ព្រះនាងតែម្យ៉ាងប៉ុណ្ណោះ ។ ពុទ្ធោអើយ! ពេលនេះនាយ ភ្លេចអ្វី១អស់ហើយក្នុងជីវិត កាលបើបានមកឈរចំពោះភក្ត្ររាជធិតាដ៏សែន សោភា រកពាក្យពេចន៍ណាមកថ្លែងឱ្យសមស្មើមិនបានឡើយ ។ ព្រះនាងញញឹម សែនស្រស់សំនៀងក៏សែនពិរោះ ថែមទាំងមានកិរិយាយកចិត្តទុកដាក់យ៉ាង ស្និទ្ធស្នាលចំពោះនាយថែមទៀត ធ្វើឱ្យនាយយើងរឹងរិតតែរំភើបចិត្តហួសព្រំដែន តែម្តង ។ ភ្លាមនោះរាជធិតាក៏លូកព្រះហស្តស្តាំរបស់ព្រះនាងមកចាប់ដៃឆ្វេងរបស់ មាណពយើងហើយក៏មានសវនីយ៍បន្តថា :

- បង ខេមឫទ្ធិ? ហេតុអ្វីក៏សំលឹងមុខអូនចំលែកម្ល៉េះ?

ខេមឫទ្ធិភ្ញាក់ព្រើត ខំឆ្លើយវិញទាំងតតាក់តតុប ត្បិតនាយនឹកមិនឃើញ សោះថា តើនាយនិងរាជធិតាស្គាល់គ្នាពីអង្កាល់ ហើយមានចំណងសម្ព័ន្ធមេត្រី ដួងចិត្តនោះតាំងពីអង្កាល់មកដែរ ហេតុអ្វីក៏នាយនឹកមិនឃើញសោះឥចឹង :

- គឺ.... គឺ..... សូមរាជធិតាព្រះរាជទានទោស... ដែលទូលបង្គំមានស្មារតីមិន.. ប្រក្រតី...

- យ៉ាងម៉េចហ្នឹង? ហេតុអ្វីក៏បងហៅខ្លួនបងថាជាទូលបង្គំយ៉ាងនេះទៅវិញ ? ឬក៏ បងផ្លាស់ប្តូរចិត្ត ភ្លេចសន្យារបស់យើងហើយ...

ព្រះអើយ!! តើឱ្យនាយយើងឆ្លើយយ៉ាងណាទៅហ្ន៎ បើនាយមិនដែលដឹងផង ថានាយធ្លាប់សន្យាអ្វីជាមួយព្រះនាងពីមុនមកផង ? ក្នុងឱកាសដែលរាជធិតាកំពុង
ជ្រួញចិញ្ចើមរង់ចាំចំលើយពី ខេមឫទ្ធិ ស្រាប់តែតាងវ៉ាងនាយសេនាចូលមកដល់ :

- បរពិត្ររាជធិតា ! ពិធីពិសេសចាប់ផ្តើមហើយ ! ព្រះចៅរាជបិតាទ្រង់មាន
បន្ទូលឱ្យចូលព្រះនាងនិងលោកវរសេនាខេមឫទ្ធិចូលគាល់ឥលូវនេះ ក្រាបទូល ។

រាជធិតាបែរភក្ត្រមកវិញ ហើយបក់ដៃឱ្យនាយនាំក្បួនដង្ហែនាំព្រះនាង និង ខេមឫទ្ធិ ចេញដំណើរយ៉ាងរហ័សសំដៅព្រះរាជវាំង ។ មាណពយើងដកដង្ហើម យូបន្ធូរការតានតឹងក្នុងចិត្ត ។ ទោះជាយ៉ាងណាក៏នាយមិនអាចទប់ចិត្តមិនឱ្យរំភើប រំជើបរំជួលមិនបានដែរ ត្បិតថ្ងៃនេះរូបនាយមានវាសនាយ៉ាងចំលែកបំផុតដែលបាន មកអង្គុយលើទីនាំង ក្បែរព្រះរាជធិតាសុរភីមល្លិកាដ៏មានរូបឆោមលោមពណ៌ល្អឥតមានទេវីណាប្រដូចបាន ។ តាមផ្លូវ នាយលួចចោលកន្ទុយភ្នែកលួចមើលភក្ត្រ ព្រះនាងជាញយ១
ហើយក៏ប្រទះក្រសែភ្នែករបស់ព្រះនាងដែលញញឹមយ៉ាងផ្អែម ល្ហែមតបមកនាយវិញជាញឹកញាប់ដែរ ធ្វើឱ្យនាយមានអារម្មណ៍ថា ខ្លួននាយកំពុងហោះហើរអណ្តែតត្រសែតនៅសួគ៌ស្រីង្គាយ៉ាងសប្បាយអស្ចារ្យ ។ ព្រមជាមួយគ្នា នោះ ខេមឫទ្ធិសង្កេតឃើញមានអ្នកស្រុក មានហ្វូងសេនាមានភិលៀងជាច្រើន ឈរជារបងកត្តិយសស្រែកជ័យឃោសន៍អឺងកង តែមិនដឹងថាគេកំពុងស្រែកជ័យ ឃោសន៍សំរាប់អ្វីទេ គ្រាន់តែឮតែស្នូរទ្រហឹងស្តាប់មិនយល់តែប៉ុណ្ណោះ ។ បន្តិច ក្រោយមក ក្បួនដង្ហែក៏បានមកដល់ឧទ្យានដ៏ប្រណិតនាមុខព្រះបរមរាជវាំង ។

CHANBOKEO.COM

នៅទីនោះ ខេមឫទ្ធិប្រទះឃើញព្រះ មហាក្សត្រចំណាស់មួយព្រះអង្គកំពុងប្រថាប់ រង់ចាំនាយជាស្រេច
ដោយមានអាការៈហាក់ដូចជាមានអាពាធផង ។ នាយក៏ចុះ
ចេញពីទីនាំងដើរតាមពីក្រោយរាជធិតា ចូលទៅថ្វាយបង្គំព្រះអង្គភ្លាម ។ កាលបើ យល់វត្តមានរបស់ខេមឫទ្ធិកាលណា
ព្រះចៅក៏មានព្រះរាជបន្ទូលថា :

- ម្នាលចៅខេមឫទ្ធិ ! យើងត្រេកអរណាស់ដែលអ្នកចូលមកទទួលពរជ័យពីយើង ថ្ងៃនេះ ។
យើងក៏សូមចូលរួមកាន់មរណទុក្ខផងដែរដែលលោកឪពុករបស់នាយ បានត្រូវអស់សង្ខារក្នុងសមរភូមិ មិនប៉ុន្មានថ្ងៃកន្លងទៅ ។ ម្យ៉ាងទៀត ម្តាយ របស់អ្នកក៏បានស្លាប់បាត់បង់ជីវិតព្រមទៅដែរ ក្រោយពេលដែលបានទទួលដំណឹង ថា លោកឪពុករបស់អ្នកបានត្រូវខ្មាំងប្រល័យជីវិត....

មានបន្ទូលមកដល់ត្រង់នេះ ព្រះចៅសំដែងទឹកមុខស្រងូត សំលឹងភ័ក្ត្ររបស់ ខេមឫទ្ធិ ហើយយកដៃទៅអង្អែលក្បាលរបស់នាយ ដែលកំពុងអោនក្រាបបង្គំ ព្រះ អង្គនៅចំពោះមុខ :

- តែយើងមានមោទនភាពខ្ពង់ខ្ពស់ណាស់ចំពោះក្រុមគ្រួសាររបស់នាយដែលបាន បំរើនគរដោយស្មោះស្ម័គ្របំផុត ។
ក្នុងចំណោមមេទ័ពទាំង១០រូប លោកឪពុក របស់អ្នកបានទទួលការទុកចិត្តពីយើងច្រើនជាងគេ ។ កាលបើអស់ពីលោកទៅ
យើងគិតថាគ្មាននរណាសក្តិសមនឹងទទួលដំណែងបន្តវេនក្រៅពីរូបអ្នកតែម្នាក់គត់ !

ឮដូច្នោះ ខេមឫទ្ធិភ្ញាក់ស្រលាំងកាំងងើបមុខធ្វើភ្នែកមូលក្រឡង់ ត្បិតមិនដឹង ថាត្រូវឆ្លើយទទួលយល់ព្រមឬក៏យ៉ាងណាវិញ បើខ្លួនមិនដឹងមិនយល់អ្វីទាំងអស់ យ៉ាងនេះ ។ ម្យ៉ាងទៀត នាយក៏តក់ស្លុតខ្លាំងណាស់ដែរ កាលបើបានដឹងដំណឹងថា លោកមេទ័ពនិងភរិយាបានធ្វើមរណកាលទៅទាំងពីរនាក់ជួនគ្នា មិនដឹងថានាងតូច ខេមរីសុខទុក្ខយ៉ាងណាទៅហើយ ។
ឃើញខេមឫទ្ធិមានកិរិយារារែកចំលែក ព្រះចៅក៏មានព្រះរាជបន្ទូលបន្តទៀតថា :

- កុំភ្ញាក់ផ្អើលអីណាំខេមឫទ្ធិ ! នៅមានរឿងដែលយើងចង់ឱ្យអ្នកបំពេញមួយមុខ ទៀតសំរាប់យើងផងដែរ...

ខេមឫទ្ធិងើបឡើងតាមព្រះចៅមហានគរដែលទាញដៃនាយឱ្យក្រោកឈរ ។
ភ្លាមនោះ ព្រះអង្គក៏មានបន្ទូលឡើងថា :

- ម្នាលបុរសក្លាហានអើយ! យើងដឹងថាអ្នកមានដួងចិត្តមេត្រីចំពោះរាជធិតាសុរភី មល្លិកាបុត្រីទោលរបស់យើងជាយូរឆ្នាំហើយ ដូច្នេះថ្ងៃនេះ
យើងចង់ភ្ជាប់សម្ពន្ធ័ មេត្រីជាគូដណ្តឹងត្រឹមត្រូវតាមបវេណី មុននឹងអ្នកចេញទៅបំពេញការសឹកនៅលើ
សមរភូមិបណ្តេញខ្មាំងចេញពីទឹកដីមហានគរ ។ លុះអ្នកវិលវិញដោយជោគជ័យ នោះយើងនឹងអភិសេករូបអ្នកជាមួយរាជធិតារបស់យើង
ហើយទទួលគ្រប់គ្រងរាជ បល្ល័ង្ក បន្តពីយើងតរៀងទៅ...

ម្តងនេះ ខេមឫទ្ធិភ្ញាក់ក្រញាងមានអារម្មណ៍ ហាក់ដូចជាកំពុងធ្លាក់ពីចុងដូង ឥចឹង... អស្ចារ្យម្ល៉េះហ្ន៎!!
សុខៗស្រាប់តែបានឡើងបុណ្យសក្តិជាមេទ័ព មិនតែ ប៉ុណ្ណោះ ថែមទាំងមានវាសនាខ្ពស់ក្រៃ ដែលបានមកទទួលអភិសេកជាមួយទេព
ទេវីដ៏មានរូបឆោមស្រស់សោភានោះទៀតផង ។ មាណពរំភើបចិត្តផង ភ័យអរៗ ផង លាយឡំគ្នា
មិនដឹងថាកិច្ចការសឹកក្នុងកងទ័ពនោះយ៉ាងម៉េចយ៉ាងម៉ាទេ ព្រោះមិនដែលចេញធ្វើសង្គ្រាមម្តងណាសោះ ។ តែបើប្រកែកវិញ នាយហាក់ដូចជា
នឹងសោកស្តាយក្នុងចិត្តស្លាប់ហើយ ត្បិតនាយនឹងខានរៀបអភិសេកនឹងរាជធិតា ដែលនាយបាក់ចិត្តគួចបេតីពេញបេះដូងទៅហើយ ។
តើនាយត្រូវគិតយ៉ាងណាទៅ គ្រានេះ បើអ្វីៗកើតឡើងប្រថុចញ៉ុចរហូតគ្មានឱកាសគិតគូរអ្វីយ៉ាងអញ្ចឹង ?
ខេមឫទ្ធិដាក់ភ្នែកលួចមើលទៅរាជធិតាសុរភីមល្លិកា ស្រាប់តែប្រទះនឹងក្រសែ ភ្នែករបស់ព្រះនាងសំលឹងមករកនាយវិញ
ដោយមានស្នាមញញឹមយ៉ាងល្អត្រកាល ធ្វើឱ្យនាយឈ្លក់វង្វេងនឹងសេចក្តីស្នេហាចំពោះទេវីយើងរិតតែខ្លាំងឡើង រកហារ

CHANBOKEO.COM

មាត់និយាយអ្វី ប្រកែកអ្វីមិនរួចសោះឡើយ ។

វិពេចនោះ តន្ត្រីក៏ចាប់ប្រគំឡើងយ៉ាងរន្ថើន ។  នារីរបាំមួយក្រុមក៏ចេញមក បង្ហាញខ្លួនលើទីលានវេទិកា ពន់ពេនកាយាយ៉ាងល្វតល្ងន់គួរចេតនាពន់ពេកក្រៃ ។ ខេមឫទ្ធិលេបទឹកមាត់ក្អឹកផ្អើមបំពង់ក ។ ឯបេះដូងនាយវិញក៏កាន់តែរំភើប ញាប់ញ័រឡើងគគ្រឹកពេញក្នុងដើមទ្រូង ។ ពិធីមង្គលភ្ជាប់ចំណងដួងចិត្តរវាង កំលោះយើងនិងរាជធិតាក៏ឧប្បត្តិកឡើងយ៉ាងគគ្រឹងគគ្រេង ដោយមានព្រឹទ្ធជន មហាជន នាម៉ឺនមន្ត្រី និង សេនាភិលៀងជាច្រើនចូលរួមផង ។ តែខេមឫទ្ធិយើង នៅតែងឿងឆ្ងល់មិនបាត់សោះថាតើអ្វីដែលគេជួបប្រទះថ្ងៃនេះជាការពិតឬទេ ឬក៏ គ្រាន់តែជាសុបិនមួយដ៏ចំលែកក្នុងជីវិតរបស់នាយតែប៉ុណ្ណោះ ។ មាណពលួចយក ដៃមួលក្តិចខ្លួនឯងយ៉ាងឈឺជាច្រើនដង ហើយក៏ខិតខំឈ្លីភ្នែកជាញឹកញាប់ ។ ទោះ ជាយ៉ាងណា នាយនៅតែមានអារម្មណ៍អ្វីដែលនាយប្រទះប្រត្យក្ស័នឹងកែវភ្នែកនោះ ជាការពិតទាំងស្រុង ។ ប៉ុន្តែនាយនៅតែមិនអស់ចិត្តថាហេតុអ្វីនាយបែរជាធ្លាក់មក នៅក្នុងយុគកាលពីរាប់រយឆ្នាំមុនទៅវិញ ។ មើលចុះ! មានតែនាយម្នាក់ទេដែល មានកិរិយាប្លែកហើយមឹងមាំងជាងគេ ។ រីឯអ្នកដទៃវិញ ហាក់ដូចជាមិនចាប់ អារម្មណ៍ចំពោះនាយឡើយ ក្រៅពីនាំគ្នាអបអរសាទរចំពោះការភ្ជាប់ចំណងមេត្រី រវាងនាយនិងរាជធិតាតែម្យ៉ាងប៉ុណ្ណោះ ។ ក្រលេកមើលទៅសុរភីមល្លិកា បុត្រីព្រះ ចៅមហានគរវិញ ក៏មានព្រះភក្ត្រ័រីករាយក្រៃលែង ។ ប្លែកអ្វីតែ ព្រះចៅមួយ ព្រះអង្គនិងមហាមន្ត្រីបួនដប់រូបទេដែលមានទឹកមុខព្រួយកង្វល់យ៉ាងធ្ងន់ ទោះបី ជាខិតខំប្រឹងញញឹមយ៉ាងណាក៏ដោយ ក៏មិនអាចលុបបំបាត់ភាពខ្វាយខ្វល់អន្ទះសា នៅលើផ្ទៃមុខបានដែរ ។

មុននឹងបញ្ចប់ពិធីភ្ជាប់មេត្រីរវាងរាជធិតានិងចៅមាណពខេមឫទ្ធិ ព្រះចៅ មហានគរបានកោះហៅសេនាឱ្យយកដាវដ៏ល្អប្រណិតមួយចូលមក រួចក៏មានរាជ បន្ទូលទៅកាន់មាណពយើងថា :

- ម្នាលមេទ័ពខេមឫទ្ធិដ៏ក្លាហាន ! ចូរអ្នកទទួលដាវឯកសិទ្ធិរបស់យើងនេះ ហើយ នាំទ័ពទៅព្រំដែនមហានគរខេមរតនី ការពារទប់ទល់កុំឱ្យបច្ចាមិត្តលុកលុយចូល បុរីមហានគរ រំលោភធ្វើបាបប្រជាពលរដ្ឋយើងបាន...

រួចហើយ ព្រះអង្គប្រឹងលូកព្រះហស្ថទាំងញ័រ១ទទ្រើក ដោយការទទួល អាពាធជាយូរឆ្នាំ លើកយកដាវដ៏ភ្លឺរលោងនោះ ហុចឱ្យទៅមេទ័ពក្មេងរបស់យើង ហើយក៏មានរាជសព្ទ័ជាបន្តថា :

- យើងសង្ឃឹមលើអ្នកទាំងស្រុងថានឹងនាំសន្តិភាពជូនមហានគរបានឆាប់ៗនេះ ។

oooooooooooooooooooo

លុះពិធីចប់សព្វគ្រប់ ខេមឫទ្ធិស្ទុះដើរចេញទៅក្រៅរាជវាំង ក្នុងចិត្តគិតថា បំរុងចេញទៅរករាជទេវីសុរភីមល្លិកា នៅឯរាជដំណាក់របស់ព្រះនាង  ស្រាប់តែ នាយបានឮសូរសៀងយ៉ាងគ្រលួចមួយចេញពីម្ខាងឧទ្យានបទុម :

ត្រកាលស្នេហ៍

ផ្កាឈូករេរាំតាមវាតា            ក្នុងទឹកបឹងថ្លាយល់បាតដី
មច្ឆាហែលលេងសប្បាយក្រៃ      ក្រោមពន្លឺថ្ងៃរះត្រចះ.....

CHANBOKEO.COM

ខេមឫទ្ធិក្រលេកទៅឃើញរាជធិតាប្រថាប់លើថ្ពាំងសិលា ពន្លាកេសាដ៏វែង អន្លាយលំអដោយផ្កាម្លិះយ៉ាងក្រអូប ឃើញភក្ត្រដ៏ត្រចង់កំពុងញញឹមមករកនាយ ព្រមជាមួយនិងសូរសៀងដ៏ពិរោះហាក់បីសៀងសួគ៌ា មាណពរំភើបចិត្តអ្វីម្ល៉េះទេ ។ មួយជីវិតនេះ នាយមិនដែលមានអារម្មណ៍រំភើបចំលែកយ៉ាងនេះសោះ ។ មាណព ឈរគយគន់រាជធិតា ស្តាប់សូរសៀង ចំរៀងដ៏ពិរោះមានន័យរបស់ព្រះនាងយ៉ាង ភ្លន់ភ្លឹកស្មារតី ។ ពេលនោះ ស្រាប់តែព្រះនាង ទុចង៉ក់ឈប់ច្រៀងកណ្តាលផ្លូវ កាលបើព្រះនាងបែរឃើញនាយយើងភ្លាម ។ ទេពទេវីក៏មានសវនីយ៍យ៉ាងរីករាយ ទៅកាន់មាណពយើងថា :

- បងខេមឫទ្ធិ ! បងចូលចិត្តច្រៀងបទចំរៀងមួយនេះណាស់ តើបងចាំបានទេ?

ហើយយើងក៏ធ្លាប់ច្រៀងឆ្លើយឆ្លងគ្នាទៀតផង ។

ព្រះអើយ!! ខេមឫទ្ធិភ្ញាក់ភើតពោះ ត្បិតនាយមិនដឹងថានាយចេះច្រៀងបទ អ្វីទេហើយធ្លាប់ច្រៀងពីកាលណា។ កំពុងលង់ចិត្តគិតតែម្នាក់ឯង នាយយើងបាន ឮព្រះរាជធិតាសុរភីមល្លិកា មានសវនីយ៍បន្ត :

- ថ្ងៃនេះ... អូនចង់ច្រៀងបទនេះជាមួយបងសាជាថ្មី... តើបងអាចច្រៀងជាមួយ អូនបានទេហ៎ ?

ម្តងនេះ ខេមឫទ្ធិ ភ្ញាក់ផ្អើលកាន់តែខ្លាំងហើយអន្ទះសាក្នុងចិត្តណាស់ គិតថា តើនាយត្រូវធ្វើយ៉ាងណាឱ្យសមបើនាយមិនដែលចេះច្រៀងម្តងណាផង...

- គឺ.... បង... គឺ....

ខេមឫទ្ធិឆ្លើយតបវិញទាំងតតាក់តតុប ។ រំពេចនោះ ស្រាប់តែព្រះនាងលូក ហត្ថារបស់ព្រះនាងមកស្រវាកាន់ដៃស្តាំរបស់ខេមឫទ្ធិ ហើយអូសដៃនាយដើរ សំដៅទៅមាត់ស្រះ ដែលនាយធ្លាប់ជួបប្រទះព្រះរាជធិតានៅថ្ងៃដំបូង ។ កាលបើ ឃើញខេមឫទ្ធិមានទឹកមុខប្លែកខុសធម្មតា រាជធិតាក៏ញញឹមឡើង ហើយបន្លឺ សវនីយ៍ទៅកាន់មាណពថា :

- យើងខានច្រៀងបទនេះយូរឆ្នាំហើយ ប្រហែលជាបងភ្លេចហើយទេដឹង ?ប៉ុន្តែ អូនចង់រំលឹកបទនេះសាជាថ្មី ចាត់ទុកដូចជាចំណងដៃពិសេសរបស់អូន ចំពោះបង មុននឹងបងឃ្លាតចេញទៅធ្វើសឹកនៅឯជាយដែនមហានគរ ។

ពោលមកដល់ត្រង់ ធិតាសំដែងទឹកមុខស្រងូត :

- ទោះបីជាយ៉ាងណា ក៏អូននៅតែរង់ចាំការវិលត្រលប់របស់បងជានិច្ច.... !!!!

រួចហើយ ព្រះនាងក៏បន្លឺសំនៀងយ៉ាងពិរោះ នូវបទចំរៀងមួយបទចំពោះ បុរសយើងបន្តថែមទៀត :

| | | |
|---|---|---|
| ស. | លើចុងព្រឹក្សាបក្សាយំ | ឯនាយជើងភ្នំ អរុណរះ |
| | ឮដំរីហែហស៏ពពកជាស | នាំខ្យល់អាកាសបរិសុទ្ធ ។ |
| ប. | សារិកាបូលយំខ្ទងក្របី | ក្រអូបផ្កាព្រៃចិត្តស្រយុត |
| | លង់ស្នេហ៍ធំធេងដូចសមុទ្រ | លាតឆ្ងាយវែងផុតឥតកោះត្រើយ ។ |
| ស. | ទេសភាពត្រកាលថ្នាលដួងចៃ | បំពេរហឫទ័យឱ្យយល់ស្បើយ |
| ប. | ធម្មជាតិភិរម្យគួរកៀកកើយ | ដូចមុំត្រាណត្រើយនិងរូបបង ។ |
| ស. | យើងស្រលាញ់គ្នាថ្ងៃប្រែ | ស្មោះស្មគ្រ័នឹងស្នេហ៍ឥតសៅហ្មង |
| ប. | ជាតិនេះជាតិណាសច្ចាផ្សង | ជួបតែនោមយង់ជាគូអើយ.... |

CHANBOKEO.COM

ខេមឫទ្ធិភ្ញាក់ស្មារតីព្រើត នឹកក្នុងចិត្តមិនយល់សោះថា ហេតុអ្វីថ្ងៃនេះ នាយ បែរជាចេះច្រៀងបទនេះយ៉ាងគ្រលួច ហើយថែមទាំងច្រៀងតបទៅរាជធិតាវិញ បានយ៉ាងពិរោះទៀតផង ។ កំពុងតែភន្ត័ភាំង រាជធិតាក៏យាងចូលមកជិត ហើយ សំលឹងមុខមាណព ដោយក្រសែភ្នែកដ៏មានទឹកដមស្នេហាធំធេងមិនអាចពណ៌នា បាន រួចក៏មានសវនីយ៏ថា :

- បង ខេមឫទ្ធិ ! អូននឹងរង់ចាំបង... ចាំថ្ងៃដែលយើងទាំងពីររៀបអភិសេកនឹងគ្នា ជាគូគ្រង.... សូមបងចេញធ្វើសឹកឱ្យបានជោគជ័យធំធេងជូននគរយើងណាំបង !!!

ខេមឫទ្ធិ ឈ្ងោកមុខសំលឹងនេត្រាដ៏ខ្មៅថ្លាយង់របស់ទេវី ក្នុងចិត្តរំភើបជ្រួល ច្រាលញាប់ញ័ររកថាមិនត្រូវ...

- រាជធិតា ! បងពិតជាវិលវិញមកជួបព្រះនាងជាមិនខាន ។ រៀមសូមសន្យា!!

ស្រដីរួចហើយ នាយក៏បន្ទាបនាសាប្រាថ្នានឹងស្រង់ស្រូបក្លិនថ្ពាល់ដ៏ល្អផូផង់ របស់ព្រះនាង ។ រីព្រះនាងក៏បិទនេត្រាទទួលយកទាំងព្រះភក្រ្តញញឹមគួរបេតី....

ស្រាប់តែមានសំលេងមួយស្រែកកាត់ឡើង :

- លោកមេទ័ពមហាសេនា ខេមឫទ្ធិ ! សត្រូវឡោមពទ្ធ័មហាបុរីយើងហើយ... ឥឡូវនគរយើងកំពុងតែចលាចលណាស់ទានប្រោស !!

គូស្នេហ៏ទាំងទ្វេភ្ញាក់កន្ត្រាក់ បើកនេត្រាធំៗដោយការភ្ញាក់ផ្អើលជាខ្លាំង ។ លុះ អ្នកទាំងពីរកាយងាកក្រោយក្រលេកទៅ ឃើញតាងវាំងនាយសេនានាំទ័ពយ៉ាង ច្រើនខ្ទាន់ខ្ទាប់ចូលមកដល់ហើយ រួចក៏នាំរូបខេមឫទ្ធិចេញទៅយ៉ាងរូសរាន់ប្រញាប់ ប្រញាល់ក្រៃលែង ។ ព្រមជាមួយគ្នានោះដែរ ម៉ែសង្វារបាននាំភិលៀងជាច្រើន មកហែហមរាជធិតាសុរភីមល្លិកាឱ្យចេញទៅរកបិតាយ៉ាងអាសន្នដូចគ្នា ។ រាជ ធិតារត់ត្រលប់ទៅរាជវាំងបណ្តើរ បែរក្រោយស្រែកផ្តាំពីនាយល្វើយៗមកមាណព យំងបណ្តើរ ថា :

- បង ខេមឫទ្ធិ!! អូនស្រលាញ់បង ហើយរង់ចាំបងជានិច្ច !! កុំភ្លេចវិលវិញមករក អូនកុំខានណាំបងណាំ....

ខេមឫទ្ធិឮហើយក៏បង្អន់ល្បឿនសេះដែលកំពុងផាយ ហើយក៏ស្រែកតបមក ព្រះនាងយំងវិញដែរ :

- បងពិតជាវិលមករកអូនវិញមិនខាន... សូមថែរក្សាព្រះកាយផង!!!

ភាពចលាចលក្នុងបុរីបានបំបែកគូស្នេហ៏ទាំងពីរឱ្យបែកគ្នា ទាំងដួងចិត្តអាល័យ បំផុត.... មានតែទឹកភ្នែកម្យ៉ាងប៉ុណ្ណោះដែលអាចជួយបន្ធូរភាពតានតឹងក្នុងបេះដូង របស់គេទាំងពីរ ។ ខេមឫទ្ធិមានអារម្មណ៏ហេងហោងក្នុងខ្លួនយ៉ាងណាមិនដឹងទេ តាំងពីឃានជើងឃ្លាតចេញពីរាជធិតាមក ។ បេះដូងនាយហាក់ដូចជាស្លោក ស្រពោនខុសធម្មតា នឹកអាណិតតែរូបរាជធិតាក្នុងចិត្តឥតរសាយ មិនដឹងថាតើព្រះ នាង និងព្រះវរបិតាសុខទុក្ខយ៉ាងណាទេពេលនេះ ។ ខេមឫទ្ធិបំផាយសេះផង លង់ ស្មារតីក្នុងការគិតផង ស្រាប់តែមានដាវហោះខ្ទាប់កាប់ពីក្រោយ រិះដាច់សក់របស់ នាយយើង ។ លុះនាយបើកភ្នែកក្រលេកមើលឡើង ឃើញខ្មាំងបិទមុខដោយ ក្រណាត់ខ្មៅជិះសេះដេញកាប់នាយប្រផិតៗខ្លួង ឃើញអ្នកស្រុករត់ច្រវាត់ច្រវែង ឃើញសាកសពស្តូកស្តឹងពាសវាលពាសកាល ឃើញកងទ័ពមហានគរប្រឹងប្រយុទ្ធ យ៉ាងស្វិតស្វាញបំផុត ។ ប៉ុន្តែគួរឱ្យឆ្ងល់ណាស់ មាណពយើងមិនដែលរៀនគុនដាវ ម្តងណាឡើយក្នុងជីវិត ស្រាប់តែពេលនេះនាយយើងប្រើដាវយ៉ាងប៉ិនប្រសប់ហើយ លឿនដូចផ្លេកបន្ទោរ ។ ផ្លែដាវហោះហើរដូចរន្ទះប្រយុទ្ធតទល់ជាមួយខ្មាំងឥត រួញរាបន្តិចសោះឡើយ ។ កំពុងតែជាប់ដៃនឹងបច្ចាមិត្តជាច្រើននាក់ ស្រាប់តែនាយ ឮសូរសំរែកក្មេងស្រីម្នាក់ យ៉ាងគ្រលួច :

CHANBOKEO.COM

- បង ខេមឫទ្ធិ !! ជួយខ្ញុំផង !! បង ខេមឫទ្ធិ!!!

មាណពងាកផាំងក្រលេកមើលទៅឃើញ ពពួកសត្រូវមួយហ្វូងកំពុងបំផាយ សេះដេញតាមប្រហារកុមារីជំទង់មួយរូប ព្រមជាមួយអ្នកស្រុកពីរបីនាក់ទៀត ។ នាយក៏លាន់មាត់ឡើង :

- នាងតូចខេមរី...!!!!

ថាហើយ នាយក៏បំបោលសេះយ៉ាងលឿនចូលទៅវាយលុកជួយសង្គ្រោះនាង ភ្លាម រួចហើយឆក់នាងដាក់លើខ្នងសេះបំបោលចេញយ៉ាងរហ័ស ប្រាថ្នានាំនាងគេច ពីការយាយីរបស់ខ្មាំងដែលកំពុងបំបោលសេះដេញទាំងហ្វូងតាមក្រោយ ។ ពេល នោះ ស្រាប់តែមានព្រួញមួយហោះស្វេរយ៉ាងលឿនមកទំលុះខ្នងរបស់នាយ ធ្លាយទៅដល់ដើមទ្រូងខាងមុខ :

- អ៊ុំយ!!!! ខេមឫទ្ធិ(ស្រែកឡើងដោយការឈឺចាប់)

ចុងព្រួញបានធ្លាយចាក់រហូតដល់ដើមស្មារបស់នាងតូចខេមរី :

- បង ខេមឫទ្ធិ!! បងត្រូវរបួសហើយ...

- បងមិនអីទេ!! នាងតូចកុំបារម្ភអី!!! (មាណពនិយាយបន្ទប់)

ការពិតខេមឫទ្ធិកំពុងមានការឈឺចាប់ក្រៃលែង តែនាយខំាមាត់មិនបង្ហាញ ការឈឺចាប់ឱ្យនាងតូចបានឃើញឡើយ ត្បិតខ្លាចនាងភិតភ័យ ។ នាយយើងពឹតតែ ពីប្រឹងបំបោលសេះគេចរត់រហូតដល់មាត់ជ្រោះមួយ ។ លុះនាយងាកក្រោយ សំលឹងពិនិត្យស្ថានការណ៍ នាយនៅតែឃើញខ្មាំងដេញតាមយ៉ាងខ្មៅមីរណែនណាន់ ខ្មាន់ខ្មាប់ដដែល ក៏ដាក់នាងតូចខេមរីចុះពីខ្នងសេះ បំរុងនាំនាងហែលឆ្លងទឹក ដេម្បី ទៅរកកន្លែងលាក់ខ្លួន ស្រាប់តែនាយងងិតមុខឈឹង ដួលគ្រេងទៅលើដី ហើយក៏ បាត់ស្មារតីទៅ ទុកចោលឱ្យនាងតូចនៅត្រមង់ត្រមោច យំខ្លោចផ្សារតែម្នាក់ឯង កណ្តាលភាព ចលាចលវឹកវរទាំងឡាយ....

00 00

00

CHANBOKEO.COM

# វគ្គទី៤

# ស្មារតីវង្វេងកាល

- បងខេមឫទ្ធិ ៗ!!

ខេមឫទ្ធិឮសំលេងមនុស្សស្រីខ្សិបហៅនាយល្វើយៗក្នុងត្រចៀកជាច្រើនដង។ នាយខំប្រឹងលេបទឹកមាត់បំបាត់ការឈឺចាប់ ហើយក៏បើកភ្នែកឡើង សំលឹងមើលជុំវិញខ្លួន ស្រាប់តែប្រទះនឹងនារីមួយរូបកំពុងមានទឹកមុខរីករាយ និយាយមកកាន់ នាយបន្តថា :

- បង ខេមឫទ្ធិ ! បងដឹងខ្លួនវិញហើយ ! អូនត្រេកអរណាស់ ។

នាយប្រឹងរកនឹកក្នុងថាតើនាងជានរណា... ស្រាប់តែនាងស្រដីមករកនាយ បន្ថែមទៀតថា :

- បង! មើលនែ៎ក! ម៉ាក់ក៏អញ្ជើញមកមើលបងដល់សៀមរាបនេះដែរ...

ភ្លាមនោះ នាងក៏រុញរទេះនាំស្ត្រីចំណាស់ម្នាក់ចូលមកជិតគ្រែដែលខេមឫទ្ធិ កំពុងគេង ។ តែនាយយើងមើលមិនច្បាស់ទេ នៅស្រវាំងភ្នែកនៅឡើយ ។ ស្ត្រី ចំណាស់ក៏លូកដៃអង្អែលថ្ងាសកូនប្រុសហើយក៏បន្លឺវាចាថា :

- តើឥឡូវនេះកូនមានអារម្មណ៍យ៉ាងណាដែរហើយ ខេមឫទ្ធិ...?

- អ្នកម្តាយ!!!....

ខេមឫទ្ធិពោលហៅខ្សិបៗ ។ មែនហើយ! នោះគឺអ្នកស្រីមណីនិងរចនាកូនស្រី របស់លោក ។ មាណពក៏ពោលសួរបន្តថា :

- តើកូននៅទីណា??...

- នៅមន្ទីរពេទ្យណាំកូន... ខេមឫទ្ធិ!! កូនបាត់ស្មារតីយូរថ្ងៃហើយ ។ ថ្ងៃនេះ កូន មានស្មារតីមកវិញ ម្តាយធូរស្បើយក្នុងចិត្តណាស់ ! ម្តាយនិងរចនាបានមកនៅរង់ ចាំថែទាំកូនជិតមួយអាទិត្យហើយ ។

- ចាំទ? ម៉ាក់មានប្រសាសន៍ថាម៉េច? កូនបាត់ស្មារតីជិតមួយអាទិត្យហើយ?? ( ខេមឫទ្ធិស្រដីសួរទាំងភ្ញាក់ផ្អើលទៅអ្នកស្រីមណី ) ហេតុអ្វីបានជាដូច្នោះទៅវិញ អញ្ចឹង អ្នកម្តាយ??

- គឺមិត្តរួមការងាររបស់កូនទាំងពីររូប បានទូរសព្ទ័ទៅប្រាប់ម៉ាក់កាលពីអាទិត្យមុន ថាគេឃើញកូនមានគ្រោះឧប្បត្តិហេតុសន្លប់បាត់ស្មារតីតែម្នាក់ឯង ឯប្រាសាទនគរ វត្ត ក្បែរក្លោងទ្វាររបងខាងកើត ទើបម្តាយដេញរចនាឱ្យនាំមកមើលកូននៅ មន្ទីរពេទ្យនេះតែម្តង ទៅ ។

ឮមកដល់ត្រង់នេះ ខេមឫទ្ធិយកដៃឈ្លីថ្ងាស បែរមើលទៅចុងជើងរបស់ខ្លួន ឃើញរចនាកំពុងគក់ ច្របាច់ជើងឱ្យនាយយ៉ាងថ្នមៗ ។ នាយក៏ងាកមើលទៅម្តាយ ហើយក៏ស្រដីថា :

- ឱ្យកូនសូមទោសអ្នកម្តាយផង ដែលធ្វើឱ្យលោកបារម្ភចំពោះកូនយ៉ាងនេះ ។ ខ្ញុំ គិតថា ខ្ញុំមានអារម្មណ៍ធូរស្រាលមកវិញហើយ ។

រចនាបែរមុខមកនាយហើយក៏និយាយទៅកាន់នាយវិញថា :

- បងឃ្លានពិសារបាយទេហ៎? អូននឹងទៅដួសជូនបង...

- មិនបាច់ទេអូន... គ្រាន់តែភ្ញាក់ឡើងឃើញមុខអូននោះ បងធូរស្រាល វិញលែង ឈឺហើយណាំ ( ខេមឫទ្ធិឆ្លើយលួងលោមមិនឱ្យនាងបារម្ភ)

CHANBOKEO.COM

រចនាឮហើយញញឹម :

- ពុទ្ធោ! មិនដឹងសោះថាមុខរចនាជាឱសថទេពដល់ម្លឹងហ្ន៎?(នារីនិយាយលលេង)

ខេមឫទ្ធិញញឹមតបវិញហើយក៏ស្រវាច្រត់ដៃបំរុងក្រោកអង្គុយ ។ ភ្លាមនោះ នាយមានអារម្មណ៍ថាឈឺចុកចាប់ក្នុងខ្លួនណាស់ ហើយថែមទាំងផ្អៀងខ្លួនរកកលនឹង ដួលទៀតផង ។ រចនាឃើញដូច្នោះស្ទុះរត់មកត្រកងទប់នាយជាប់ ។ ពេលនោះ ខេមឫទ្ធិក្រអូបផ្កាម្លិះភាយ ចេញពីកេសាដ៏ខ្មៅរលីបរបស់កញ្ញារចនាដ៏ស្រស់ស្អាត មាណពភ្ញាក់ព្រើតលាន់មាត់ភ្លាម :

- រាជធិតា ?!!?!!

រចនាឮដូច្នោះ ក៏សើចខឹកៗ :

- យ៉ាងម៉េចហើយហ្នឹងបង ? គ្រាន់តែឃើញអូនចងផ្កាម្លិះនៅលើសក់ ស្រាប់តែ ច្រលំហៅអូនជារាជធិតាទៅហើយ...? ឬក៏បងនៅមិនស្រួលខ្លួនមមើមមាយនៅ ឡើយទេ??

ខេមឫទ្ធិ ភ្ញាក់ព្រើតសំលឹងមុខនាង :

- រចនាទេហ៍?? រួចចុះឯណារាជធិតាសុរភីមល្លិកា? ព្រះនាងនៅឯណា? ខេមរី!! តើនាងយ៉ាងណាដែរ?

មាណពខំប្រឹងស្ទុះងើបម្តងទៀត តែក៏ត្រូវដួលត្មោលទៅក្នុងរង្វង់ដៃរចនាវិញ ដដែល ថែមទាំងមានអារម្មណ៍ថាចុកចាប់ក្នុងប្រាណពេកកន្លង ។ រចនាសំលឹងមុខ ម្តាយហើយក៏សំលឹងមុខនាយវិញទាំងងឿងឆ្ងល់ហើយបារម្ភផង :

- ប្រហែលជាបងមានរបួសនៅខ្នងធ្ងន់ពេកទេដឹង បានជាវង្វេងវង្វាន់និយាយអ្វីៗ ចំលែកយ៉ាងនេះ?

អ្នកស្រីមណីក៏មានចំងល់ដូចគ្នា :

- មែនហើយកូន ! ម៉ាក់បារម្ភពីកូនប្រុសម៉ាក់ណាស់ ។ឆាប់ទៅតាមលោកគ្រូ ពេទ្យមក !

-ចា៎ស!!

រចនាផ្តេកកាយមាណពទៅលើខ្នើយវិញយ៉ាងថ្នមៗហើយក៏ស្ទុះចេញទៅក្រៅ ជាប្រញាប់ ។រីឯ ខេមឫទ្ធិវិញនៅតែទន្ទេញជាប់មាត់ហៅរករាជធិតាសុរភីមល្លិកា និងនាងតូចខេមរីមិនដាច់ពីមាត់សោះ ។

មួយភ្លែតក្រោយមក រចនាក៏វិលមកបន្ទប់វិញដោយមាននាំលោកគ្រូពេទ្យ មកតាមផង ។ មាណពបើកភ្នែកឡើងសំលឹងលោកគ្រូពេទ្យ ស្រាប់តែប្រទះ ឃើញតាងរ៉ាងដើរចូលមកដល់ដៃក្នុងសំលៀក សម័យថ្មីហ៊ឺហាបែបសម័យថ្មី ។ នាយក៏លាន់មាត់ឡើង :

- តាងរ៉ាង? ហេតុអ្វីក៏ឯងប្តូរតួលឿនម្លេះ?

តាងរ៉ាង សំលឹងមើលមុខ ខេមឫទ្ធិ ហើយឈ្ងោកសំលឹងខ្លួននាយ ធ្វើភាំង :

- ខេមឫទ្ធិ!! ឯងនិយាយស្អីហ្នឹង ស្តាប់មិនបានទេ? តាងរ៉ាងមានតែមួយមិនដែល ប្តូរតួម្តងណាទេ? សង្ស័យតែមិត្តមានរបួសធ្ងន់វង្វេងវង្វាយខ្លាំងហើយ...

ភ្លាមនោះគិលានុបដ្ឋាកយិកាពីរបីរូបចូលមកដល់ ស្រវាលើក ខេមឫទ្ធិឡើង លាងរបួសមួយនៅខ្នងយ៉ាងវែង ទំនងដូចត្រូវអ្វីមុតយ៉ាងជ្រៅទៅក្នុងសាច់ ។ បន្ទាប់មកលោកវេជ្ជបណ្ឌិតក៏ចាក់ថ្នាំ ហើយព្យួរសេរ៉ូមបន្ថែមឱ្យនាយមួយកំប្លោក ទៀត ។ បន្តិចក្រោយមកលោកវេជ្ជបណ្ឌិតក៏បែរមកមានប្រសាសន៍ប្រាប់អ្នកទាំង បីថា :

- កូនប្រុសរបស់អ្នកស្រីត្រូវមែកឈើបាក់សង្កត់ មុតជ្រៅចូលសាច់ខ្នងមែន តែមិន មានអ្វីជាគ្រោះថ្នាក់ដល់ជីវិតទេ គ្រាន់តែគ្រាំបន្តិចបន្តួចដែលបណ្តាលឱ្យគ្រុនក្តៅ មមើមមាយខ្លះៗ មិនយូរប៉ុន្មានទេ គេនឹងជាសះស្បើយវិញហើយ ។

CHANBOKEO.COM

ថាចប់លោកក៏នាំពេទ្យនារីចេញទៅអស់ ។ តាងវ៉ាងក៏ដើរទៅជិត ខេមឫទ្ធិ ហើយស្រដីថា :

- ឆាប់ជាណាំសំលាញ់ !!

ខេមឫទ្ធិសំលឹងតាងវ៉ាងឥតពព្រិចភ្នែកទេ... នាយនៅតែនឹកឆ្ងល់ក្នុងចិត្តថាតើ អ្វីដែលគេជួបប្រទះប្រត្យក្សនឹងនេត្រាកន្លងមកនោះ ជាការពិតឬទេ? ប៉ុន្តែទោះ ជាយ៉ាងណា ក៏នាយមានការនឹករលឹកហើយបារម្ភចំពោះសុខទុក្ខរបស់រាជធិតានិង នាងតូចខេមរីជាប់ដក់ក្នុងចិត្តជានិច្ច ។ រំពេចនោះស្រាប់តែនាយដាក់ភ្នែកសំលឹង ទៅចុងគ្រែ ឃើញតាងវ៉ាងញញឹមហើយដាក់ខ្លួនអង្គុយចុះក្បែររចនា ព្រមទាំង ពូនាយនិយាយទៅកាន់នាងថា :

- រចនា! អូនអត់ងងុយកំដរនាយឫទ្ធិអស់ជាច្រើនយប់ ហើយ ទុកឱ្យបងនៅមើល ថែរក្សាអ្នកម្ដាយរបស់អូនឯផ្ទះសំណាក់ មើលទៅអ្នកមីងដូចជាបារម្ភពីអូនហើយ ។ ថ្ងៃនេះ អូនគួរទៅសំរាកគេងយកកំលាំងខ្លះៗទៅណ៎ា ។ ម្យ៉ាងទៀត នៅពេទ្យនេះ នាយឫទ្ធិក៏បានគ្រាន់បើបន្តិចហើយ រួចទទួលការបំរើយ៉ាងដិតដល់ពីមន្ទីរពេទ្យ ទៀតផង ។ ដូច្នេះ គួរតែអូនថែរក្សាសុខភាពខ្លួនឯងផងណ៎ា ។

រចនាញញឹមបំរុងនឹងតបវិញ ស្រាប់តែ ខេមឫទ្ធិត្អូញកាត់ផ្ទួង :

- រចនា!!... (មាណពថាផងយកដៃស្ទាបថ្ងាសផង) រចនា!! បងក្ដៅមុខក្ដៅមាត់ ណាស់ សុំជូតខ្លួនឱ្យបងបន្តិចមក....

រចនាឮដូច្នោះ ក៏ក្រលេកបែរមកនាយ ហើយស្ទុះយកកូនកន្សែងពោះគោទៅ ជ្រលក់ទឹកក្ដៅជូតខ្លួនឱ្យនាយភ្លាមឥតបង្អង់ ។ តាងវ៉ាងសំលឹងមើលតាម ភ្នែកសោះ ។ ចំណែកអ្នកស្រីមណីឃើញហើយក៏សើចញឹមៗ ធ្វើហាក់ដូចមិនដឹង ហេតុការណ៍អ្វីទាំងអស់ ។

ពីរបីថ្ងៃក្រោយមក អ្នកស្រីមណីក៏សុំអនុញ្ញាតពីគ្រូពេទ្យខេមឫទ្ធិមក ព្យាបាលនៅផ្ទះឯភ្នំពេញវិញ ទោះបីមាណពយើងទទូចសុំនៅសៀមរាបបន្តក៏ដោយ ព្រោះអីអ្នកស្រីឃើញកូនមមើមមាយចំលែកៗដូច្នោះ មិនទុកចិត្តថានាយនឹងថែ រក្សាខ្លួនឯងបានល្អឡើយ ។ ដោយទើសទាល់ ខេមឫទ្ធិត្រូវបង្ខំចិត្តវិលមកភ្នំពេញ វិញ ។ ការពិត ករណីដែលជំរុញអោយនាយយើងវិលមកផ្ទះវិញនោះ ក៏គឺព្រោះ ដោយសារតែនាយមានអារម្មណ៍មិនល្អសោះ ពេលណានាយបានឃើញតាងវ៉ាង មានអាការៈ ជិតដិតស្និទ្ធស្នាលនឹងរចនាពេក ។

0000000000000000000000000

នៅភ្នំពេញ....

ខេមឫទ្ធិអង្គុយនៅមាត់បង្អួចសំលឹងទៅក្រៅតែម្នាក់ឯង ។ កំពុងតែបណ្ដែត អារម្មណ៍អណ្ដែតអណ្ដូង ស្រាប់តែរចនាដើរចូលមកដោយកាន់អាហារមួយថាស មកផង :

- បងឫទ្ធិ!! ដល់ម៉ោងពិសារបាយហើយ !

ខេមឫទ្ធិងាកមកមើលនាង ហើយក៏ស្រដីថា :

- រចនា! បើបងនិយាយប្រាប់អូនពីរឿងចំលែកមួយ តើអូនជឿបងទេហ៎?

មាណវីងើបមុខឡើងញញឹម ហើយមានវាចាតបវិញថា :

- ចា៎ស! ជឿ!! ព្រោះតាំងពីតូចដល់ធំ បងមិនដែលភូតខ្ញុំម្ដងណាទេ..

- តែរឿងនេះចំលែកណាស់... បងគិតមិនយល់សោះណាំអូន ហើយបងចង់បក ក្រោយទៅសៀមរាបដើម្បីស្វែងរកការពិតមួយ...

CHANBOKEO.COM

រចនាងើបមុខឡើងសួរភ្លាម :

- ការពិតពីរឿងរាជធិតាសុរភីមល្លិកានោះមែនទេហ៍?

- មែនហើយ... ហ្អាក់!? ! ចុះអូនដឹងរឿងអ្វីពីព្រះនាងដែរ???

- ចាំស! អត់ទេ ! ប៉ុន្តែធ្លាប់ឮបងមមើមមាយហៅរកតែឈ្មោះរាជធិតាអង្គនោះ ព្រមទាំងមានហៅឈ្មោះនាងតូចខេមរីថៃមទៀតជាញឹកញាប់ណាស់ ។ ម៉ាក់និងខ្ញុំ កំពុងឆ្ងល់ដូចគ្នាថា តើហេតុអ្វីបានជាបងមានអាការៈចំលែកម្ល៉េះ តាំងពីបងមាន គ្រោះឧប្បត្តិហេតុមួយនោះមក...

ខេមឫទ្ធិឈ្ងោកមុខសំដែងការព្រួយក្នុងចិត្ត ។ រចនាឃើញហើយក៏ស្ទុះទៅជិត រួចចាប់ដៃបងប្រុសអង្អែលថ្នមៗ :

- បងត្រូវការឱ្យរចនាជួយបងអ្វីខ្លះទេហ៍?? អូននឹងជួយបងគ្រប់បងគ្រប់ប្រការ ដែលអូនអាចធ្វើបាន ។ ឃើញបងកើតទុក្ខអំពល់ក្នុងចិត្តយ៉ាងនេះ ចិត្តអូនក៏ស្ដោក ស្រពោនដែរណាំបង...

ខេមឫទ្ធិងើបមុខឡើង  ឃើញរចនារលីងរលោងទឹកភ្នែក នាយក៏នឹកអាណិត នាងព្រួចក្នុងចិត្ត ហើយលាន់មាត់តិចៗ :

- រចនា!!

ខេមឫទ្ធិនាយយកដៃអង្អែលសក់រចនា រួចហើយក៏ចាប់ខ្លួននាងមកផ្ទោបនឹង ដើមទ្រូងរបស់ខ្លួនយ៉ាងណែន :

- អរគុណអូនណាស់ដែលអូនយល់ចិត្តរបស់បង...

ខេមឫទ្ធិស្រដីទាំងរំភើបចិត្តកាលបើឃើញមាណវីមានសន្ដានចិត្តជួយឈឺឆ្អាល នឹងសុខទុក្ខរបស់នាយ ។ តាមការពិត នៅកំលុងពេលនេះ នាយយើងចាប់មាន អារម្មណ៍ច្របូកច្របល់ក្នុងចិត្តកាន់តែខ្លាំង ថាតើការដែលនាយបានជួបជីវិតដល់ ទៅពីរ ក្នុងឱកាសតែមួយនោះ តើមួយណាជាការពិតសំរាប់រូបនាយទៅ??... ទោះជាយ៉ាងណាក្ដី ការដែលនាយបានវិលមកផ្ទះ ឃើញមុខម្ដាយ ឃើញមុខរចនា នាយគិតថាជីវិតរបស់នាយមានសេចក្ដីសុខបំផុត ខុសពីគ្រាដែលនាយជួបនឹងរាជ ធិតា អ្វីៗជុំវិញខ្លួនសុទ្ធតែប្រកបដោយភាពចលាចលចំលែកណាស់ ។ តែបើឱ្យ នាយឈប់គិត ឈប់នឹករលឹករាជធិតាមួយព្រះអង្គនោះ នាយច្បាស់ជាធ្វើមិនបាន ទេ មិនដឹងជាហេតុអ្វីបានជានាយមាន អារម្មណ៍ប្រតិពទ្ធ័ជាប់ជំពាក់នឹងព្រះនាងដល់ ម្ល៉ឹង ។ តាមពិតទៅ នាយបានលង់ក្នុង សេចក្ដីស្នេហាចំពោះរាជធិតា រហូតដល់ទៅ ហ៊ានប្ដូរជីវិតរបស់ខ្លួនដើម្បីព្រះនាងទៅហើយ ។ តើមកពីនិស្ស័យអ្វីទៅហ្ន៎....? នាយយើង គិតយូរទៅនៅតែមិនយល់ដដែល ។

0000000000000000000000000000

ថ្ងៃមួយ....

ព្រឹកនេះ ខេមឫទ្ធិមានអារម្មណ៍ថាខ្លួនមានកំលាំងដូចប្រក្រតីវិញហើយ ក៏ ងើបស្លៀកពាក់យ៉ាងស្អាតបាតដើរចេញមកពីបន្ទប់គេងមក ស្រាប់តែឮសូរសំលេង រថយន្តមួយមកដល់មុខផ្ទះ :

- ច្បាស់ជានាយតាងវ៉ាងទៀតហើយមើលទៅ...

ខេមឫទ្ធិ គិតដូច្នោះហើយក៏ស្ទុះយ៉ាងប្រញាប់ចុះទៅទទួលមិត្ត ស្រាប់តែទង្គិច គ្នានឹងរចនាដែលដើរចេញពីបន្ទប់បាយមកដែរ ។ ទាំងពីរនាក់ដួលត្មោលទៅលើ កំរាលផ្ទះ ។ រាងកាយរបស់នាយយើងក៏ដួលសង្កត់លើនារីទាំងជំហរ រីឯច្រមុះរបស់ នាយវិញក៏យោលផ្ទប់ប៉ះកញ្ចឹងករបស់រចនាពីចំហៀងលាន់ខ្សឺត ។ រចនានឹកអៀន

CHANBOKEO.COM

ខ្មាស់រកពាក្យអ្វីថ្លែងមិនបានឡើយ ក៏ស្រវាទាញសក់មកគ្របកញ្ចឹងករបស់នាងរួច ស្ទុះស្ទារងើបគេចខ្លួនចូលបន្ទប់យ៉ាងលឿនបាត់ស្រមោល  ទុកឱ្យនាយយើងសំលឹង តាមពីក្រោយនាងទាំងភន្តំភាំង ។

ភ្លាមនោះ នាយឮសូរសំឡេងមួយបន្លឺឡើង :

- ខេមឫទ្ធិ ហេតុអ្វីក៏កូនមកដួលលើកំរាលយ៉ាងនេះ ? រចនា !! ទៅណាហើយ? ឆាប់មកជួយលើកបងឯងបន្តិច...

នាយយើងងាកផាំងឃើញតាងវ៉ាងរុញរទេះនាំម្តាយចូលមក ។

- អ្នកម្តាយ!! តាងវ៉ាង !! (ខេមឫទ្ធិលាន់មាត់ឡើង)

តាងវ៉ាងឃើញនាយភ្លាម ក៏ស្ទុះមកជួយលើក ថែមទាំងស្រដីថា :

- ឯងមិនទាន់គ្រាន់បើនៅឡើយទេ កុំប្រញាប់ដើរចេញមកក្រៅម្នាក់ឯងធ្វើអី ចង់ ចេញទៅណាមកណា ត្រូវហៅគេហៅឯងឱ្យជួយណាំ ។

ថាផង នាយដើរទៅអូសរទេះនាំខ្លួនអ្នកស្រីមណីចូលមកជិតផង ។ កាល បើឃើញខេមឫទ្ធិនៅតែម្នាក់ឯង អ្នកស្រីក៏សួរថា :

- រចនា គេទៅណាកូន??

- បាទ !! គឺ... គឺ... នាងនៅផ្ទះតើហ៍ម៉ាក់... (នាយឆ្លើយទាំងតតាក់តតុប)

ឮដូច្នោះអ្នកស្រីក៏កូកហៅ :

- រចនាកូន!!

រចនានៅក្នុងបន្ទប់ ក្តៅមុខភាយៗតែម្នាក់ឯង រារែកមិនហ៊ានចេញទៅសោះ ត្បិតនឹកខ្មាស់ខេមឫទ្ធិយ៉ាងណាមិនដឹង ។ តែដោយខ្លាចម្តាយបារម្ភ នាងក៏ឈ្ងោក មុខដើរចេញមក ។ លុះមកដល់បន្ទប់ទទួលភ្ញៀវ នាងលួចដាក់កន្ទុយភ្នែកទៅ ខេមឫទ្ធិ ឃើញនាយលួចសំលឹងមុខនាងដោយក្រសែភ្នែកមានទឹកដមភ្លឺថ្លា នាងរិត តែនឹកខ្មាស់ក្នុងចិត្តខ្លាំងឡើងទៀត  មិនដឹងថាមកពីហេតុអ្វី ។ អ្នកស្រីឃើញកូន ដើរចូលមកដល់ ក៏មានប្រសាសន៍ឡើង :

- ជួយមើលបងឱ្យបានជិតដល់ផងណាំកូន កុំឱ្យគេដួលដំ  ក្រែងលោងធ្ងឺរាំងរឡើង វិញ ។

- ចាំសម៉ាក់ !

រចនាឆ្លើយដោយឈ្ងោកមុខដដែល ។ អ្នកស្រីហាក់ដូចជាចាប់ភ្លឹកនឹងកិរិយា ចំលែករបស់កូន ក៏លួចសំលឹងមុខរបស់ខេមឫទ្ធិ។ លុះឃើញនាយមានកិរិយាទ្រង់ ខ្មាស់ៗអេះអុញដូចគ្នានឹងរចនាដែរ អ្នកស្រីក៏និយាយបន្លប់វិញថា :

- តែបើកូនរវល់ធ្វើកិច្ចការផ្ទះច្រើន ចាំម៉ាក់សុំឱ្យតាងវ៉ាងគេមកកំដរបងឯងឱ្យបាន ញឹកញាប់វិញចុះណាំកូន ។

ឮដូច្នោះតាងវ៉ាងបានចិត្ត ត្រេកអរភើត ទទួលពាក្យភ្លាម :

- បាទៗអ្នកមីង ពេលណាក៏បានដែរ ព្រោះឫទ្ធិជាមិត្តរបស់ខ្ញុំស្រាប់ទៅហើយ ។

ការពិត តាងវ៉ាងកំពុងតែចង់រកលេសមកលេងរចនាឱ្យបានញឹកញាប់ស្រាប់ ផង លុះអ្នកស្រីមណីសុំដូច្នោះ នាយក៏ស្ទ័រយ៉ាងរហ័សមិនឱ្យអ្នកអ្នកស្រីដូរចិត្តវិញ ទាន់ឡើយ ។ នៅថ្ងៃដដែលនោះ ក្រោយពេលដែលតាងវ៉ាងត្រលប់ទៅវិញបាត់ ខេមឫទ្ធិ ក៏លូនទៅជិតម្តាយ សុំការអនុញ្ញាតិពីលោក :

- អ្នកម្តាយ !! កូនគិតថា សុខភាពកូនបានគ្រាន់បើហើយ តើអ្នកម្តាយអនុញ្ញាត្តឱ្យ កូនវិលត្រលប់ទៅធ្វើការវិញបានទេហ៎?

CHANBOKEO.COM

អ្នកស្រីសំលឹងមុខនាយ ហើយក៏ងើបសំលឹងមុខរចនា អស់មួយស្របក់ក៏មាន ប្រសាសន៍ឡើងថា :

- តើកូនមានចិត្តចង់ត្រលប់ទៅសៀមរាប ដោយសារចង់ទៅធ្វើការវិញ ឬទៅជួប អ្នកណាម្នាក់ ឬក៏កំពុងគេចពីនរណាម្នាក់ ហ្ន៎សកូន??

ខេមឫទ្ធិ ភ្ញាក់ព្រើត ឆ្លើយរឹងថា :

- អត់ទេអ្នកម្តាយ ! កូនមិនបានចង់គេចពីនរណាទេ...

- បើអញ្ចឹង ចុះហេតុអ្វីថ្ងៃនេះ  មាក់ឃើញកូនមានឫកពារប្លែកម្ល៉េះ??

- បាទ? កូនប្លែករឿងអ្វីទៅម៉ាក់??

- គឺ ម៉ាក់ឃើញតែកូននិងរចនាលួចមើលមុខគ្នាញឹកញាប់តែមិនស្រដីរកគ្នាអ្វីមួយ ម៉ាត់សោះ ពេញមួយថ្ងៃហើយ តើកូនមានរឿងអ្វីនឹងគ្នាមែនទេហ៎?

សួរចំចំណុច... រចនានឹកអៀនក្នុងចិត្តថ្ពាល់ឡើងក្រហមទុំ ។ ខេមឫទ្ធិភ្ញាក់ ព្រើត ឆ្លើយទាំងតតាក់តតុបទៅកាន់ម្តាយវិញថា :

- បាទ!! អត់... មាន... រឿងអ្វីទេម៉ាក់ ។

- កូននិយាយការពិតទេ?

- ដោយមានព្រះជាសាក្សីជានិច្ចបាទ !!

- អឺ!! បើអញ្ចឹងម៉ាក់ធូរទ្រូងហើយ ។

អ្នកស្រីមណីលួចក្រលេកមើលទៅរចនាឃើញនាងនៅតែឈ្ងោកមុខធ្វើអៀន ប្រៀនកេះដៃ ដដែល ក៏ពោលបន្ត :

- ណ្ហើយ! បើកូនចង់ត្រលប់ទៅសៀមរាប ម្តាយក៏មិនថាអ្វីដែរ តែម្តាយចង់មាន ពិធីតូចមួយសំរាប់ជូនដំណើរកូនណា៎...

- ពិធីអ្វីទៅម៉ាក់?

- អញ្ចឹង ! កូនមកតាមម៉ាក់ម៉ោហ៎ !!

នៅក្នុងបន្ទប់ដែលមានបល្ល័ង្កដំកល់ព្រះពុទ្ធរូប និងបាយសីស្លាធមិពណ៌មាស យ៉ាងឆ្អិនឆ្អៅ អ្នកស្រីអង្គុយនៅលើព្រំចំពោះមុខព្រះពុទ្ធអង្គ ព្រមទាំងមានរូបថត របស់លោកវ៉ាដេតតាំងនៅទីនោះផង ។ អ្នកស្រីអុជធូបហើយបែបន់ថា :

- សូមព្រះជាម្ចាស់ជួយតាមថែរក្សា ខេមឫទ្ធិកូនប្រុសរបស់ម៉ាក់ផង ។

រួចហើយ លោកក៏បែរយកអំបោះសបីសរសៃមកចងដៃឱ្យនាយ ។  ខេមឫទ្ធិ សំលឹងមើលតាមឥតព្រិចសោះឡើង ។ រំពេចនោះ អ្នកស្រីក៏បន្តប្រសាសន៍ថា :

- ទៅហើយ  កុំភ្លេចផ្ទះរបស់យើងណា៎កូន    ព្រោះមានអ្នករង់ចាំឱ្យកូនវិលមកផ្ទះ ជានិច្ច ។

ពង្ងូច្នោះ ខេមឫទ្ធិឱនក្រាបសំពះទទួលអំបោះចំណងដៃពីម្តាយភ្លាម ថែមទាំងលួចចោលកន្ទុយភ្នែកសំលឹងមើលទៅរចនា ដែលនៅអង្គុយស្ងៀមស្ងាត់ ក្បែរនោះ ឃើញនាងមានអាការៈហាក់ព្រួយបារម្ភពីនាយក្រៃលែង ។ មាណព ក៏វាចាទៅកាន់អ្នកម្តាយវិញថា :

- កូនមិនទៅយូរទេ កូននឹងប្រញាប់ត្រលប់មកផ្ទះវិញកាលបើចប់កិច្ចការហើយ ។

លុះនាយដាក់ភ្នែកម្តងទៀត ស្រាប់តែឃើញរចនាលួចជូតទឹកភ្នែកហើយ ក្រោកចេញទៅបាត់យ៉ាងរហ័សពីបន្ទប់ ។ នាយពិភាល់ក្នុងចិត្តណាស់ ក៏ស្ទុះរឹង ចេញទៅតាមរហូតដល់រានហានខាងមុខផ្ទះ ទុកឱ្យម្តាយនៅអង្គុយសំលឹងពីក្រោយ រកតែនិយាយអ្វីក៏មិនទាន់ ។ អ្នកស្រីក៏បែរកាយក្រាបបង្គំព្រះសូត្រធម៌ស្ងៀមស្ងាត់ រំងាប់អារម្មណ៍ព្រួយក្នុងចិត្តទាំងឡាយចំពោះកូនទាំងពីរ ។

CHANBOKEO.COM

រចនាដាក់ខ្លួនចុះក្នុងអង្រឹងយោលមួយ ធ្វើមុខស្រងូតស្រងាត់ យោលទៅ យោលមកតែម្នាក់ឯង... ខេមឫទ្ធិដើរចូលមកស្ងាត់ៗ រួចឈរសំលឹងមុខនាងមួយ ស្របក់ ទើបបន្លឺវាចាទៅកាន់មាណវីថា :

- រចនា!! អូនអន់ចិត្តនឹងបងមែនទេហ៍? ឱ្យបងសូមទោសណាំចំពោះឧប្បត្តិហេតុ កាលពីព្រឹកមិញនេះផងណាំ... បងគ្មានចេតនាទេ !!

រចនាងាកផាំងឃើញបុរសយើងដើរចូលមកដល់ ក៏ដាក់មុខឈ្ងោកចុះវិញ មួយសន្ទុះទើបនាងឆ្លើយឡើងថា :

- អូនមិនបានខឹងអ្វីនឹងបងទេ...

- ឥចឹង.... ហេតុដូចម្ដេចបានជាអូនមិនស្រដីរកបងសោះ មួយថ្ងៃមកហើយ...?

ខេមឫទ្ធិនិយាយផង ដាក់ខ្លួនអង្គុយជិតនាងផង ។ រចនានៅតែឈ្ងោកមុខ ដដែល ។ មាណពឃើញនាងនៅស្ងៀមក៏សួរថែមទៀត :

- រចនា! អូននិយាយអ្វីនឹងបងខ្លះមើល៍.... បងចង់ឮសំដីអូននិយាយស្រស់ស្រាយ ជាមួយបងដូចរាល់ថ្ងៃណាំ... នៅស្ងៀមស្ងាត់យ៉ាងនេះ បងហាក់ដូចជាតុញថប់ក្នុង ចិត្តណាស់អូន ។

ភ្លាមនោះ រចនាដកដង្ហើមធំមួយបន្ទូរទ្រូង ហើយក៏ងើបមុខឡើងសួរថា :

- បងប្រាប់រចនាបានទេ ថាហេតុអ្វីក៏បងឆាប់វិលត្រលប់ទៅសៀមរាបម្ល៉េះ កាលបើបងមិនទាន់ជាសះស្បើយស្រួលបួលផង...?

ខេមឫទ្ធិយកដៃអង្អែលសក់នាងបន្ថើរៗ ដោយការថ្នាក់ថ្នមនិងសេចក្ដី ស្រលាញ់ ហើយតបវិញថា :

- បងស្រួលបួលវិញហើយណាំ! អូនកុំបារម្ភអី...

- ហ៊ឺ!... (រចនាថ្ងូរតិចៗ) តើនារីម្នាក់នោះជាអ្នកណាទៅ?.. បងស្គាល់នាងមិនបាន ប៉ុន្មានថ្ងៃផង ស្រាប់តែគេអាចទាក់ទាញចិត្តបង ឱ្យប្រាថ្នាចាកពីពីផ្ទះរបស់យើង យ៉ាងអន្ទះសា? ហេតុអ្វីបានជានាងមានសារៈសំខាន់ចំពោះរូបបងដល់ម្លឹង??

មាណពឮដូច្នោះភ្ញាក់ព្រើត ក៏ឆ្លើយរឹងថា :

- រចនា! អូនគិតខុសហើយ ។ រូបអូននិងម៉ាក់មានន័យធំធេងសំរាប់ជីវិតបងជានិច្ច បងមិនដែលនឹកចង់ឃ្លាតឃ្លាពីអូនទេ...

- កាលពីមុន... ប្រហែលមែនហើយ... តែឥលូវនេះ ចិត្តបងបានប្រែប្រួលហើយ... អូនពិតជាខ្លាច... ខ្លាចណាស់កាលបើថ្ងៃណាមួយបងត្រូវបែកពីអូនទៅ...

- រចនា! ម៉េចបានអូនពោលវាចាយ៉ាងនេះ? បងសន្យាណាំ ថាបងមិនឃ្លាតទៅ ណាចោលអូននឹងម៉ាក់ទេ ។ អ្នកទាំងពីរគឺជាជីវិតរបស់បង....

រំពេចនោះ នាយហាក់ដូចជាមានអារម្មណ៍ថា ខ្លួនកំពុងតែឮសៀងមនុស្ស ស្រីយំខ្សឹកខ្សួលល្ហើយៗ ថែមទាំងមានហៅឈ្មោះនាយផងថា :

- បង ខេមឫទ្ធិ.... ! បងនៅឯណា?? អូននៅរង់ចាំបង... រង់ចាំបង... រង់ចាំបង...

បុរសយើងឮហើយនឹកឆ្ងល់ក្នុងចិត្តណាស់ ក៏បែរមើលជុំវិញខ្លួនតែមិនឃើញអ្វី សោះ ក៏គិតថានោះប្រហែលជាគ្រាន់តែជាការមមើមមាយរបស់នាយដ៏ឥតបានការ តែប៉ុណ្ណោះ ។ បន្ទាប់មកមាណពក៏ងាកមកនិយាយជាមួយរចនាបន្តទៅទៀត :

- បងទៅសៀមរាបលើកនេះដើម្បីស្រាវជ្រាវរឿងមួយ ។ មិនយូរទេ ពីរបីថ្ងៃទៀត បងនឹងមកផ្ទះវិញហើយ....ឬក៏អូនចង់នាំម៉ាក់ទៅព្រមគ្នាជាមួយបងដែរ?

រចនាងើបមុខឡើងសំលឹងនេត្រារបស់ខេមឫទ្ធិ :

- កុំឱ្យរំខានបងអី... អូននៅផ្ទះថែម៉ាក់ចុះ ។ ឱ្យតែអូនបានដឹងថាបងប្រាកដជា ត្រលប់មកផ្ទះវិញដូចពាក្យសន្យា... ចិត្តអូនលែងមានកង្វល់ហើយ ។

CHANBOKEO.COM

- អូនពិតជានៅចាំបងមែនហ្អែស? ( ខេមឫទ្ធិសួរព្រមទាំងសំលឹងមុខនាងដោយ កែវភ្នែកភ្លឺថ្លាផ្លេក១ ទំនងហាក់ចង់ស្គាល់ពីជំរៅចិត្តរបស់នាងណាស់ )

រចនាងក់ក្បាល ហើយញញឹម ធ្វើឱ្យនាយយើងរំភើបចិត្តក្រៃលែង ។ បន្តិច ក្រោយមក ខេមឫទ្ធិក៏ពោលសួររចនាទាំងទឹកមុខរីករាយថា :

- អូនចង់ស្តាប់បទចំរៀងមួយទេ?

រចនាឮនាយសួរដូច្នេះក៏នឹងឆ្លល់ភ្លាមតែម្តង :

- អូហ៎ ឥលូវ បងចេះច្រៀងផង?

- ទើបតែរៀនច្រៀងមិនប៉ុន្មានថ្ងៃនេះឯង ។

- មែនហ្អែស? បើដូច្នេះ រចនាដូចជាចង់ឮបងច្រៀងដល់ហើយ ហើយបង លួចទៅរៀនច្រៀងតាំងពីអង្កាល់ហ្នឹង?

- បងនៅគេងក្នុងបន្ទប់យូរថ្ងៃមកហើយ អផ្សុកណាស់ ក៏នឹកភ្នកតែងបទចំរៀង មួយបទនេះឡើង... រួចហើយចង់ឱ្យអូនបានស្តាប់មុនគេផង ។

- អញ្ចឹងបងច្រៀងមក... អូននៅចាំស្តាប់បងណា៎!

- បទនេះនិពន្ធដោយបេះដូងរបស់បងពិត១ សំរាប់នារីមួយរូបដែលមានតម្លៃបំផុត ចំពោះជីវិតរបស់បង ។

ឮហើយ រចនាញញឹមយ៉ាងស្រស់បំព្រង រួចលើកដៃផាត់សក់ដ៏វែងអន្លាយទៅ ក្រោយ បង្ហាញផ្ទៃមុខដ៏សោភាមួយធ្វើឱ្យបុរសយើងគយគន់យ៉ាងភ្លន់ភ្លឹកស្មារតី :

- រចនា!! គេងកើយលើស្មាបងមក... ចាំបងបំពេរឱ្យអូនមានអារម្មណ៍ស្ងប់សុខ ហើយគេងលក់ស្កប់ស្កល់ក្បែមក្សាន្តក្នុងរាត្រីនេះណា៎អូន...

ធិតាសំលឹងមុខមាណពសាជាថ្មី ក៏ប្រទះនូវស្នាមញញឹមដ៏មានទឹកដមផ្អែម ល្ហែមមួយ ធ្វើឱ្យនាងរំភើបចិត្តរកថាមិនត្រូវ ។ នាងក៏រំកិលខ្លួនមកជិតនាយយើង ហើយផ្តេកកេសាដ៏ក្រអូបកើយលើស្មាខេមឫទ្ធិ ធ្មេចនេត្ររង់ចាំស្តាប់សំនៀងបំពេរ របស់នាយ ។ ព្រមជាមួយគ្នានោះ បុរសយើងក៏បន្លឺសំនៀង យ៉ាងក្រអួនក្រអៅ កាត់រាត្រីដ៏សែនស្ងាត់មានតែផ្កាយនិងដួងខែកំដរគេទាំងពីរកាយ :

## មួយរាត្រីដ៏មានន័យ

១. មួយរាត្រី ស្រីធ្មេចកើយលើស្មា ស្តាប់រៀមរ៉ា បន្លឺសៀងបេះដូង
មួយរាត្រី ដ៏អណ្តែតអណ្តូង រំភើបទ្រូង ហាក់យល់ឋានសួគ៌ា ។

២. មួយរាត្រី ដែលបងច្រៀងថ្នាក់ថ្នម បំពេរឆោម ប្រលោមក្រពុំផ្កា
មួយរាត្រី ហឫទ័យសែនសុខា ក្រោមចន្ទ័ថ្លា ពេញវង់ដ៏ពណ្ណរាយ ។

៣. មួយរាត្រី មេឃដីជាមេបា ត្របកផ្កា រោយធ្លាក់សស្គុសស្គាយ
ហាក់ពរជ័យ ពីព្រះព្រហ្មងនាយក្រោមព្រះពាយបបោសថ្នមកាយា ។

៤. មួយរាត្រី ដ៏ភិរម្យបរិសុទ្ធ ទោះសមុទ្ទមិនជ្រៅស្មើចិន្តា
វេហាស៍ខ្ពស់ មិនស្មើក្លិនស្នេហា ចិត្តរៀមរ៉ា ស្នេហ៍ស្រីវាស់មិនបាន ។

៥. មួយរាត្រី ភ្ជាប់និស្ស័យទ្វេហា ទោះមរណា ក៏ស៊ូប្តូរក្ស័យប្រាណ
ភក្តីភាព បរិសុទ្ធឥតឃ្លាតបាន លុះអវសាន សច្ចាស្មោះរៀងអើយ ។

CHANBOKEO.COM

00 00

00

CHANBOKEO.COM

# វគ្គទី៥

# ពិភពវង្វេង

ខេមឫទ្ធិមកដល់សៀមរាបដោយសុវត្ថិភាព ហើយត្រលប់ចូលទៅស្នាក់នៅ ផ្ទះជួលជាមួយសហការីរបស់នាយដដែល តែនាយមិនទាន់ចង់ចូលធ្វើការវិញទេ ក្នុងចិត្តគិតប្រាថ្នាថា នឹងវិលទៅកន្លែងចាស់ដែលនាយជួបនឹងឧប្បត្តិហេតុដ៏ចំលែក ថ្ងៃមុន ដើម្បីបណ្តោះចិត្តងឿងឆ្ងល់ទាំងឡាយមិនដាច់ស្រេចនៅក្នុងអារម្មណ៍សិន ។

នៅចំពោះមុខក្លោងទ្វារដែលមានរូបអប្សរា ជួនគ្រាន់ជារូបចំលាក់ ជួនជារូប ដែលមានព្រលឹង... ខេមឫទ្ធិឈរសំលឹងយ៉ាងពិនិត្យពិច័យ តែអស្ចារ្យណាស់ ថ្ងៃ នេះ នាយហាក់ដូចជាមិនឃើញមានអ្វីប្លែកសោះ ឃើញតែចំលាក់នៅស្ងៀមនឹងលើ ជញ្ជាំងប្រាសាទដូចប្រក្រតី ។ លុះនាយដើរឆ្លងក្លោងទ្វារទៅក្នុងទីលានវាលឧទ្យាន ជុំវិញប្រាសាទ ក៏មិនឃើញអ្វីចំលែក ក្រៅពីហ្វូងទេសចរណ៍ មានខ្មែរ មានបរទេស ដើរចុះដើរឡើង ស្រូស្រ យ៉ាងណែនណាន់ខ្នាន់ខ្នាប់ ។ មាណពដើរចុះដើរឡើងទាំង អន្ទះសា រហូតដល់អស់កំលាំង នៅតែមិនបានប្រទះអ្វីដែលនាយចង់ឃើញ ចង់ យល់នោះឡើយ ។ ថ្ងៃលិចទៅហើយ... ភ្ញៀវទេសចរណ៍ក៏នាំគ្នាឡើងរថយន្ត ត្រលប់ចូលក្រុងវិញម្តងមួយៗ ។ ខេមឫទ្ធិឡើងទៅឈរនៅចំកណ្តាលផ្លូវមាត់ ជណ្តើរនាទិសខាងលិចនៃប្រាសាទមហានគរ ភ្នែកសំលឹងទៅកំពូលប្រាសាទ ដែល មានពណ៌មាសឆ្អិនឆ្អៅ ហើយពោលបែបទន់ឡើងថា :

- សូមបារមីនៃវត្ថុសក្តិសិទ្ធិទាំងឡាយជួយនាំរូបខ្ញុំឱ្យបានជួបរាជទេវីម្តងទៀតផង!

តែ.... នាយនៅឈរស្ងៀមស្ងាត់អស់ជាយូរម៉ោងហើយ នៅតែមិនឃើញមាន អ្វីចំលែកកើតឡើងដដែល ។ រំពេចនោះ នាយបានឮសូរសំលេងបុរសម្នាក់និយាយ មកកាន់នាយថា :

- ប្អូន! ដល់ម៉ោងហើយណា៎!! ទីនេះគេបិទចរាចរលែងឱ្យមានចេញចូលរហូត ដល់ព្រឹកស្អែកទើបអាចចូលកំសាន្តបានទៀត ។ ប្អូនឆាប់ត្រលប់ចេញមក....!!

ខេមឫទ្ធិភ្ញាក់ព្រើត ងាកក្រោយ ឃើញបុរសម្នាក់ក្នុងឯកសណ្ឋានជាក្រុម តម្រួតកំពុងឈរកាន់ពិលបក់ដៃហៅឱ្យនាយប្រញាប់ចាកចេញពីទីលាន ប្រាសាទ មហានគរដ៏ល្អវិចិត្រនោះ ។ ខេមឫទ្ធិក៏តបយ៉ាងរហ័ស :

- អូហ៍ សូមទោសបាទ!! អាល័យតែភ្លឹក ភ្លេចមើលម៉ោង ។

ខេមឫទ្ធិស្រដីយ៉ាងទន់ភ្លន់ចំពោះនាយតម្រួត ហើយក៏ហាក់ចូលរថយន្តបរ ចេញទៅ ។

0000000000000000000000

រាត្រីនោះ នាយយើងហាក់ដូចជារសាប់រសល់ក្នុងចិត្តចំលែកណាស់ ដូច ជានឹកផ្ទះបន្តិច នឹកមហានគរបន្តិច.. ចង់ត្រលប់ទៅផ្ទះបន្តិច ចង់នៅបន្តិច...។ នៅ ក្នុងបន្ទប់គេង មាណពដើរចុះដើរឡើង គិតខ្វល់ខ្វាយថាតើនាយត្រូវធ្វើយ៉ាងណា

CHANBOKEO.COM

ដើម្បីទៅតាមរករាជធិតាសុរភីមល្លិកាឱ្យឃើញ ។ នាយក៏ដាក់ខ្លួនអង្គុយចុះលើគ្រែ ហើយលើកដៃជ្រោងសក់ ស្រាប់តែចាប់ភ្លឹកឃើញសរសៃអំបោះដែលម្ដាយបានចង ដៃឱ្យកាលពីម្សិល ក៏គិតថា :

- ឬក៏ប្រហែលពីវេទមន្តពរជ័យសក្តិសិទ្ធិរបស់អ្នកម្ដាយទេដឹង ទើបយើងមិនអាច វិលទៅជួបព្រះនាងបាន?

ភ្លឺស្រាងឡើង ខេមឫទ្ធិងើបឡើងយកកន្ត្រៃកាត់អំបោះសចំណងដៃពរពីម្ដាយ ហើយទំលាក់អំបោះទៅលើខ្នើយរបស់នាយ រួចធ្វើដំណើរយ៉ាងលឿនសំដៅទីដៅ ។ ពេលនោះ ថ្ងៃមិនទាន់រះភ្លឺច្បាស់នៅឡើយទេ ។ មាណពរបស់យើង ក៏បានមកដល់ ដែនចាស់ដដែល តែមិនឃើញអ្វីទាំងអស់ក្រៅពីក្មេងបីបួនរូបកំពុងរែកដូងយកទៅ លក់ ។ លុះក្មេងដើរផុតទៅ នាយក៏ដើរក្រលឹងមួយសាទៀត តែពេលនោះ នាយ យើងហាក់ដូចជាមានអារម្មណ៍ថាមានអព្ភ័ធ្លាក់ចុះជាខ្លាំង ហើយស្រាប់តែឃើញ ស្ត្រីចំណាស់ពីរនាក់ស្លៀកក្បិនចងពុង រត់ម្នីម្នាសំដៅទៅណាមិនដឹង ថែមទាំង ស្រែកឆោឡោប្រាប់គ្នីគ្នាថា :

- នាងអើយ ជិតដល់ផ្ទះគ្រូហ្មហើយនៅ?

- ចាំស! ជិតដល់ហើយ បងម៉ៅឯងខំរត់បន្តិចមើល៏ !!

ខេមឫទ្ធិនឹកឆ្ងល់ណាស់ក៏ស្រែកសួរ :

- មីងៗ នាំគ្នារត់ប្រញិបប្រញាប់ទៅណាហ្នឹង?

ស្ត្រីចំណាស់ងាកបែរក្រោយ ឃើញនាយហើយក៏ទុចង៉ក់ :

- ឯងមិនដឹងទេហ៎ ? អ្នកម្នាងកំពុងប្រឈួនខ្លាំងណាស់ ត្រូវការពេទ្យហ្មតលូវនេះ ឯងមានស្គាល់ផ្លូវទៅផ្ទះគ្រូហ្មលំផាផុនទេហ៎?

- ពុទ្ធោអើយ មីង! ខ្ញុំមិនស្គាល់ទេ !!

ខេមឫទ្ធិឆ្លើយផងសើចផង ត្បិតមិនដឹងពិតមែន ។ ភ្លាមនោះស្រាប់តែស្ត្រី ឈ្មោះម៉ៅស្រែកមករកនាយថា :

- អឺ អឺ!! បើមិនដឹងទេ ត្រលប់ថយក្រោយទៅរាជដំណាក់ ជួយទៅមើលអ្នក ម្នាងផង ក្រែងលោចាស់ៗមានការអ្វីត្រូវប្រើឱ្យឯងជួយណាំ ។

- ហើយចុះដំណាក់អ្នកម្នាងនៅខាងណាវិញទៅមីង? ( មាណពសួរ)

- យី!! ចុះអន្ទិតឯងមកពីខាងណាទើបមិនស្គាល់ដំណាក់អ្នកម្នាង? ( មីងម៉ៅសួរ)

នុ៎ះ! នៅចុងព្រៃលីមៗឯណោះ ។

ខេមឫទ្ធិក្រលេកមើលទៅតាមដៃដែលស្ត្រីចំណាស់ចង្អុល ស្រាប់តែប្រទះ ឃើញកំពូលដំណាក់ដ៏វិចិត្រមួយលេចធ្លោឡើងផុតចុងព្រឹក្សា ។ នាយឈរមើល ភាំង! មែនហើយ នោះពិតជារាជដំណាក់មួយមែន ។ គ្រានោះ ស្ត្រីចំណាស់ទាំងពីរ រូបក៏ម្នីម្នារួសរាន់បន្តដំណើរទៅមុខទៀតបាត់ស្រមោល ។ មាណពយើងក៏បោះ ជំហានដើរចូលទៅក្នុងទីធ្លាឧទ្យានដ៏ស្អាតមួយ ស្រាប់តែមានបុរសស្ត្រីក្នុងសំលៀក ជាភិលៀង ជាសេនាបាវបំរើ មកចោមរោមមើលនាយយ៉ាងអ៊ូអរ ។ ភ្លាមនោះ ស្រាប់តែមានព្រឹទ្ធជនមួយរូបក្នុងសំលៀកចាស់ទុំបុរាណបានមកដល់ ឧទានថា :

- ព្រះអើយ! នេះគឺលោកមេទ័ពមហាសេនាខេមឫទ្ធិតើហ៏ !! ចុះហេតុដូចម្ដេចបាន ជាលោករក្សាយុវភាពបានល្អម្ល៉េះ? នៅក្មេងហើយសង្ហារដដែលឥតផ្លាស់ប្ដូរសោះ ។ មើលតាងរ៉ាងខ្ញុំវិញចុះ ជរាដើរលែងចង់រួចទៅហើយ ។

ខេមឫទ្ធិឮគាត់មានប្រសាសន៏ដូច្នោះក៏ភ្ញាក់ក្រញ៉ាង លាន់មាត់ឡើងថា :

- លោកតាជានាយតាងរ៉ាង? ស្លាប់ខ្ញុំហើយ! ហេតុអ្វីក៏ចាស់ជរាយ៉ាងនេះ?

ខេមឫទ្ធិសំលឹងតាងរ៉ាងយ៉ាងពិនិត្យពិច័យ ហើយនឹកឆ្ងល់ក្នុងចិត្តក្រៃលែង ថា ហេតុអ្វីបានជាតាងរ៉ាងក្លាយជាចាស់ទ្រុឌទ្រោមយ៉ាងនេះ ។ នាយក៏នឹកភ្ញាក់ចង់សួរ ដំណឹងអំពីរាជធិតាសុរភីមល្លិកាផងដែរតែនឹកដូចជាខ្មាស់មាត់មិនហ៊ានស្ដី ស្រាប់តែ មានសំលេងមនុស្សចាស់ស្រែកហៅ :

CHANBOKEO.COM

- លោកតា តាងរ៉ាង! អ្នកម្នាងមិនស្រួលខ្លាំងហើយ! ឆាប់ទៅមើលភ្លាមឡើង ។

លោកតាឮហើយក៏ងាកមករក ខេមឫទ្ធិរួចចាប់អូសដៃនាយឡើងទៅរាជ ដំណាក់តាមជាមួយដែរ ៖

- លោកមេទ័ពមកតាមខ្ញុំមក ! ខ្ញុំគិតថាវត្តមានរបស់លោកអាចនាំឱ្យអ្នកម្នាងបាន ធូរស្រាលពីជំងឺផងក៏មិនដឹង ។

លុះអ្នកទាំងពីរមកដល់បន្ទប់មួយដ៏ស្អាត ខេមឫទ្ធិបានយល់ស្ត្រីជរាមួយរូប កំពុងមានអាការៈធ្ងន់ធ្ងរ សំរាន្តសណ្តូកជើងលើទេនសយនាមួយយ៉ាងប្រណិត ។ តាងរ៉ាងក៏ចូលទៅក្បែរតហើយវន្ទាគោរព ៖

- អ្នកម្នាងខេមរី ! មើលហ្នែក ! មានមនុស្សដែលអ្នកម្នាងរង់ចាំដំណឹងជាយូរឆ្នាំ កន្លងមកនេះ បានមកដល់ជួបអ្នកម្នាងវិញហើយ ។

ឮឈ្មោះខេមរីភ្លាម មាណពយើងភ្ញាក់កន្ត្រាក់ដូចគេដាស់ពញ្ញាក់ត្បិតអីនៅ ក្នុងចិត្តរបស់នាយ គឺកំពុងតែទន្ទឹងរង់ចាំរកកុមារីខេមរីដ៏តូចច្រលឹង តែហេតុអ្វី ខេមរីដែលគេកំពុងប្រទះចំពោះមុខឥឡូវនោះ បែរក្លាយជាអ្នកម្នាងដ៏ចាស់ជរាទៅវិញ ។ កាលបើតាងរ៉ាងស្រដីប្រាប់ដូច្នោះ អ្នកម្នាងក៏ប្រែខ្លួនបែរមើលមកមាណព ស្រាប់តែបើកភ្នែកធំៗ សំដែង ការភ្ញាក់ផ្អើលជាខ្លាំងថែមទាំងឧទានថា ៖

- បង ខេមឫទ្ធិ? គឺបងមែនទេ?

ម្តងនេះ ខេមឫទ្ធិរឹតតែភ្ញាក់ស្រលាំងកាំងថែមទៀតដែលមានដូនចាស់សក់ស្កូវ សស្កុស មានបុណ្យឋានៈជាអ្នកម្នាងមកហៅនាយថា "បង" ដូចជាចំលែកត្រចៀក យ៉ាងណាមិនដឹង ។ ភ្លាមនោះ អ្នកម្នាងក៏ពោលវាចាបន្តទៀតថា ៖

- ហេតុអ្វីក៏បងនៅតែក្មេងដដែលយ៉ាងនេះ? បងចាំខ្ញុំបានទេ? នេះគឺខេមរីប្អូនស្រី របស់បងណា៎ ...

- នាងតូចខេមរី? (ខេមឫទ្ធិលាន់មាត់ខ្សិបៗ)

- បងពិតជាមានជីវិតនៅឡើយថែមទាំងនៅរឹងពេញកំលាំងដដែល... ទេវតាពិត ជាតាមថែរក្សាមនុស្សល្អដូចបងមែន ។ ប្អូនសែនរីករាយអ្វីម្លេះ កាលបើបានឃើញ បងបានសុខសប្បាយ ។

អ្នកម្នាងខេមរីសំដែងទឹកមុខរីករាយ បាត់ការឈឺចាប់អស់រលីង ហើយក៏ប្រឹង តោងស្មាភិលៀងមួយរូបក្រោកអង្គុយឡើងទាំងត្រដរ ។ ខេមឫទ្ធិសំលឹងមុខអ្នក ម្នាងទាំងងឿងឆ្ងល់ស្រលាំងកាំង សឹងដូចជាមិនជឿភ្នែកខ្លួនឯង ថាអ្វីៗដែលនាយ បានប្រទះថ្ងៃនេះជាការពិតសោះឡើយ ហើយក៏មិនយល់សោះដែរថា ម៉េចក៏អ្វីៗ ផ្លាស់ប្តូរខុសកាលខុសវេលាឡើងវង្វេងអស់យ៉ាងនេះ ។ បន្តិចក្រោយមក នាយក៏ បន្លឺវាចាសួរទៅអ្នកម្នាងវិញថា ៖

- តាំងពីយើងបែកគ្នាប៉ុន្មានថ្ងៃមកនេះ តើមានហេតុការណ៍អ្វីខ្លះកើតឡើង បានជា ម្នាក់ៗក្លាយជាចាស់ជរាអស់បែបនេះ អ្នកម្នាងខេមរី?

អ្នកម្នាងជ្រួញចិញ្ចើមសំលឹងមុខមាណពហើយក៏ឆ្លើយវិញថា ៖

- យើងមិនមែនបែកគ្នាត្រឹមប៉ុន្មានថ្ងៃទេ គឺយើងបែកគ្នាជាងហុកសិបឆ្នាំហើយណា៎ បងប្រុស...

- ថាម៉េច? បែកគ្នាជាងហុកសិបឆ្នាំ??

ខេមឫទ្ធិបើកភ្នែកធំៗ ហើយឧទានដោយមិនអស់ចិត្តសោះថា ៖

- ទើបតែជាងពីរអាទិត្យសោះ ម៉េចក្លាយជាជាងហុកសិបឆ្នាំកើត?

អ្នកម្នាងឮដូច្នោះ ក៏សំលឹងមុខតាងរ៉ាង ហើយបែរមកនាយវិញ សំដែងការ ងឿងឆ្ងល់ដូចគ្នា ៖

- គឺយើងបែកគ្នាជាងហុកសិបឆ្នាំមែនណា៎ មើលចុះ! សូម្បីតែនាយសេនាតាងរ៉ាងក៏ ចាស់មើលមិនយល់ដូចតែរូបប្អូនដែរ បងមិនឃើញទេហ៏?

ខេមឫទ្ធិដាក់ខ្លួនអង្គុយចុះលើកៅអី គិតងឿងឆ្ងល់មិនអស់មិនហើយ ។ បន្តិច ក្រោយមកក៏ដាច់ចិត្តសួរបន្ថែមទៀតថា ៖

- ល្ហើយចុះ ! តើអ្នកម្នាងខេមរីពន្យល់មកខ្ញុំបានទេ នូវអ្វីៗទាំងឡាយរាប់សិប ឆ្នាំកន្លងមកនេះ?

CHANBOKEO.COM

អ្នកម្នាងទំលាក់ទឹកមុខស្រងូតពេលដែលឮនាយសួរដូច្នោះ រួចក្អកខេះៗ ទើប និយាយខ្សាវៗបន្តថា :

- ប្រហែលជាបងចង់ដឹងពីសុខទុក្ខរបស់រាជធិតាសុរភីមល្លិកាដែរហើយ មែនទេ?

ខេមឫទ្ធិងក់ក្បាល :

- មែន! ខ្ញុំបារម្ភពីព្រះនាងណាស់ តើព្រះនាងមានសុខទុក្ខយ៉ាងណាដែរ?

ស្រាប់តែ អ្នកម្នាងខេមរីរលីងរលោងទឹកភ្នែកយំទ្រហោរយំឡើងជាខ្លាំង ។ ទាំងព្រឹទ្ធជនតាងវ៉ាង ទាំងភិលៀង ទាំងឆ្មាំទ្វារ ទាំងសេនាទាំងឡាយ នាំគ្នាឈ្ងោក មុខឈរស្ងៀមស្ងាត់ទំនងដូចជាកំពុងកាន់មរណទុក្ខដូច្នោះឯង។ ខេមឫទ្ធិហាក់ដូច ជា រន្ធត់ក្នុងចិត្តណាស់ ក៏សួររន្ថើនឡើងថា :

- តើរាជធិតាគង់នៅទីណា? ខ្ញុំសូមចូលគាល់ព្រះនាងបានទេហ៎?

អ្នកម្នាងនឹងព្រឹទ្ធជនតាងវ៉ាងសំលឹងមុខគ្នា។ បន្តិចមកអ្នកម្នាងក៏ចេញបញ្ជា :

- លោកនាយសេនាតាងវ៉ាង ! សូមលោកនាំខ្ញុំនិងបងខេមឫទ្ធិទៅប្រាង្គត្រ័យ លក្ខណ៍បន្តិចបានទេហ៎ !!....

0000000000000000000000000

នៅចំពោះមុខប្រាង្គដ៏ល្អស្កឹមស្កៃមួយ ដែលមានម្លប់ព្រឹក្សាត្រឈឹងត្រឈៃពទ្ធ័ ជុំវិញយ៉ាងងងឹតឈឹង...

អ្នកម្នាងគង់នៅលើគ្រែទនមួយ ក្នុងអាការៈមានប្រឈួននៅឡើយ ។ ព្រឹទ្ធ ជនតាងវ៉ាងក៏នាំសេនាភិលៀងបួនប្រាំរូបចូលអុជធូបថ្វាយបង្គំចំពោះមុខប្រាង្គ រួច ក៏មានប្រសាសន៍ ឡើងថា :

- នេះជាទីសក្ការៈ ដែលពលរដ្ឋនៅមហានគរតែងតែមកអុជធូបគោរពបូជាដួង វិញ្ញាណសក្តិសិទ្ធិជានិច្ចជាកាលអស់ជាងហុកសិបឆ្នាំមកហើយ ។

ខេមឫទ្ធិមិនដឹងថាទីនោះជាអ្វីទេ តែដើម្បីសំដែងនូវក្តីគោរពចំពោះម្ចាស់ទឹក ម្ចាស់ដី នាយក៏ចុះពីលើខ្នងសេះចូលទៅអុជធូបនឹងគេដែរ ។ កំពុងតែប្រណម្យ ក្រាបសំពះ ស្រាប់តែនាយបានឮសំលេងស្រែកហៅឈ្មោះនាយយ៉ាងគ្រលួច :

- បង ខេមឫទ្ធិ ! អូននៅរង់ចាំបងជានិច្ច !

មាណពភ្ញាក់ព្រើត ងាករកម្ចាស់សំលេងតែមិនឃើញអ្វីសោះ ក៏លាន់មាត់ :

- រាជធិតា ! អូននៅឯណា? បងវិលមករកអូនតាមសន្យាហើយ!! រាជធិតា...

តែ... ស្ងាត់ជ្រៀប ខេមឫទ្ធិមិនឮមានចំលើយអ្វីតបវិញទេ ។ អ្នកម្នាងក៏ ពោលឡើងថា :

- បង ខេមឫទ្ធិ ! កុំបាច់ស្រែកហៅអី... ចាំប្អូននិទានរឿងមួយឱ្យបងស្តាប់ នោះ បងនឹងយល់ថាហេតុអ្វី បងឮសំលេងហៅឈ្មោះបងគ្រលួចយ៉ាងនេះ..

មាណពអន្ទះសាណាស់ក៏តឿនអ្នកម្នាង :

- សូមនិយាយពន្យល់ឱ្យខ្ញុំបានដឹងផង... ឥឡូវនេះខ្ញុំកំពុងស្ថិតក្នុងភាពងងឹតឈឹង មួយដែលរកកោះរកត្រើយមិនឃើញឡើយ ។

អ្នកម្នាងសំលឹងមុខ ខេមឫទ្ធិហើយក៏មានវាចាបន្តថា :

- ការពិតរឿងហេតុដូចយ៉ាងនេះ ណា៎បងប្រុស !!

CHANBOKEO.COM

អ្នកម្នាងក៏ចាប់រៀបរាប់ដំណើររឿងយ៉ាងពិស្តារអោយមាណពយើងស្តាប់ ដើម្បីអោយបានជ្រះចំងល់ទាំងឡាយ....

0000000000000000000000

ពេលដែលព្រះរាជធិតាត្រលប់វិលចូលរាជវាំង ក៏ប្រទះបច្ចាមិត្រដែលបង្កប់ ខ្លួន កំពុងចាប់យកព្រះចៅបិតារបស់ព្រះនាង បំផាយសេះចេញទៅ ។ ព្រះរាជ ធិតាក៏ស្រវាចាប់ដាវ នាំទ័ពចូលទៅរំដោះព្រះអង្គយ៉ាងក្លាហាន ។ ថៃដន្យ សត្រូវ មានគ្នាច្រើនពេក ព្រះនាងក៏ត្រូវរបួសហើយមិនអាចរំដោះព្រះវរបិតាបាន ។ ក្រោយមក ខេមរិន្ទដែលជាប្អូនកណ្តាលរបស់ខេមឫទ្ធិ បាននាំទ័ពពីជាយដែនខាងជើង ត្រលប់មកដល់ប៉ុរីទាន់ពេល ទើបអាចរំដោះព្រះនាងរួចពីគ្រោះថ្នាក់ ។ ព្រម
ជាមួយគ្នានោះដែរ ព្រះរាជបុត្រ សុភានវង្សដែលត្រូវជាត្រូវជាបងប្អូនជីទួតមួយ ជាមួយនឹងរាជធិតាសុរភីមល្លិកា
ក៏បាននាំទ័ពមួយផ្នែកទៀតទៅតតាំងនឹងខ្មាំង បច្ចាមិត្ត ហើយក៏បានរំដោះនាងតូចខេមរី បានសុខសប្បាយដែរ ។ តែនៅគ្រានេះ
នរណា១ក៏សន្ទូតគ្រប់គ្នាថា មេទ័ពមហាសេនាខេមឫទ្ធិបានស្លាប់បាត់បង់ជីវិតនៅ លើសមរភូមិទៅហើយ
ត្បិតគេបានឃើញលោកត្រូវព្រួញពិសធ្លាក់ពីលើខ្នងសេះ ពិតមែន ។

ថ្ងៃមួយ...

ព្រះរាជធិតាសុរភីមល្លិកាកំពុងជជែកពិភាក្សាជាមួយនឹងរាជបុត្រសុភានវង្ស ព្រមជាមួយនឹងមេទ័ពវ័យក្មេងខេមរិន្ទ ដើម្បីគ្រោងទ័ពចេញទៅរំដោះព្រះចៅរាជ បិតា ស្រាប់តែបច្ចាមិត្របានមកឡោមពទ្ធ័រាជប៉ុរីសាជាថ្មី ។ ក្រោយពីចាញ់ដៃ ខ្មាំង មួយលើកជាពីរលើក ព្រះនាងសំរេចចិត្តថា នឹងទៅប្រឈមមុខសត្រូវសាជាថ្មី ដោយស្នាដៃព្រះនាងផ្ទាល់ ។
ស្រាប់តែមានរាជាសារពីព្រះចៅម៉ឺនខែងនៃនគរ ជាសត្រូវជិតខាង មកគំរាមអោយព្រះនាងដាក់ទ័ព ហើយស្មគ្រ័រៀបអភិសេកជា
មហេសីទី៧របស់ទ្រង់ ព្រមទាំងលើកមហានគរទាំងមូលជាចំណុះផង នោះព្រះអង្គ
នឹងដោះលែងព្រះចៅបិតាអោយត្រលប់មកនគរវិញដោយសុខសប្បាយ ។ រាជ ធិតាទ្រង់ពិរោធជាខ្លាំងចំពោះភាពប្រមាថរបស់សត្រូវ ។ នៅគ្រានោះទៀត បុគ្គលជាទីស្រលាញ់ក្នុងជីវិតរបស់ព្រះនាងរួមទាំងព្រះមាតាបិតា និងខេមឫទ្ធិ កំពូលដួងចិត្តបានឃ្លាតចាកពីរាជធិតាអស់រលីង ធ្វើអោយព្រះនាងរិតតែឈឺចាប់ ប្រាថ្នាចេញសងសឹកសត្រូវទាំងអស់ដែលបានមកបំផ្លាញ សេចក្តីសុខរបស់ព្រះនាង
និងភាពក្សេមក្សាន្តនៃមហាប៉ុរីទាំងមូល ។ ដោយប្រការនោះហើយទើបព្រះនាង សច្ចាថា នឹងធ្វើពិធីបូជាយញ្ញថ្វាយជីវិតទៅព្រះព្រហ្មជាម្ចាស់ ដើម្បីឱ្យដួងវិញ្ញាណ របស់រាជធិតាបានទទួលនូវមហិទ្ធិឫទ្ធិខ្លាំងក្លា អាចបង្ក្រាបសត្រូវទាំងឡាយឱ្យ បាក់បបខ្លបខ្លាចបាន ។ បន្ទាប់មក រាជធិតាក៏បញ្ជាឱ្យសេនាចាត់ពិធីបូជាយញ្ញមួយ នៅចំកណ្តាលទីលានឧទ្យានប៉ុរីមហានគរ ហើយបានកោះហៅរាជវង្សានុវង្ស មេទ័ព និង នាម៉ឺនមហាមន្ត្រីទាំងឡាយ មកផ្តាំថា :

- ក្រោយពេលដែលខ្ញុំម្ចាស់សោយទីវង្គតទៅ សូមអ្នកទាំងអស់កុំភ្លេចឆ្លាក់រូបយើង នៅគ្រប់ក្លោងទ្វារទាំងបួនទិសនៃមហានគរផង ។
គោលបំណងរបស់យើងមានតែ ពីរយ៉ាងគត់ ទីមួយគឺរង់ចាំការវិលត្រលប់របស់បងខេមឫទ្ធិពីសមរភូមិ ហើយទីពីរ
គឺរង់ចាំគំរាមសំលុតស្មារតីសត្រូវដែលចូលមកយាយីមហានគររបស់យើង ។

បន្ទាប់មក ព្រះនាងសុរភីមល្លិកា ក៏បូជាព្រះកាយទៅក្នុងភ្លើងអគ្គីទាំងរស់ នោះទៅ ដោយសច្ចាជាចុងក្រោយថា :

- បរពិត្រព្រះជាម្ចាស់ ! ខ្ញុំព្រះអង្គសច្ចា ថាមិនរត់ចាកចេញចោលទឹកដី មហានគរ ឱ្យធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មាំងជាដាច់ខាត!!!
សូមប្រជាពលរដ្ឋទាំង ឡាយតស៊ូលុះដង្ហើមចុងក្រោយ ដើម្បីការពារដែនដីជាទីស្រលាញ់របស់យើង ។

CHANBOKEO.COM

ទោះបីជារូបកាយរបស់ខ្ញុំម្ចាស់ក្ស័យលាចាកលោកនេះទៅមែន តែសូមឱ្យវិញ្ញាណ ដួងព្រលឹងរបស់ខ្ញុំម្ចាស់បាននៅថែរក្សាសម្បត្តិមហានគរជានិច្ច មិនឱ្យខ្មាំងសត្រូវ ចូលមកឈ្លានពានរំលោភបានឡើយ!!!"

លុះព្រះនាងឈានបោះជំហាន ចូលទៅក្នុងអណ្តាតភ្លើងដ៏សន្ធោសន្ធៅនោះ រាជធិតាបានងើយព្រះភក្រ្តសំលឹងមើលទៅផ្ទៃមេឃ ហើយមានសវនីយ៍បន្ថែម ទៀតថា :

- បងខេមឫទ្ធិ!! អូននៅតែស្រលាញ់ ហើយរង់ចាំជួបបងជានិច្ច មិនថាជាតិនេះ ឬជាតិណាទេ!!

ព្រះនាងមានសវនីយ៍ទាំងនេត្រារលីងរលោង រួចក៏ពន្លិចព្រះកាយទៅក្នុង អណ្តាតភ្លើងសោយទីវង្គតនៅគ្រានោះតែម្តង ។ រីឯសង្គ្រាមក្នុងរាជបុរីបានរាល ដាលពាសពេញនគរអស់ជាច្រើនឆ្នាំ ទំរាំសត្រូវបាក់ទ័ពរត់ខ្ចាត់ខ្ចាយពីដែនដី មហា រាជរលីង ។ ក្រោយមក មហានគរក៏បានជួបសុខសាន្តត្រាណឡើងវិញ ។ ខេមរីក៏បានរៀបអភិសេកជាមួយរាជបុត្រសុភានវង្សនោះ រួចមករស់នៅឯដំណាក់ចាស់របស់នាងវិញ ។ ចំណែក ខេមរិទ្ធជាបងប្រុស ក៏បានទទួលងារ ជាមេទ័ពមហាសេនាបន្តពីបងប្រុសខេមឫទ្ធិរបស់ខ្លួនផងដែរ ។

គួរសង្វេគអនិច្ចាណាស់!! ទោះបីមហានគរបានទទួលសន្តិភាពវិញ ក៏ពិតមែន តែដួងព្រលឹងវិញ្ញាណរបស់រាជធិតាមិនបានស្ងប់ម្តងណាឡើយ.... គឺនៅវិលវល់នៅ ជាមួយនឹងមហានគរជានិច្ច ។ ម្ល៉ោះហើយ ពលរដ្ឋនៃរាជបុរីទាំងឡាយនាំគ្នាសន្មត យកប្រាង្គត្រ័យលក្ខណ៍ធ្វើជាទីសក្ការៈសំរាប់បូជារំលឹកថ្វាយដួងវិញ្ញាណរបស់រាជ ធិតាសុរភីមល្លិកា តរៀងមក.......

ជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជជ

ពោលមកដល់ត្រង់នេះ អ្នកម្តាងខេមរីរលីងរលោងនេត្រាអួលដើមកនិយាយ លែងរួច ក៏ទាញកូនកន្សែងមកខ្ទប់មុខហើយនៅស្ងៀមមួយស្របក់ ។ ប៉ុន្តែ ខេមឫទ្ធិបែរជាអន្ទះសាដូចមេមាន់រកពងទៅវិញ ហើយក៏មានអារម្មណ៍ដូចត្រូវគេ យកដាវមកកាត់បេះដូងរបស់នាយបាត់ពីទ្រូងអញ្ចឹង ។ មាណពងើបឡើងស្រែក ឧទានយ៉ាងភ្លាត់សំលេងថា :

- អត់ទេ ! ខ្ញុំមិនជឿទេ... ! ខ្ញុំទើបតែបែកពីព្រះនាងចំនួនជាងពីរអាទិត្យសោះ.. ហេតុអី...? ហេតុអី... បានជាព្រះនាងនៅសល់តែដួងព្រលឹងសំរាប់ជួបរូបខ្ញុំទៅ វិញ... អត់ទេ... ខ្ញុំមិនជឿទេ... មិនជឿទេ.... មល្លិកា! មល្លិកា!! អូននៅឯណា?? មល្លិកា...!!!

ខេមឫទ្ធិរត់ឆ្វេឆ្វាចុះឡើងទាំងចិត្តអន្ទះសា មិនដឹងថានាយចង់ធ្វើអ្វីទេ ។

មួយស្របក់មក នាយយើងទ្រោបមុខទៅលើជញ្ជាំងប្រាង្គទាំងឱរាន្ធត់ ញាប់ញ័រ ។ ទឹកភ្នែកពីរតំណក់បានប្រជ្រៀតខ្លួនហូរចាកនេត្រាទាំងគូរបស់នាយ មកប្រលែងនឹងផ្ទៃមុខដ៏ស្លោកស្រពោន ។ ខេមឫទ្ធិនឹកសង្វេគក្នុងចិត្តចំពោះរាជ ទេវីណាស់ ។ ត្រចៀកនាយហាក់ដូចជាហ៊ឹងស្តាប់លែងឮអ្វីទាំងអស់ ។ ភ្លាមនោះ នាយក៏បែរមើលទៅអាកាស ជុំវិញខ្លួនហើយក៏ឧទានបន្តទៀតថា :

- រាជធិតា! អូនធ្លាប់សន្យាថា អូននៅរង់ចាំបង!! ឥលូវបងមកដល់ហើយ.. តើអូននៅឯណា? ម្តេចមិនឃើញអូនមកជួបបងវិញតាមសន្យាដូច្នោះ?

រំពេចនោះ ស្រាប់តែនាយបានឮសូរសៀងឆ្លើយតបមួយត្រលប់មកវិញ :

CHANBOKEO . COM

- មល្លិកានៅរង់ចាំបងជានិច្ច... មល្លិកានៅចាំបង... បងខេមឫទ្ធិ.... !!

ខេមឫទ្ធិភ្ញាក់ស្មារតីព្រើតសំលឹងបែររកម្ចាស់សំលេង ស្រាប់តែឃើញរូបកាយ ព្រះរាជធិតាបានផុសឆ្ពោឡើងក្បែរនោះ ថែមទាំងមានទាំងដំណក់ទឹកនេត្រាជាប់ ព្រះនេត្រទាំងគូរបស់ព្រះនាងទៀតផង ។ ខេមឫទ្ធិឃើញហើយត្រេកអរភើត ស្ទុះទៅជិត លាតរង្វង់ដៃស្រវាក្រសោបកាយដ៏ល្វតល្វន់របស់ព្រះនាង... តែអនិច្ចា នាយយើង ស្រវាផុត១ មិនអាចចាប់ប៉ះព្រះនាងបានទាល់តែសោះ :

- មល្លិកា... មល្លិកា.... ហេតុអ្វីបងមិនអាច.... ?

រាជធិតា គង់នៅថ្ងឹងសំលឹងមកមាណពហើយក៏មានសវនីយ៍តបវិញថា :

- បងខេមឫទ្ធិ ! រូបដែលបងបានឃើញឥឡូវនេះ គ្រាន់តែជាស្រមោលនៃដួង វិញ្ញាណរបស់អូនតែប៉ុណ្ណោះ ។ ការពិតអូនគ្មានរូបរាងឱ្យបងអាចប៉ះពាល់បានទៀត ឡើយ ។

- រាជធិតា !( ខេមឫទ្ធិសំដែងឫកពារហាក់បីដូចជាខកចិត្តសំបើមខ្លាំងណាស់) បង ពិតជានឹករលឹករូបអូនខ្លាំងណាស់... !!

មាណពនិយាយទាំងខ្សឹកខ្សួលក្នុងឱរា ។ ចំណែកវិញ្ញាណរបស់រាជធិតាក៏ទ្រង់ ព្រះកន្សែងដូចគ្នា ព្រមទាំងវាចាទាំងអួលអាក់ថា :

- បងខេមឫទ្ធិ ! អូនត្រេកអរណាស់ដែលបងវិលមកវិញតាមសន្យា ទោះបីយឺត ពេលបន្តិចក៏ដោយ...តែពេលនេះ...យើងមិនអាចជួបគ្នាវិញ ដើម្បីរួមជីវិតជាគូគ្រង នឹងគ្នាបានទេ ត្បិតបងមានរូបកាយមានព្រលឹង ខុសពីមល្លិកាដែលនៅសល់ត្រឹម តែដួងវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះ...

ខេមឫទ្ធិសំលឹងភក្ត្រព្រះរាជធិតា រួចក៏បន្លឺវាចា :

- មល្លិកា!! តើបងត្រូវធ្វើយ៉ាងណាទៅវិញដើម្បីរំដោះវិញ្ញាណរបស់អូនបានទៅ?

រំពេចនោះ កាំរស្មីព្រះអាទិត្យក៏រះចាំងរស្មីផ្លេក១ភ្លឺខ្ទាលចូលតាមចន្លោះមែក ព្រឹក្សាលើកំពូលប្រាង្គ ស្រាប់តែរាជធិតាក៏រលាយស្រមោលទៅបាត់យ៉ាងរហ័ស ដោយមិនបានលាខេមឫទ្ធិអ្វីមួយម៉ាត់សោះ ។ មាណពឃើញដូច្នោះក៏ស្លន់ស្លោ រត់ចុះ រត់ឡើង :

- មល្លិកា!! កុំទៅណាចោលបង... មល្លិកា....

មើលចុះ ! នាយយើងឆ្វេឆ្វាមិនដឹងថាត្រូវធ្វើអ្វីទេ ក្រៅពីទទូចស្រែកហៅ វិញ្ញាណរាជធិតាឱ្យវិលវិញ ។ តែទោះជាយ៉ាងណាក៏គ្មានបានការអ្វីឡើយ ។ នាយមិនបានឃើញអ្វីទេ ក្រៅពីប្រាង្គដ៏ស្ពឹមស្ពៃកណ្ដាលព្រៃស្ងាត់តែប៉ុណ្ណោះ ។ អស់ចិត្តហើយ នាយក៏ដាក់ខ្លួនអង្គុយចុះ ហើយសោកសង្រេង សំដែងនូវទឹកចិត្ត ស្នេហាមួយម៉ឺនសែនអាល័យចំពោះរាជទេវី ។ អ្នកម្នាងក្ដី ព្រឹទ្ធជនតាងវ៉ាងក្ដី ព្រមទាំងនាម៉ឺនមន្ត្រីសេនាភិលៀងទាំងឡាយដែលនៅឈរហែហមទីនោះក្ដី ក៏នាំ គ្នាសំរួមតិរិយាបថយ៉ាងស្ងៀមស្ងាត់ស្រគត់ស្រគំ ហាក់ដូចជាកំពុង កាន់មរណទុក្ខ ចំពោះវិញ្ញាណក្ខន្ធ័របស់ទេពទេវី យ៉ាងស្រងេះស្រងោច ។

មួយស្របក់ក្រោយមក ខេមឫទ្ធិក៏ងាកមកសួរថា :

- អ្នកម្នាងខេមរី!! តើយើងត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីរំដោះដួងវិញ្ញាណរបស់រាជ ធិតាឱ្យផុតទុក្ខផុតកម្មពីការបំរើតួនាទីរក្សារាជសម្បត្តិមហានគរ ហើយអាចវិល ទៅចាប់ជាតិចាប់កំណើតជាមនុស្សលោកសាជាថ្មីដូចដួងវិញ្ញាណទាំងពួង?...

អ្នកម្នាងងាកសំលឹងមុខព្រឹទ្ធជនតាងវ៉ាងហាក់ដូចជាសុំយោបល់ ។ ឃើញ ដូច្នោះ ព្រឹទ្ធជនក៏មានប្រសាសន៍ឡើងថា :

- នៅក្នុងពិធីបូជាយញ្ញរំលាយរូបកាយក្នុងភ្នក់ភ្លើងរបស់មហានគរ ដើម្បីឱ្យក្លាយ ជាដួងវិញ្ញាណដែលមានមហិទ្ធិឫទ្ធិសក្ដិសិទ្ធិ ធិតាត្រូវតែជានារីបរិសុទ្ធហើយមាន ចិត្តស្មោះនឹងនគររបស់ខ្លួន។ កាលបើរាជធិតាបានក្លាយវិញ្ញាណសក្ដិសិទ្ធិហើយ

CHANBOKEO.COM

នោះព្រះនាងមិនអាចវិលទៅចាប់ជាតិកំណើតជាមនុស្សវិញបានឡើយគឺ វិញ្ញាណ របស់ព្រះរាជធិតា ត្រូវតែនៅគង់យាមថែរក្សាសម្បត្តិទ្រព្យមហានគរជានិរន្តន៏ អង្វែងរហូតផុតកល្ប ។

ខេមឫទ្ធិឮហើយ ក៏បើកភ្នែកធំៗ :

- បានន័យថា ព្រះនាងនឹងក្លាយជាដួងវិញ្ញាណនៅវិលវល់ដូច្នេះរហូតតទៅ?

ភ្លាមនោះ មាណពរលីងរលោងទឹកភ្នែកសាជាថ្មី ។ ភ្លាមនោះ អ្នកម្នាងក៏បន្លឺ វាចាឡើង ទៅកាន់នាយយើង ទំនងហាក់ចង់ជួយលួងលោមឱ្យនាយបានរសាយ ក្នុងឱរា :

- ប៉ុន្តែ នៅមានសល់មធ្យោបាយមួយ ដែលអាចជួយសង្គ្រោះព្រះនាងបាន...

ខេមឫទ្ធិអរភើតស្ទុះងើបយ៉ាងរហ័ស ហើយស្ដីសួរបន្ដយ៉ាងរន្ថើន :

- តើមធ្យោបាយអ្វីទៅ?...សូមអ្នកម្នាងមេត្តាប្រាប់ខ្ញុំផង....

- គឺរកនារីបរិសុទ្ធណាម្នាក់មកស្ម័គ្រ័បូជារូបកាយនិងជីវិត ដើម្បីឱ្យក្លាយជាវិញ្ញាណ សក្តិសិទ្ធិ ហើយចូលប្ដូរតួនាទីថែរក្សាសម្បត្តិទ្រព្យមហានគរបន្តពីរាជធិតា នោះ វិញ្ញាណរាជធិតានឹងអាចបានទទួលការដោះលែងឱ្យទៅចាប់កំណើតក្លាយជា មនុស្សបានវិញហើយ ។

ស្ដាប់ចប់ មាណពយើងដាក់មុខជ្រប់ ហើយពោលខ្សិប ៗ :

- តើនារីណាទៅដែលប្រថុយប្ដូរជីវិតមកទទួលនាទីបន្តពីរាជធិតា ? នោះពិតជា មធ្យោបាយដែលយើងមិនអាចរកចំលើយវិជ្ជមានបានឡើយ ។

ខេមឫទ្ធិដាក់ទឹកមុខជ្រប់ ធ្លាក់ក្នុងការអស់សង្ឃឹមវិញដដែល....

CHANBOKEO.COM

0000000000000000000000000000

ថ្ងៃលិចហើយ...

ព្រឹទ្ធជនតាងវ៉ាង បាននាំក្បួនដង្ហែជូនអ្នកម្នាងត្រលប់ទៅដំណាក់វិញ ទុកឱ្យ ខេមឫទ្ធិអង្គុយនៅត្រមង់ត្រមោចតែម្នាក់ឯងកណ្ដាលទ្រូងព្រៃ ។ យូរៗម្ដង យើង ឃើញនាយដកដង្ហើមធំ ជូនកាលងើបប្រកូកហៅរកដួងព្រលឹងរាជធិតា ជូនសំរក់ ទឹកនេត្រា សំដែងការអស់អាល័យចំពោះរាជធិតា ។ ការពិត នាយចង់ស្លាប់ណាស់ ស្លាប់ដើម្បីឱ្យវិញ្ញាណរបស់នាយបានទៅជួបរាជធិតា ។ ជិតមួយរាត្រីហើយដែល នាយអង្គុយរង់ចាំក្រែងព្រះនាងបង្ហាញរូបកាយសាជាថ្មី តែ..មាណពមិនបានប្រទះ អ្វីទាំងអស់ក្រៅពីសំលេងចង្រិតយំច្រែៗ និងក្លិនផ្កាវំដួលចោលក្លិនក្រអូបភាយៗ ពីនាយមកបបោសអង្អែលដួងចិត្តឱ្យធូរស្រាលទុក្ខសោកទាំងឡាយ....

ចាំ...

| | |
|---|---|
| រាត្រីសែនស្ងាត់បាត់តារា | បាត់ទាំងចន្ទ័ផ្កាធ្លាប់ពណ្ណរាយ |
| ជំនោរត្រសៀកបក់ពីនាយ | អារម្មណ៏វាយមាយនឹកម្ចាស់ស្នេហ៏ ។ |
| ពៅនៅទីណាមេត្តាឆ្លើយ | យប់ជ្រៅណាស់ហើយមុំមាសមេ |

ចិត្តរៀមនឹកថ្លៃដូចទន្លេ មិនគ្មេរហូរទៅដែនសមុទ្ទ ។
ចង្រិតយំច្រៃក្បែរគុម្ពស្មៅ ស្លឹកឈើរោយទៅគួររន្ធត់
គិតដល់ចរណៃស្មារតីស្លុត ក្លិនស្នេហ៍បរិសុទ្ធប្រៃឃ្លាតឆ្ងាយ ។
ទឹកភ្លៀងស្រក់ចាកកែវនេត្រា ច្រៀងផ្កាំធិតាស្រស់ឆោមឆាយ
បងនឹកអូនណាស់គ្មានរសាយ កំពូលហឫទ័យ វិលទេអូន ?

00 00

00

CHANBOKEO . COM

# វគ្គទី៦

# ផ្កាម្លិះមួយទង

-បងខេមឫទ្ធិ!! បង!!

មាណពយើងបានឮសៀងដ៏ពិរោះមួយខ្សិបដាក់ត្រចៀករបស់នាយស្រាល១ ។ នាយខំបើកភ្នែកឡើងសំលឹងរកមើលម្ចាស់សំលេង តែភ្នែកនាយនៅព្រិលនៅ ឡើយ មិនអាចមើលឃើញនាងច្បាស់ទេ គ្រាន់តែដឹងថា នាងមានកេសាវែង អន្លាយលំអដោយផ្កាម្លិះយ៉ាងក្រអូបទៀតផង ។ ខេមឫទ្ធិនឹកអរព្រួចនៅក្នុងចិត្ត ថែម ទាំងឧទានថា :

- មល្លិកា!! អូនត្រលប់មករកបងវិញហើយមែនទេ?

ស្រាប់តែនាងបែរជាសើចខឹក១ ហើយតបវិញថា :

- ចាស ! អូនមកដល់មែន តែអូនមិនមែនឈ្មោះមល្លិកាទេ ។ នេះគឺរចនាណាបង!

ខេមឫទ្ធិភ្ញាក់ព្រើត ស្ទុះក្រោកអង្គុយ :

- រចនា?... (នាយលាន់មាត់ផងបែរមើលជុំវិញខ្លួនផង) តើបងកំពុងឋិតនៅទីណា ឥលូវនេះ?

- នៅផ្ទះយើងណាបង ! ថ្ងៃនេះបងមមើមមាយទៀតហើយ...

- ហ្អែក? ចុះហេតុម៉េចបានជាបងមកដល់ផ្ទះយើងទៅវិញ ហើយមកពីអង្កាល់ ដែរ? ម្សិលមិញបងនៅសៀមរាបសុខ១ ភ្ញាក់ឡើងម៉េចបងមកនៅភ្នំពេញវិញ ឥចឹង?

ភ្លាមនោះ រចនាឈប់ញញឹម ហើយប្រែជាសំដែងទឹកមុខងឿងឆ្ងល់ :

- បងទៅសៀមរាបពីអង្កាល់? ម្សិលមិញម៉ាក់ចងអំបោះដៃអោយបង ហើយយប់ មិញបងសំរាន្តទាល់ភ្លឺរហូតដល់ថ្ងៃត្រង់ មិនទាន់ទាំងបានចេញដំណើរទៅណាផង ម៉េចក៏បងមានប្រសាសន៍ថាទើបត្រលប់មកវិញកើត?

ខេមឫទ្ធិឮដូច្នោះក៏ជ្រួញចិញ្ចើម ត្បិតនាយចាំច្បាស់ណាស់ ថាបានត្រលប់ទៅ សៀមរាប ថែមទាំងលួចកាត់បណ្តាច់ខ្សែអំបោះពរជ័យរបស់ម្តាយទៀតផង ។ ដើម្បីឱ្យអស់សង្ស័យ នាយក៏លើកដៃយកមកមើល ស្រាប់តែឃើញខ្សែអំបោះនៅ ជាប់នឹងដៃរបស់នាយដូចដើមដដែល ។ នាយភ្ញាក់ព្រើត ញីភ្នែកហើយមើលសា ជាថ្មី ក៏នៅតែឃើញអំបោះសជាប់នឹងដៃ ញីភ្នែកប៉ុន្មានដងក៏នៅដដែលមិនផ្លាស់ ប្តូរ... ពុទ្ធោអើយ!! ពេលនេះ នាយយើងមានអារម្មណ៍ថាឡប់ស្មារតីអស់ហើយ មិនដឹងថាតើជីវិតមួយណាជាការពិតសំរាប់នាយទេ ។ រំពេចនោះ តាងវ៉ាងរុញរទេះ ពិការនាំអ្នកស្រីមណីមកដល់បន្ទប់គេងរបស់នាយ ហើយបន្លឺវាចាថា :

- ម៉េចហើយសំលាញ់? គ្រាន់បើទេហ៎ថ្ងៃនេះ... មើលទៅមុខឯងដូចជានៅស្លេក នៅឡើយទេ ។

អ្នកស្រីមណីក៏មានប្រសាសន៍បន្ថែមថា :

- ម៉ាក់ឃើញកូនមិនស្រួលខ្លួនទើបមិនហ៊ានដាស់ បានជាចេះតែបណ្តោយឱ្យកូន គេងរហូតដល់ថ្ងៃត្រង់តែម្តងទៅ ។ ពេលនេះប្រហែលជាកូនឃ្លានហើយ ទើបម៉ាក់ មកបបួលហៅកូនទៅបរិភោគបាយជុំគ្នា ។

CHANBOKEO.COM

មាណពមិនបានឆ្លើយតបទៅអ្នកទាំងពីរវិញទេ ត្បិតអីនាយយើងកាន់តែ មានអារម្មណ៍ចំលែកឡើងក្នុងចិត្តបន្ថែមទៀត កាលបើឃើញនាយតាងវ៉ាង ក្លាយ មកជាបុរសដ៏ក្មេងសង្ហារវិញ មិនដូចកាលពីម្សិលដែលនាយបានប្រទះនៅខេត្ត សៀមរាប ជាតាចាស់ជ្រីវជ្រួញមើលមិនយល់នោះឡើយ ។ ខេមឫទ្ធិលើកដៃ ខ្ទប់ថ្ងាស ហើយខំសញ្ជឹងថាតើនាយពេលនេះត្រូវសំរេចចិត្តយ៉ាងណា បើជីវិតច្របូកច្របល់ដូច្នេះទៅហើយ បើថាមិនឱ្យគិតពីរាជធិតា មិនបានសោះឡើយ ព្រោះក្នុងចិត្ត

ក្នុងអារម្មណ៏របស់នាយហាក់ដូចជាមានតែរូបរាជធិតាមល្លិកាតែ ម្នាក់ប៉ុណ្ណោះដែល ផ្ចិតស្រមោលជាប់យ៉ាងជ្រៅក្នុងបេះដូងនាយមិនអាចដកវិញបាន ។ ចំពោះអ្វីៗទៀត នាយពិតជាអាចកាត់ចិត្តបំភ្លេចបានទាំងអស់ ។

លុះបរិភោគបាយហើយ ស្រាប់តែមានលោកវេជ្ជបណ្ឌិតចំណាស់ម្នាក់ចូលមក ដល់ ។ ខេមឫទ្ធិក្រលេកឃើញលោកភ្លាមក៏លាន់មាត់ឡើងថា :

- អ្នកម្តាយ ! កូនជាស្រួលបួលហើយ ម៉េចក៏នៅអញ្ជើញលោកមកពិនិត្យសុខភាព កូនធ្វើអ្វីទៀត ។

អ្នកស្រីឮហើយក៏ញញឹមហើយមានប្រសាសន៏តបវិញថា :

- ម៉ាក់ឃើញកូននៅមានកំលាំងទន់ខ្សោយ ហើយចេះតែគេងមមើមមាយផ្តេស ផ្តាស ទើបមិនអស់ចិត្តណាកូន ។

លុះដឹងថាម្តាយមានចិត្តបារម្ភមកលើខ្លួន នាយក៏នៅស្ងៀម ។ ប៉ុន្តែក្នុងឱកាស ដែលលោកវេជ្ជបណ្ឌិតពិនិត្យអាការរោគរបស់នាយ ស្រាប់តែខេមឫទ្ធិដាក់ភ្នែក ទៅតាមប្រលោះចំរឹងបង្អួចឃើញតាងវ៉ាងនិងរចនាកំពុងអង្គុយយោលទោងជដែក ហើយសើចញញឹមដាក់គ្នាជាច្រើនដង ។ នាយនឹកពិភាល់ក្នុងចិត្តណាស់ក៏ចេះតែ ដកកលួចមើលតាមកិរិយាអ្នកទាំងពីរមិនដាក់ភ្នែកសោះ ក្នុងចិត្តចេះតែមាន អារម្មណ៏ថា នាយហាក់ដូចជាខឹងនឹងតាងវ៉ាងហើយធុញថប់ក្នុងចិត្តយ៉ាងណាមិនដឹង ដែលមិត្តរបស់នាយមកមានចំណងស្និទ្ធស្នាលជាមួយរចនា ។ លោកវេជ្ជបណ្ឌិតមិន ទាន់ធ្វើការពិនិត្យរោគចប់ចុងចប់ដើមផង ខេមឫទ្ធិក៏ស្ទុះចេញទៅក្រៅហើយក៏ ដាក់ខ្លួនអង្គុយលើទោងចំប្រលោះកណ្តាលអ្នកទាំងពីរភ្លាម ដោយមិនស្តីអ្វីមួយ ម៉ាត់ ។ រចនានិងតាងវ៉ាងយល់កិរិយារបស់នាយដូច្នោះក៏នាំគ្នាឈប់និយាយអស់ ហើយបែរជាធ្វើមុខឡឹងឡង់ទាំង ពីរនាក់ ។

ក្រោយពីរចនាជូនដំណើរតាងវ៉ាងចេញទៅវិញ ខេមឫទ្ធិចូលបន្ទប់វិញអង្គុយ នៅក្បែរបង្អួចធ្វើមុខក្រម៉ូវ ។ អ្នកស្រីឃើញកូនប្រុសមានអារម្មណ៏មិនល្អក៏រាដៃ ជាសញ្ញាឱ្យរចនាទៅតាមមើលនាយ ។ នាងក៏ស្ទុះរឹងទៅរកបន្ទប់របស់ខេមឫទ្ធិយ៉ាងរហ័សភ្លាម :

-បង ខេមឫទ្ធិ! ចូលសំរាន្តហើយឬនៅ បង?

តុក! តុក! តុក!

- បងខេមឫទ្ធិ!!!... អូនសូមចូលបានទេ?

តែមិនឮសូរនាយឆ្លើយតបវិញសោះ ។ រចនាគិតរេរាមួយស្របក់មិនដឹងថា នាយកំពុងតែសំងំគេងឬក៏ដួលសន្លប់ដូចថ្ងៃមុនៗទៀត ក៏ស្ទុះបើកទ្វារទៅ ស្រាប់តែ ប្រទះឃើញមាណពអង្គុយច្រងុកអោបដៃនៅស្ងៀមឈឹងដូចរូបចំលាក់ ភ្នែកវិញ សំលឹងទៅក្រៅតាមបង្អួចមើលពពកដោយឥតមានពព្រិច ។ រចនាដើរទៅជិតយក ដៃទៅចាប់ជាយដៃអាវរបស់នាយ ហើយអង្រួនហៅ :

- បង! មិនស្រួលខ្លួនទៀតហើយមែនទេ ?

តែខេមឫទ្ធិនៅតែស្ងៀមធ្មឹងដដែល ។ ម្តងនេះរចនាហាក់មានអារម្មណ៏ភិត ភ័យណាស់ ក៏ឧទានថា :

- ឬក៏បងកំពុងតែភ្លឹកស្មារតីទៅវិញទៀតដូចកាលសព្វដង??

CHANBOKEO.COM

មាណេរីយកដៃទៅអង្រួនស្មានាយ តែមិនឃើញកំរើកតបមកសោះ ហើយក៏ មិនព្រិចភ្នែកដែរ ។ រចនាក៏អោនស្រវាលូកត្រកងលើកខ្លួននាយឡើង រួចហើយ លើកដៃនាយភ្ជាក់លើស្មារបស់នាង អូសនាយតតេះតតះ យកមកផ្អែកនៅលើគ្រែគេង ។ ភ្លាមនោះនាងឃើញខេមឫទ្ធិបិទ ភ្នែកហើយថ្ងូរហឹមៗក្នុងមាត់តិចៗ។ រចនាក៏ឈ្ងោកមុខដាក់ត្រចៀកក្បែរមាត់ នាយ ចង់ស្តាប់ថាតើនាយចង់និយាយអ្វី

មករកនាង  ស្រាប់តែឮនាយហៅខ្សិបៗ :

- មល្លិកា... មល្លិកា...

រចនានឹកឆ្ងល់ណាស់ថាតើមល្លិកាជាអ្នកណា ត្បិតតាំងពីខេមឫទ្ធិត្រលប់ពី សៀមរាបមកវិញ នាយតែងមមើមមាយហើយរកម្ចាស់នាមនេះមិនឈប់ឈរ សោះ ។  នាងយកដៃស្ទាបបុរសយើង ឃើញមានកំដៅក្តៅគគុក ក៏លើកយកភួយទៅដណ្តប់ឱ្យ ហើយក៏យកកន្សែងជ្រលក់ទឹកក្តៅដាក់លើថ្ងាសអោយនាយទៀត ។

រំពេចនោះស្រាប់តែខេមឫទ្ធិលូកដៃស្រវាចាប់ខ្លួននាងមកអោបរិតយ៉ាងណែនផ្ទាប់នឹងដើម ទ្រូងរបស់នាយ ធ្វើឱ្យធិតាយើងភ្ញាក់ភន្ដ័ភាំង មិនដឹងថាត្រូវបំរះចេញ ឬក៏ សំងំបណ្តោយតាម ។  ពេលនោះនាងបានឮនាយនិយាយខ្សិបៗបន្តទៅទៀតថា :

- បណ្តូលចិត្តបងអើយ... បងស្រលាញ់អូនណាស់... !!!

រចនារិតតែភ្ញាក់ស្មារតីខ្លាំងឡើង គិតក្នុងចិត្តថា :

- តើបងស្រលាញ់នារីណា? មល្លិកា... មែនទេហ៎?

គ្រាន់នឹកដល់ឈ្មោះនេះ នាងជ្រួញចិញ្ចើមភ្លាម ហើយស្ទុះងើបគេចចេញពី រង្វង់ដៃរបស់ខេមឫទ្ធិយ៉ាងរហ័ស ។ នាងបែរមើលទៅមាណពយ៉ាងយូរ ហើយ លាន់មាត់ខ្សិបៗថា :

- មល្លិកា... តើនាងជាអ្នកណា នៅឯណា? ដឹងខ្លួនទេថា នាងមានសំណាងណាស់ ដែលបងខេមឫទ្ធិមានចិត្តស្នេហាចំពោះនាងរហូតមមើមមាយហៅរកគ្រប់វេលា?

រចនាហាក់ដូចជាមានអារម្មណ៍ថាធុញថប់នៅក្នុងចិត្តណាស់ ។ បើតាមចិត្ត ខ្ញាញ់ នាងចង់តែដើរចេញទៅឱ្យបាត់ពីបន្ទប់មិនខ្ចីរវីរវល់នឹងខេមឫទ្ធិឡើយ តែលុះ ដល់ក្រលេកឃើញនាយមានមុខស្លេកៗបិទភ្នែកសន្ធឹងសន្ធៃស្ងៀមស្ងាត់ ក៏នឹកបារម្ភ ម្ល៉ោះហើយស៊ូនៅអង្គុយច្របាច់ជើងច្របាច់ដៃអោយនាយមួយស្របក់ ទើបទាញ ភួយមកដណ្តប់អោយនាយមុននឹងថយចេញទៅវិញ ។ មួយភ្លែតក្រោយមក ខេមឫទ្ធិបើកភ្នែកប្រែខ្លួនស្រវាក្រោកអង្គុយឡើង ឃើញកូនផ្កាម្លិះមួយទងជ្រុះនៅ លើភួយរបស់នាយ ។ មាណពលូកដៃស្រវាយកផ្កាម្លិះមកកាន់សំលឹង ហើយគិត ក្នុងចិត្តរារែក :

- តើម្ចាស់ផ្កាជាអ្នកណា? អូនរចនា ឬក៏ជារបស់រាជធិតាមល្លិកា?

ខេមឫទ្ធិលើកយកផ្កាមកដាក់ផ្ទាប់នឹងនាសា ស្រង់ក្លិនក្រអូបមួយខ្សឹតយ៉ាង វែង ស្រាប់តែផ្ទៃមុខរបស់នាយក្លាយជាមានភាពរីករាយខុសធម្មតា  ។ នាយ ក៏សំលឹងទៅផ្កាម្តងទៀត ព្រមទាំងស្រដីតែម្នាក់ឯងថា :

- ខ្ញុំពិតជាស្រលាញ់អ្នកណាស់ ណ៎ាផ្កាម្លិះដ៏ក្រអូបអើយ!!!

មែនហើយ   ពេលនេះ មាណពយើងមានអារម្មណ៍រំភើបរីករាយយ៉ាងណាមិន ដឹង ស្រាប់តែស្វាងស្មារតីធេងតែម្តង  ហើយគ្មានគិតអ្វីទេ ក្រៅពីគេងច្រៀងរងំក្នុង បំពង់កតែម្នាក់ឯង ។

CHANBOKEO.COM

ម្លិះរួតក្រពុំ

ឱ! ក្លិនផ្កាអើយសែនក្រអូប　　នាសាបងស្រូបស្រង់មិនណាយ
ម្លិះរួតក្រពុំគន្ធាសាយ　　ក្រេបហើយសប្បាយក្រេបជាថ្មី ។
ឱ! ក្លិនក្រពុំផ្ទំចុងមែក　　ចិន្តាបងត្រេកក្លិនភិសម័យ
ពិដោរបុប្ផាអប់ហឫទ័យ　　រីករាយចិត្តក្រៃឃើញស្ងិគា ។
បេះដូងបងមួយព្រួយលួចស្នេហ៍　　ម្លិះរួតដីខ្មែរល្អនាមា
សក្តិសមនឹងរូបក្លិនគន្ធា　　ពំងាបងស្ម័គ្រតែផ្កាអូន ។
ឱ! ម្លិះក្រពុំមាសចរណៃ　　រៀមសូមភក្តីលុះថ្ងៃសូន្យ
រក្សាក្លិនក្លែបផុតស្រពោន　　តើម្លិះពៅស្ងួនឆ្លើយយ៉ាងណា??

0000000000000000000000

ព្រហាមឡើងមិនទាន់ នាយក៏ស្ទុះងើបងូតទឹកតុបតែងខ្លួនយ៉ាងស្អាតបាត ហើយក៏រត់ទៅរកម្តាយដែលកំពុងសំរាន្តឯបន្ទប់នៅឡើយ :

- អ្នកម្តាយ! ថ្ងៃនេះកូនសូមនាំអ្នកម្តាយនិងអូនរចនាទៅដើរលេងម្តង...

អ្នកស្រីមណីភ្ញាក់ក្រញាង :

- ពីយប់មិញ ម៉ាក់ឮរចនាប្រាប់ថាកូនមិនស្រួលខ្លួនទៀតហើយ ចុះហេតុអីក៏ថ្ងៃនេះ កូនស្វាងលឿនម្ល៉េះ?

- បាទ ! កូនស្រួលបួលវិញហើយ អ្នកម្តាយ ។ ចុះរចនានៅឯណា?

- នៅក្រោយផ្ទះ កំពុងបោកខោអាវឯណោះ ។

- អញ្ចឹងកូនសុំទៅប្រាប់នាងសិនបាទ ! ចាំកូនមកជួយរៀបចំអ្នកម្តាយវិញ ។

- អ៊ឺ ! ទៅចុះកូន ។

ខេមឫទ្ធិចេញទៅខាងក្រោយផ្ទះ ក៏ប្រទះនឹងរចនាកំពុងតែរលាស់ខោអាវ ហាល ។

នាយលួចឈរគយគន់មើលនាងពីក្រោយខ្នងហើយគិតក្នុងចិត្ត :

- រចនា!! តើអូនមានអារម្មណ៍យ៉ាងណាចំពោះបងដែរទៅ ព្រលឹងបង?

មួយស្របក់មកទើបនាយគ្រហែមឡើង ។ រចនាឮហើយក៏ងាកផាំង ស្រាប់ តែឧទានទាំងភ្ញាក់ផ្អើលថា :

- បង! ស្រួលខ្លួនវិញហើយហ្នឹង បានជាចុះមកមើលខ្ញុំដល់នេះ?

- បាទ!

នាយយើងឆ្លើយតែមួយម៉ាត់ក៏ដើរមកជិតរចនា ហើយឈោងចាប់ដៃនាងឱ្យ ឈប់ រួចបន្តថា :

- អូនទុកអោយបងធ្វើបន្តចុះ ហើយឆាប់ទៅផ្លាស់សំលៀកបំពាក់មក ។ ថ្ងៃនេះ បងចង់នាំអូននឹងម៉ាក់ទៅកំសាន្តនៅក្រៅក្រុងម្តង ។

ឮដូច្នោះ ធិតាបែរងើបមើលមុខខេមឫទ្ធិធ្វើភាំង ទ្រង់ងឿងឆ្ងល់ :

- ក្រែងបងមិនទាន់ស្រួលខ្លួនមែនទែនឯណា? មិនបាច់ដើរលេងទៅណាក៏បានដែរ ណាបង ! ត្រឹមការងារផ្ទះតិចតួចបំរើបងនិងម៉ាក់ប៉ុណ្ណឹង មិនបានធ្វើឱ្យអូនធុញ ទ្រាន់ក្នុងជីវិតឬតប់ប្រមល់ចិត្តអ្វីបន្តិចទេ ។

CHANBOKEO . COM

- បងមិនបានគិតតចឹងឯណា? គ្រាន់តែចង់ផ្លាស់ប្តូរបរិយាកាសគ្រួសារយើងខ្លះៗ តែប៉ុណ្ណោះតើហ៎ ។ អូនឆាប់ទៅផ្លាស់ប្តូរសំលៀកភ្លាមទៅ ចាំបងបង្ហើយកិច្ចការ ដែលនៅសល់ទាំងនេះ ។

រចនាងាកសំលឹងមុខខេមឫទ្ធិម្តងទៀតទាំងងឿងឆ្ងល់ តែក៏មិនប្រកែកទៀត ដែរ ។ នាងបែរជាញញឹមយ៉ាងស្រស់ហើយពោលថា :

- ខ្ញុំសប្បាយចិត្តណាស់ បងដឹងទេ កាលបើបានឃើញបងមានសុខភាពនិងស្មារតី រឹងប៉ឹងមកវិញ ។

ខេមឫទ្ធិ សំលឹងមុខនាងដោយក្រសែភ្នែកដែលប្រកបដោយសេចក្តីស្រលាញ់ យ៉ាងធំធេង :

- ឆាប់ទៅផ្លាស់ខោអាវភ្លាមទៅ អាលឆាប់បានចេញដំណើរ ។

- ចាំសបង!!

រចនាតបទាំងញញឹមពព្រាយ ។

បួនម៉ោងក្រោយមក ខេមឫទ្ធិបាននាំរចនានិងអ្នកស្រីមណីមកដល់ឆ្នេរសមុទ្រ ដ៏ល្អវិចិត្រមួយនៅកំពង់សោម ។ ថ្ងៃនេះ រចនាសង្កេតឃើញខេមឫទ្ធិសប្បាយចិត្ត ប្លែកណាស់ ។ ក្រៅពីបំរើម្តាយយ៉ាងគាប់គួរនោះហើយ នាយក៏ហាក់ដូចជាយកចិត្ត យកថ្លើមនាងខុសធម្មតាដែរ ថែមទាំងស្រដីរួសរាយខុសសព្វកាលទៀតផង ។ តែ នាងមិនបានសង្ស័យអ្វីច្រើនទេ គ្រាន់តែគិតថា ប្រហែលជាមាណពយើងឈឺយូរថ្ងៃ អផ្សុកក្នុងចិត្តពេកហើយ បានជាថ្ងៃនេះចង់ផ្លាស់ប្តូរបរិយាកាសឱ្យមានអារម្មណ៍ល្អ មានកំលាំងមកវិញ នឹងអាលចេញត្រលប់ទៅធ្វើការនៅក្រសួងវិញតែប៉ុណ្ណោះ ។ នៅក្នុងម្លប់ខ្ទមទេសចរណ៍នាឆ្នេរខ្សាច់សអួរឈើទាល អ្នកស្រីមណីអង្គុយសំលឹង មើលកូនទាំងពីរ ពីចំងាយដោយទឹកមុខញញឹម ។ អ្នកស្រីក៏មានអារម្មណ៍សប្បាយ រីករាយក្នុងចិត្តពន់ពេកណាស់ កាលបើបានយល់នូវចំណងជិតស្និទ្ធរវាងកូនទាំងពីរ គ្រាន់តែមិនបានដឹងថាតើរចនាកូនស្រីរបស់គាត់គិតយ៉ាងណា សំរាប់អនាគតរបស់ នាង ។ ទោះបីពេលនេះ បំណន់ផ្សងរបស់លោកមានតែម្យ៉ាង គឺចង់អោយ អ្នកទាំងពីរមានចិត្តដូចគ្នា ក៏លោកគ្មានបំណងបង្ខំចិត្តកូនស្រីបន្តិចណាឡើយ ។ លោកចង់បណ្តោយអោយពេលវេលាជាអ្នកកាត់ក្តីឱ្យវិញ ក្រែងយុត្តិធម៌ជាជាង ។

នៅលើឆ្នេរខ្សាច់ស ខេមឫទ្ធិកាន់ដៃរចនាដើរយឺតៗ ទាំងទឹកមុខញញឹមមាន សុភមង្គល ។ តែរចនាវិញបែរជាមានកិរិយាហាក់អៀន ប្រៀនរឹងខ្លួនយ៉ាងណាមិន ដឹង ត្បិតខេមឫទ្ធិមិនដែលកាន់ដៃនាងម្តងណាទេ តាំងពីនាងធំពេញវ័យមកម្ល៉េះ ។ ថ្ងៃនេះ នាយមានកិរិយាចំលែកណាស់មិនដឹងថានាយកំពុងគិតពីអ្វីឡើយ ។ ទោះជា យ៉ាងណាក៏មាណវីហាក់ដូចជាមានអារម្មណ៍ថា ពេលនេះ នាងមានសេចក្តីសុខ មាន ការកក់ក្តៅក្នុងចិត្តអ្វីម្ល៉េះទេ កាលបើបានទទួលការយកចិត្តទុកដាក់ យ៉ាងជិតដិត ពីមាណពរបស់យើង ។ កំពុងតែគិតៗស្លុងអារម្មណ៍ ស្រាប់តែនាងបានឮស្នូរសូរ សៀងដ៏ពិរោះផ្អែមល្ហែមមួយចេញពីក្រអូមមាត់របស់ ខេមឫទ្ធិ :

ដានស្នេហ៍ឆ្នេរខ្សាច់

ឱវាលខ្សាច់ស ល្អដូចសំឡី ក្រោមព្រះសុរិយ៍ពេញវង់ភ្លឺថ្លា
ឆ្នេរកំពង់សោមល្បាញល្បីនាមា ថ្ងៃនេះសូមចារស្នេហាខ្ញុំផង ។
រលកគ្រាំគ្រេងប្រលែងលើឆ្នេរ ដូចសៀងបំពេររៀមនិងទងវង
យើងកាន់ដៃគ្នាកៀកកើយត្រសង លើវាលខ្សាច់ផងផ្សងស្នេហ៍និស្ស័យ ។
ជលធារសន្ធឹងមិនឃើញកោះត្រើយ មិនឆ្ងាយស្មើឡើយចិត្តស្មគ្រ័មេត្រី

CHANBOKEO.COM

វេហាស៍វែងខ្ពស់មិនស្មើភក្តី បងស្នេហ៍រូបស្រីគ្មានអ្វីវាស់បាន ។
ឱរលកអើយកុំឡើយអ្នកលប់ ដានស្នេហ៍គូគាប់ឆ្លាក់ទាំងពីរប្រាណ
ជាតិនេះជាតិណាសច្ចាប្រាំធាន ជួបតែកល្យាណជាគូរៀងអើយ...

- បងខេមឫទ្ធិ ! (រចនាឧទានឡើង)

- បាទ !

- នេះជាលើកទីពីរក្នុងជីវិតហើយណាដែលអូនបានឮបងច្រៀង ..

- អូនគិតថាប្លែកមែនទេ?

- ចាស មែនហើយបង ! ហេតុអ្វីបងផ្លាស់ប្តូរច្រើនម្ល៉េះ?

ភ្លាមនេះ ខេមឫទ្ធិញញឹមហើយតបវិញថា :

- នៅមានប្លែកតទៅទៀតណាអូន.. អូនខ្លាចទេ បើបងផ្លាស់ប្តូរ?

- អត់ខ្លាចទេ កុំតែបងប្តូរឈប់ស្គាល់រចនាទៅបានហើយ

- អញ្ចឹង!! នៅថ្ងៃនេះបងសូមប្រព្រឹត្តនូវអ្វីដ៏ចំលែកថែមមួយទៀតបានទេ?

ស្រាប់តែរចនាបើកភ្នែកធំៗ សំលឹងមុខ ខេមឫទ្ធិ :

- អត់ទេ!! បងចង់ធ្វើអ្វីហ្នឹង?

រចនារលាស់ដៃបំរុងរត់គេច គិតស្មានថាប្រហែលជាខេមឫទ្ធិសុំនាងថើបដៃ ថើបថ្ពាល់អ្វីផងក៏មិនដឹង ស្រាប់តែនាយចាប់ដៃនាងជាប់ហើយស្រដីថា :

- ម៉ោះ!! ទៅតាមបង!! បងចង់អោយម៉ាក់ធ្វើជាសាក្សីផង ។

ថាហើយ ខេមឫទ្ធិស្រវាអូសដៃរចនាដើរត្រលប់ថយក្រោយយ៉ាងលឿន សំដៅទៅរកអ្នកស្រីមណីនៅឯម្លប់ខ្ទមស្បូវ ។

ក្រុងកំពង់សោម នៅក្នុងព្រះវិហារវត្តលើកំពូលភ្នំ...

នៅចំពោះមុខអ្នកស្រីមណីនិងព្រះភិក្ខុមួយព្រះអង្គ ខេមឫទ្ធិ លូនចូលទៅ ក្រាបវន្ទាទន្ទឹមនឹងរចនា ហើយក៏បន្លឺវាចា :

- ថ្ងៃនេះ កូនសូមមកសារភាពនូវការពិតមួយនៅចំពោះមុខព្រះអង្គនិងអ្នកម្តាយ ដើម្បីសំដែងនូវការស្មោះត្រង់និងភក្តីភាពរបស់ខ្ញុំចំពោះនារីមួយរូបដែលខ្ញុំប្រាថ្នា រួមជីវិតជាគូគ្រងរហូតតទៅ ។

រចនាឮដូច្នោះក៏ភ្ញាក់ដូចគេកន្ត្រាក់ ហើយលាន់មាត់ខ្សិបៗ :

- បង ខេមឫទ្ធិ ! បងកំពុងធ្វើអ្វីទៀតហើយ ?

ភ្លាមនោះ មាណពយើងក៏លើកផ្តិលទឹកមួយដែលមានអប់ដោយផ្កាម្លិះយ៉ាង ក្រអូបយកមកកាន់ រួចក៏បែរមករចនា ហើយបន្លឺវាចាថា :

- រចនា ! អូនគឺជាបេះដូងរបស់បង ជាជីវិតរបស់បង... នៅថ្ងៃនេះ បងសូមអូន រៀបការជាគូរួមជីវិតរបស់បងនៅចំពោះមុខព្រះពុទ្ធអង្គ ព្រះសង្ឃនិងអ្នកម្តាយ... តើអូនឆ្លើយយ៉ាងណា...?

CHANBOKEO.COM

ព្រះអើយ!! តើឱ្យនាងឆ្លើយយ៉ាងណាទៅ បើប្រថុចញ៉ុចរកតែគិតអ្វីមិនទាន់ យ៉ាងនេះ? រចនាធ្វើមុខស្រលាំងកាំង ស្ដីអ្វីក៏មិនរួច រកញញឹមក៏មិនសម រកប្រកែក ក៏មិនកើត ។ លុះនាងបែរក្រលេកទៅម្ដាយឃើញលោកមើលមកនាងញញឹមយ៉ាង ស្រទន់មករកនាង ក៏មានអារម្មណ៍កក់ក្ដៅក្នុងចិត្តបន្ដិច ទើបងើបមុខញញឹមតប មកខេមឫទ្ធិវិញ ហើយស្រដីថា :

- ខ្ញុំមានអ្នកម្ដាយជាមាតាជីវិតសំរាប់កូន បើលោកយល់ថាប្រពៃ អូនយល់ព្រម គោរពតាមជានិច្ច ។

មាណពឮហើយក៏ញញឹមពព្រាយ ស្ទុះយកផ្តិលទឹកផ្កាម្លិះនោះមកប្រគេនព្រះភិក្ខុហើយក៏ក្រាបវន្ទា ។ ព្រះសង្ឃក៏សូត្រពិធីសព្វសាធុការប្រសិទ្ធិ៍ពរជ័យដល់គូ ស្នេហ៍ទាំងទ្វេហា ។ រីអ្នកស្រីមណីវិញក៏ហួតអំបោះបីសរសៃមកចងដៃកូនទាំងពីរ ព្រមទាំងមានប្រសាសន៍ថា :

- ម្ដាយស្រលាញ់កូនទាំងពីរស្មើជីវិតរបស់ម្ដាយ ។ មិនថាមានអ្វីកើតឡើងក្នុងជីវិត ទេ ចូរកូនកុំបោះបង់ចោលគ្នា កុំធ្វើបាបចិត្តគ្នាទៅវិញទៅមក ហើយត្រូវជួយ សំរាលទុក្ខធុរៈគ្នា ជាពិសេសគឺត្រូវចេះអភ័យទោសឱ្យគ្នាជានិច្ច បើសិនជាមានការ ឆ្គាំឆ្គង កើតឡើងដោយប្រការណាមួយ ។ ម៉ាក់សូមជូនសូមអោយកូនទាំងពីរ
ប្រទះតែសេចក្ដី សុខ និងសុភមង្គលជានិរន្តន៍តទៅ ។

រចនាបែរមើលទៅខេមឫទ្ធិឃើញនាយញញឹមដាក់នាងដោយក្រសែនេត្រា យ៉ាងស្រទន់ប្រកបដោយសេចក្ដីស្នេហាយ៉ាងធំធេងគ្មានព្រំដែន ក៏ដាក់ដៃផ្គុំ ប្រណម្យឡើង ហើយក្រាបសំពះទទួលអំបោះចំណងដៃពីមាតាព្រមជាមួយគ្នានឹង
បុរសយើងដោយទឹកចិត្តរំភើបក្អុកក្អួលរកថាមិនត្រូវ ។

លុះចប់ពិធីហើយ ខេមឫទ្ធិក៏នាំរចនានិងអ្នកស្រីមណីត្រលប់ចូលទៅរថយន្ត ធ្វើដំណើរត្រលប់មកផ្ទះវិញទាំងចិត្តរីករាយ ។ តាមផ្លូវ អ្នកស្រីមណីនៅអង្គុយខាង ក្រោយម្នាក់ឯងស្ងៀមស្ងាត់ ខុសអ្វីពីរចនានិងខេមឫទ្ធិដែលចេះតែលួចសំលឹងគ្នា ទៅវិញទៅមកតែពុំព្រមនិយាយអ្វីនឹងគ្នាសោះ ទំនងដូចជានឹកអៀនចំពោះគ្នានៅ ឡើយ ជាពិសេសគឺរចនាតែម្ដង សុខៗស្រាប់តែក្លាយខ្លួនជានារីដែលមានស្វាមី ដោយឥតព្រៀងទុក ។ គ្រានេះ នាងមានអារម្មណ៍ហាក់ដូចជាខេមឫទ្ធិនោះជា បុរសចំលែកក្នុងជីវិតទៅវិញ មិនមែនមនុស្សដែលនាងមានការស្និទ្ធស្នាលតាំងពីតូច មកសោះ មិនដឹងថាមកពីហេតុអ្វី បានជានាងមានអារម្មណ៍ដូច្នោះ ។ ម្យ៉ាងទៀត នាងក៏មិនទាន់ជឿជាក់ច្បាស់ថា ខេមឫទ្ធិមានចិត្តស្រលាញ់នាងដោយចិត្តស្មោះ បរិសុទ្ធឫយ៉ាងណា បើថ្មីៗនេះ នាងឮសូរនាយរវើរវាយហៅរកតែឈ្មោះមល្លិកា មិនឈប់ឈរសោះ មិនដឹងថាតើនាងជាអ្នកណា នៅឯណា ។ កំពុងតែគិតភ្លេច ខ្លួន ស្រាប់តែ ខេមឫទ្ធិនាំនាងនឹងម្ដាយមកដល់ផ្ទះល្វម ។

00 00

00

CHANBOKEO . COM

# វគ្គទី៧

# ភក្តីស្នេហ៍

រាត្រីថ្ងៃដដែល...

រចនាដើរទៅដើរមកក្នុងបន្ទប់ យ៉ាងអន្ទះសា ។ នាងមានអារម្មណ៍ភ័យអរៗ យ៉ាងណាមិនដឹង... នឹកឆ្ងល់ថាថ្ងៃនេះខេមឫទ្ធិនឹងត្រូវមកគេងរួមបន្ទប់ជាមួយនាង ឬក៏យ៉ាងណា កាលបីគេទាំងពីរបានរៀបការយ៉ាងត្រឹមត្រូវរួចហើយ ។ ពុទ្ធោអើយ! មើលចុះនាងភ័យបែកញើសស្រោក់តែម្នាក់ឯង ។ រំពេចនោះ ស្រាប់តែនាងឮសូរ ស្នូរគោះទ្វារ :

- រចនា! អោយបងសុំនិយាយជាមួយអូនបន្តិចបានទេហ៎?

មែនហើយ!! នោះជាសំលេងដ៏ក្រអួនក្រអៅរបស់ខេមឫទ្ធិ ។ រចនាភ្ញាក់ ក្រញាង រិតតែភ័យក្តុកក្តាក់ក្នុងទ្រូងរិតតែខ្លាំងឡើង ។ ខេមឫទ្ធិហៅម្តងទៀត :

- រចនា! អូនគេងហើយមែនទេហ៎? ឥចឹងចាំស្អែក ចាំយើងនិយាយគ្នាក៏បាន...

ពេលនោះរចនាឮសូរសិរបខេមឫទ្ធិជើងដើរចេញទៅវិញ ។ នាងក៏ស្ទុះងើប បើកទ្វារបន្ទប់បំរុងនឹងឃាត់ តែលុះដល់បើកទ្វាររួចហើយបែរជារារែកទៅវិញ ។ មួយស្របក់ក្រោយមក នាងក៏ដាច់ចិត្តដើរចេញពីបន្ទប់ទៅក្រៅបំរុងថានឹងទៅរកមាណពដល់បន្ទប់  ស្រាប់តែឃើញនាយនៅឈរក្រពាត់មើលផ្កាយរះឯរានហាល ខាងក្រៅ ។ នាងលួចដើរលបៗទៅឈរនៅក្បែរទ្វារលួចសំលឹងនាយពីក្រោយខ្នង ក្នុងចិត្តនៅតែរារែកដដែល ត្បិតនឹកមិនឃើញសោះថា តើនាងត្រូវនិយាយសួរ នាយអំពីអ្វីឡើយ ។ រំពេចនោះស្រាប់តែនាងហាក់ដូចជាឮសូរនាយនិយាយ រវើយៗហៅខ្សិបៗ តិចៗ ទៅអាកាសថា :

- មល្លិកា....

រចនាភ្ញាក់ព្រើត ! គ្រាន់តែឮឈ្មោះនេះកាលណា ឱរានាងហាក់ណែនណាន់ តានតឹងញាប់ញ័ររកថាមិនត្រូវ ។ ហេតុអ្វីទៅហ្ន៎ដែលគេមកសុំនាងរៀបការ ប៉ុន្តែ ចិត្តគេនៅតែស្រម័យនារីមួយរូបផ្សេងទៀត? រចនាគិតចុះគិតឡើងនៅតែមិន យល់ដដែល មិនតែប៉ុណ្ណោះ ចិត្តនាងរិតតែតប់ប្រមល់ទ្វេឡើងថែមទៀត ។ ទឹកនេត្រាពីរតំណក់ក៏រមៀលធ្លាក់ចុះមកប្រលែងនឹងថ្ពាល់ទាំងគូដ៏ផូផង់របស់ឆវី ។ នាងឱនយកដៃខ្ទប់ភ្នែកមិនឱ្យទឹកភ្នែកហូរចេញមក ស្រាប់តែមានដៃមួយមក ចាប់ដៃនាងចេញហើយលូកដៃមកផ្តិតទឹកភ្នែករបស់នាងជំនួសវិញ ។ នារីងើបមុខ ឡឹងទាំង ភ្ញាក់ ស្រាប់តែឃើញ ខេមឫទ្ធិនៅឈរចំពោះមុខនាងតែម្តង ។ ភ្លាមនេះ នាយក៏បន្លឺវាចាសួរនាងថា :

- រចនា! អូនស្រក់ទឹកភ្នែករឿងអ្វី? ឬក៏... មិនសប្បាយចិត្តចំពោះការដែលបងសុំ អូនរៀបការ?

រចនាឈ្ងោកមុខមិនតបត ។ នាយឃើញដូច្នោះក៏អូសដៃនាងមកអង្គុយ ចុះលើទោងយោល ហើយយកដៃផាត់សក់នាងចេញពីមុខរួចស្រដីយ៉ាងទន់ភ្លន់ទៅ កាន់នារីសោភាថា:

- អូនមិនសួរនាំ មិននិយាយអ្វីជាមួយបងខ្លះទេហ៎ រចនា? បងគ្មានអ្វីដែលលាក់ បាំងក្នុងចិត្តទេ... បើអូនចង់ដឹង បងរង់ចាំប្រាប់អូនជានិច្ច...

រចនាឮហើយគិតក្នុងចិត្ត តែម្នាក់ឯង :

CHANBOKEO.COM

- ចុះម៉េចចាំបាច់អោយរចនាសួរផង? បើសិនបងថាមានចិត្តស្មោះត្រង់នឹងអូន មែននោះ បងគួរតែប្រាប់អូនដោយត្រង់អំពីអារម្មណ៍ដ៏ពិតរបស់បងហើយ...

តែ... រចនារកហារមាត់និយាយទៅខេមឫទ្ធិមិនរួចសោះ មិនដឹងថាមកពី ហេតុអ្វីទេ គិតតែពីអង្គុយញ័រចំប្រប់ដូចកូនសត្វតែម្យ៉ាងប៉ុណ្ណោះ។ ឃើញនាងមាន កិរិយាដូច្នោះ ខេមឫទ្ធិក៏លូកដៃអង្អែលកេសានាងបន្តិចៗ :

- រចនា ! ទោះបីអូនមិនសួរក៏បងចង់និយាយប្រាប់អូនដែរ ដើម្បីឱ្យអូនបានយល់ ច្បាស់ពីចិត្តរបស់បង ។

ពេលនោះ រចនាឃើញនាយលូកយកចិញ្ចៀនមួយវង់ចេញពីហោប៉ៅហើយ ស្រវាលូកយកដៃឆ្វេងរបស់មាណវីយើងមកកាន់ព្រមទាំងវាចាថា :

- បងសូមផ្ញើបេះដូងនិងជីវិតរបស់បងលើដៃអូនហើយ តើអូនទទួលយកពីបងទេ ព្រលឹងមាសបង?

រចនាសំលឹងមុខខេមឫទ្ធិ ក្នុងចិត្តរបស់នាងនៅតែសង្ស័យមិនអស់មិនហើយ តែក៏មិនដឹងថាត្រូវតបវិញយ៉ាងណាឱ្យសក្តិសមទេ ។ នាងមិនឆ្លើយថាព្រម តែនាង ក៏មិនដកដៃវិញដែរ ។ លុះឃើញដូច្នោះ ខេមឫទ្ធិញញឹមយ៉ាងផ្អែមល្ហែមមួយដាក់ ឆវីយើង ហើយក៏យកចិញ្ចៀនស៊កម្រាមនាងដៃឆ្វេងរបស់នាងភ្លាម រួចក៏លើកយក មកថើបថ្នមៗ បង្ហាញ នូវជំរៅចិត្តស្នេហាដ៏ធំធេងរបស់នាយចំពោះមាណវី ។

ចិញ្ចៀនបញ្ចាំចិត្ត

១. ចិញ្ចៀនបងឆ្លាក់ដោយដួងចិត្ត ប្រគល់វរមិត្រ ម្ចាស់ចិត្តកំពូលស្នេហា
តំណាងបេះដូងថ្លៃវៀមរ៉ា សូមពៅធិតារក្សាផង ។

២. ចិញ្ចៀនមួយវង់រង់ចាំម្ចាស់ សាក្សីជាព្រះ សំពះភ្ជាប់ជាចំណង
តំណាងជីវិតអូននិងបង ភ្ជាប់ជាគូគ្រងរងនិស្ស័យ ។

៣. ចិញ្ចៀនបងមានផ្ញើតែអូន ទទួលផងស្ងួន ណាំនួនស្រីមាសចរណៃ
មួយវង់ដំណាងដួងហឫទ័យ លុះគ្រាបងក្ស័យមិនប្តូរផ្លាស់ ។

៤. ចិញ្ចៀនសូមឆ្លើយប្រាប់ពាលពៅ ឱ!មាសឆោមឆ្នៅ ពេលនេះទៅភ្លឺត្រចះ
ចិញ្ចៀនពណ៌មាសស្រស់ល្អល្អះ ដូចចិត្តបងស្មោះតែស្នេហ៍មួយ...

គ្រាន់ឮមាណពពោលចប់ រចនាក៏ញញឹមឡើងពព្រាយ។ រីឯ ចិត្តសង្ស័យទាំង អំបាលមាន ក៏រលាយពីដួងចិត្តរបស់នាងអស់រលីង ។ ស្រាប់តែ.... មានសំលេង មនុស្សស្រីលាន់គ្រលួចកាត់រាត្រី ស្រែកហៅ ខេមឫទ្ធិទៀតហើយ :

- បងខេមឫទ្ធិ !! អូននៅរង់ចាំបងជានិច្ច... មករកអូនផងម្ចាស់ស្នេហ៍អូនអើយ..

ខេមឫទ្ធិភ្ញាក់ក្រញាងបែររកមើលម្ចាស់សំលេង តែមិនឃើញអ្វីសោះ ។ នាយ ក៏លាន់មាត់ឡើងថា :

- រាជធិតា មល្លិកា?...

ឮខេមឫទ្ធិលាន់មាត់ដូច្នោះ រចនាក៏ភ្ញាក់ផ្អើលភ្នែកឡឹងឡង់ ហើយសំដែងកិរិយា ហាក់ដូចជាខកចិត្តចំពោះខេមឫទ្ធិណាស់ ។ ស្រាប់តែអ្នកទាំងពីរបានឮសូរសំលេង នោះហៅសាជាថ្មី :

- បង ខេមឫទ្ធិ!! បងវិលមករកអូនវិញទេ? ដឹងទេថាអូននៅរង់ចាំបងជានិច្ច...

CHANBOKEO.COM

មាណពព្យហើយក៏ក្រោកឈរឡើងយ៉ាងរហ័ស :

- រាជធិតា... បងនឹងទៅរកអូនពេលឥលូវនេះហើយ ។

ភ្លាមនោះ ខេមឫទ្ធិទំលាក់ដៃរចនាចុះ ហើយស្ទុះរឹងទាញកូនសោរឡានបំរុង បរចេញទៅទាំងយប់ស្រាប់តែរចនារត់ឆ្លេឆ្លាមកឈរពាំងពីមុខឡានលើកដៃរាមិន ឱ្យនាយចេញដំណើរ :

- បង ខេមឫទ្ធិ!! បងចង់ទៅណា?

- រចនា!! ឱ្យបងសុំទៅតែមួយភ្លែតទេ បន្តិចបងមកវិញហើយ ។

- បងប្រាប់អូនសិនមកថាបងចង់ទៅណា? បើមិនដូច្នោះ អូនមិនគេចផ្លូវអោយ បងទៅទេ...

- រចនា... បងមិនដឹងត្រូវពន្យល់អូនថាយ៉ាងណាទេ... តែបងដាច់ខាតត្រូវតែចេញ ទៅនៅពេលឥលូវនេះ...

- តើនរណាទៅដែលមានឥទ្ធិពលដណ្តប់ចិត្តបងដល់ថ្នាក់នេះ... បង ខេមឫទ្ធិ? បង ប្រាប់អូនបានទេហ៎ ថាគេជានរណា.....?

ខេមឫទ្ធិឮដូច្នោះក៏លេបទឹកមាត់ក្អឹក :

- គឺ..... គេជាគូកំណាន់ចិត្តរបស់បង តាំងពីច្រើនជាតិកន្លងមកហើយ...

- ចាំស? បងមានប្រសាសន៏ថាម៉េច ? រចនាមិនយល់ទេ...

- មែនណាំ! បងមិនភូតកុហកអូនទេ  បងជាប់កំណាន់សន្យាដែលបងធ្លាប់ប្រគល់ ជូនដល់រូបនាងកាលពីជាតិមួយនោះនាអតិតកាល ។ ឥលូវនាងមកតាមទាមទារ សន្យានោះពីបងវិញហើយ ។

- បង ខេមឫទ្ធិ ! បើសិនជាពិតដូចពាក្យបងពោលប្រាប់អូនមែន ពេលនេះ មានន័យថា នាងគ្រាន់តែជាដួងវិញ្ញាណតែប៉ុណ្ណោះ ប៉ុន្តែបងជាមនុស្សមានសាច់ មានឈាមពេញលក្ខណ៍ តើបងនឹងបំពេញសន្យានោះដូចម្តេចទៅ?

- អូនមិនយល់ទេ... រាជធិតាមល្លិកាបានត្រូវបណ្តាសាមិនអាចទៅចាប់ជាតិបាន លុះណាតែមានវិញ្ញាណថ្មីមកទទួលរងកម្មជំនួសព្រះនាង ទើបព្រះនាងអាចក្លាយជា មនុស្សមានសាច់មានឈាមដូចគេទាំងពួងឡើងវិញ...

- បានន័យថា បងទៅស្ម័គ្រ័បូជាជីវិតដើម្បីយកដួងព្រលឹងរបស់បងទៅរំដោះ វិញ្ញាណរបស់នាងមែនទេ?

- ជាំទ! មែនហើយ... ជាកូនប្រុសត្រូវតែរក្សាពាក្យសន្យារបស់ខ្លួន ។

- បើបងបំពេញសន្យាដើម្បីនាងមែន ចុះអូនវិញ... តើបងគិតយ៉ាងដូចម្តេចទៅ? បងចាំបានទេហ៎ ថាបងទើបតែសច្ចាចំពោះអូនថ្មីៗនៅឡើយទេ ហេតុអ្វីក៏បងឆាប់ ភ្លេចម្លេះ?

ខេមឫទ្ធិសំលឹងមុខនាងតែមិនឆ្លើយយ៉ាងណាទេ ។ អាល័យតែប្រកែកទៅ ប្រកែកមក រចនាក៏ប្រហែសខ្លួនមិនបានប្រុងប្រយត្ន័ ស្រាប់តែខេមឫទ្ធិ ស្ទុះហក់ ចូលឡានបើកគេចនាងហើយបរចេញទៅយ៉ាងលឿនស្លេវ ។ រចនាឃើញហើយ ស្ទុះរត់តាមក្រោយលើកដៃបបោយហៅយ៉ាងរន្ធត់ :

- ឈប់សិន បង ខេមឫទ្ធិ ! ឈប់សិន ចាំអូនផង... បង....

តែគួរអនិច្ចា!! ខេមឫទ្ធិបានបររថយន្តចេញទៅឆ្ងាយបាត់ស្រមោលទៅហើយ ដោយមិនបានឮសូរសៀងរបស់នាងដែលស្រែកហៅនោះឡើយ ។ មាណវីយើង ដាក់ខ្លួនឈរផ្អែកនឹងមាត់របង ស្រក់ទឹកភ្នែកតក់ៗតែម្នាក់ឯង....

នៅខាងលើរានហាលខាងមុខផ្ទះ អ្នកស្រីមណីអង្គុយលើរទេះពិការ ស្តាប់ការ ជជែកកក្អារបស់កូនទាំងពីរ ឮគ្រប់ម៉ាត់ទាំងអស់ ប៉ុន្តែ តើឱ្យអ្នកស្រីជួយគេដូចម្តេច ទៅ? បន្តិចក្រោយមក រចនាស្ទុះរត់ឡើងទៅលើផ្ទះវិញ ទៅស្រវាអោបម្តាយ ទ្រហោរយំ ខ្សឹកខ្សួលជាលើកដំបូងបង្អស់ក្នុងជីវិតរបស់នាងតាំងពីធំពេញវ័យមក :

CHANBOKEO.COM

- អ្នកម្ដាយ! កូនមិនយល់សោះថា ហេតុអ្វីបង ខេមឫទ្ធិគាត់ធ្វើយ៉ាងនេះ? ថ្ងៃនេះ គាត់បានសុំកូនរៀបការយ៉ាងត្រឹមត្រូវ តែអារម្មណ៍គាត់បែរជាស្រម័យរកអ្នកផ្សេង ទៅវិញ? អ្នកម្ដាយ! តើអោយកូនគិតយ៉ាងណា?

អ្នកស្រីមណីដកដង្ហើមធំ :

- រចនា! ម្ដាយក៏គិតមិនយល់ដូចគ្នា... តែ... ម្ដាយនៅតែមានពិភាល់ក្នុងចិត្តថា គេពិតជាត្រលប់មករកកូនវិញមិនខាន....

រចនាជូតទឹកភ្នែកហើយបែរសំលឹងទៅមេឃ រួចបែបន់ថា :

- សូមឱ្យបងបាត់សុខសប្បាយ ហើយឆាប់វិលមកផ្ទះរបស់យើងវិញណាំបង ។

ថ្លែងពីមាណពយើងវិញម្ដង....

ជាងបួនម៉ោងក្រោយមកគេក៏បានមកដល់សៀមរាបដោយសុវត្ថិភាព។ ពេល នោះ ព្រះអាទិត្យក៏រះព្រាង១ឡើង។ មាណពបានមកដល់មុខប្រាង្គត្រ័យលក្ខណ៍ ដែលស្ថិតនៅឈរស្ដឹមស្កៃកណ្ដាលទ្រូងព្រៃ ។ នាយអុជធូបហើយបែបន់ខ្សិប១ តិច១ថា :

- រាជធិតា មល្លិកា... បងមកដល់ហើយតាមសន្យា.... តើអូននឹងបង្ហាញរូបកាយ អោយបងបានឃើញទេហ៍?

អនិច្ចា!! មាណពមិនបានឮអ្វីទេ ហើយក៏មិនបានជួបអ្នកណាដែរ ។ គេនៅ អង្គុយចាំយ៉ាងយូរ នៅតែមិនឃើញចំលើយតបដដែល ។ នាយនឹកមិនអស់ចិត្ត ក៏ ដើរបកក្រោយត្រលប់ទៅរកដំណាក់អ្នកម្នាងខេមរី ស្រាប់តែបាត់រាជដំណាក់ទៅ ណាមិនដឹង បែរជាឃើញសុទ្ធតែចេតិយច្រូងច្រាងជាច្រើន ព្រមទាំងឃើញមានន ដើមពោធិព្រឹក្សមួយយ៉ាងធំត្រឈឹងត្រឈៃមួយដុះក្បែរព្រះវិហារ និងស្រះឈូក យ៉ាងស្អាតសោភាទៅវិញ ។ មាណពនឹងឆ្ងល់សែនឆ្ងល់ ក៏រត់ចុះរត់ឡើង ក៏បានមកដល់ទីធ្លាមុខប្រាង្គត្រ័យលក្ខណ៍វិញដដែល។ នាយអន្ទះសាក្នុងចិត្តឆ្លេឆ្លា១ មិនដឹងថាត្រូវធ្វើយ៉ាងណាទៀត ។ មួយសន្ទុះក្រោយមក នាយក៏បានឮសូរសៀង ហៅឈ្មោះនាយដដែលឡើងទៀត :

- បង ខេមឫទ្ធិ ! អូននៅរង់ចាំបងជានិច្ច!! បងនៅឯណា ឆាប់មកជួយរំដោះអូន ផង.... ណាំកំពូលដួងចិត្ត!!

ឮភ្លាម ខេមឫទ្ធិភ្ញាក់ក្រញាង ដើរផងរត់ផងតាមរកម្ចាស់សំលេង ប៉ុន្តែ នាយ យើងមិនបានប្រទះម្ចាស់សៀងឡើយ ។ ភ្លាមនោះ នាយក៏ស្រែកឆ្លើយតបទៅ កាន់ម្ចាស់សំលេងនោះថា :

- រាជធិតា ! បងដឹងថាវិញ្ញាណរបស់អូនបានត្រូវរងទុក្ខ នៅចាំយាមថែរក្សាមហា នគរអស់ជាច្រើនរយច្រើនពាន់ឆ្នាំមកហើយ ។ បងពិតជាអាណិតអូនឥតឧបមា.... មិនអាសូររូបអូនមិនបានទេ... ។ ថ្ងៃនេះ បងប្រាថ្នាយកជីវិតរបស់បង មកប្ដូរ ដើម្បីរំដោះដួងវិញ្ញាណរបស់អូនឱ្យបានផុតទុក្ខផុតកម្មអកុសល ឈប់វិលវល់រង់ចាំ ចាំនូវការវិលត្រលប់របស់បងតទៅទៀត!!!

ថាចប់ ខេមឫទ្ធិទាញកាំភ្លើងខ្លីមួយដើមចេញមកហើយលើកដាក់ក្បែរសៀត ផ្ការបស់នាយ រួចបិទភ្នែក គិតថាបំរុងនឹងគាស់កៃ ស្រាប់តែមានសំលេងមួយ ស្រែកកាត់យ៉ាងរហ័ស :

- មិនអាចទៅរួចទេ លោកមហាសេនា!!

ខេមឫទ្ធិភ្ញាក់ព្រើត បើកភ្នែកឡើង ស្រាប់តែប្រទះនឹងព្រឹទ្ធជនតាងរ៉ាង ព្រម ទាំងអ្នកម្នាងខេមរី ថែមទាំងមានហ្វូងកិលៀងសេនាហែហមបានមកដល់យ៉ាង គគ្រឹកគគ្រេង ។ នាយដាក់កាំភ្លើងចុះ ហើយនឹកឆ្ងល់ក្នុងចិត្តថា តើពួកគេមកដល់ពី អង្កាល់ ហើយមកតាមណា ហេតុអ្វីបានជានាយមិនឮស្នូរសិ៊បជើងអ្វីសោះយ៉ាង នេះ . ភ្លាមនោះ ព្រឹទ្ធជនតាងរ៉ាងបន្លឺវាចាបន្តទៅទៀតថា :

CHANBOKEO.COM

-ឥតប្រយោជន៍ទេដែលលោកចង់បូជាជីវិតរបស់ខ្លួន ដើម្បីរំដោះប្តូរយកដួង វិញ្ញាណរាជធិតា ឱ្យបានទៅចាប់ជាតិ
យ៉ាងណាក៏ដោយក៏មិនអាចទៅរួចដែរ...

- តើព្រោះហេតុអ្វីទៅ? (ខេមឫទ្ធិសួរ)

- ត្បិតលោកជាបុរស... មានតែដួងវិញ្ញាណរបស់នារីបរិសុទ្ធតែប៉ុណ្ណោះទើបអាច
មានប្រសិទ្ធិភាពសក្តិសិទ្ធិជួយព្រះនាងសុរភីមល្លិកាឱ្យផុតបណ្តាសានៃការបូជាយញ្ញ នោះបានដែរ ។

- ប៉ុន្តែ ខ្ញុំជាស្រី សុខចិត្តបូជាជីវិតដើម្បីរំដោះវិញ្ញាណព្រះនាងនៅពេលនេះចុះ !!! ហើយព្រះរាជធិតានឹងមានឱកាសក្លាយជាមនុស្សមកវិញ
នឹងអាលបានវិលមក ជួបជុំជាមួយ គូរស្នេហ៍របស់ព្រះនាងសាជាថ្មី !

ឮវាចានេះកាលណា មាណពភ្ញាក់ដូចគេចាប់គ្រវែង ហើយបែរក្រោយផាំង ងាកសំលឹងរកម្ចាស់សំលេង ឃើញហើយក៏ឧទានយ៉ាងរហ័សថា :

- រចនា!! អូនមកពីអង្កាល់? ហើយយ៉ាងម៉េចបានជាអូនដឹងថាបងមកដល់ទីនេះ?

ខេមឫទ្ធិ ស្ទុះងើបឡើងទៅរកនាងភ្លាម ។ រចនាដើរចូលមកយឺត១ ភ្នែក
សំលឹងទៅកំពូលប្រាង្គ រួចលើកដៃផ្គុំប្រណម្យ បន្លឺវាចាថា :

- រាជធិតាមល្លិកា!! ថ្ងៃនេះ រាជធិតានឹងបានរួចផុតគុកកម្មដែលបានចងដួង វិញ្ញាណរបស់ព្រះនាងច្រើនរយឆ្នាំមកហើយ ។ នាងខ្ញុំរចនា
សូមពលីជីវិតរបស់ នាងខ្ញុំផ្ទាល់ នៅពេលនេះ ដើម្បីសេចក្តីសុខរបស់រាជធិតានិងបងខេមឫទ្ធិ ដែលនាងខ្ញុំស្រលាញ់ជាទីបំផុតក្នុងលោក ។
សូមអោយសេចក្តីស្នេហារវាងអ្នក ទាំងពីរ មានអាយុស្ថិតស្ថេរក្សេមក្សាន្ត ចាប់ពីពេលនេះតរៀងទៅ ។

ថាចប់ រចនាក៏បិទនេត្រា ហើយទន់ដៃទន់ជើងដួលប្រួសទៅលើដី ថែមទាំង មានធ្លាក់ឈាមពីមាត់មកយ៉ាងខ្លាំងទៀតផង ។
ខេមឫទ្ធិឃើញដូច្នោះ រន្ធត់ចិត្ត ណាស់ ក៏ស្ទុះទៅចាប់ត្រកងបីលើកនាងឡើង :

- រចនាអូន... អូនយ៉ាងម៉េចហ្នឹង? ហេតុអ្វីអូនធ្វើយ៉ាងនេះ? រចនា...

ទឹកភ្នែកជាច្រើនដំណក់បានប្រជ្រៀតគ្នាហូរចេញពីកែវនេត្រារបស់ខេមឫទ្ធិ។ ពេលនេះ នាយរន្ធត់ចិត្តអ្វីម្ល៉េះ អាណិតផង ភ័យផង
ញាប់ញ័រក្នុងចិត្តគិតអ្វីក៏លែង ឃើញហើយ កាលបើឃើញរចនាសុខចិត្តធ្វើពលិកម្មដើម្បីសេចក្តីសុខរបស់នាយ :

- អូនមិនគួរមកប្តូរស្លាប់ដើម្បីរូបបងនិងព្រះនាងទេ.... រចនា...

មាណវីលើកដៃឡើងស្ទាបមុខបុរសយើងហើយបើកភ្នែកព្រឹម១ ព្រមទាំង ស្រដីខ្សាវ១ថា :

- អូនបានលេបថ្នាំបំពុលសំលាប់ខ្លួន... ពេលនេះ គ្មានអ្វីអាចជួយអូនបានឡើយ... ការពិត...អូនមិនចង់រស់នៅ
ដោយឃើញបងគេងអោបសេចក្តីទុក្ខក្នុងដួងចិត្ត ចំពោះស្នេហារបស់បងរៀងរាល់ថ្ងៃបានទេ ។ បងខេមឫទ្ធិ! អូនស្រលាញ់បង...
ហើយហ៊ានបូជាជីវិតដើម្បីសេចក្តីសុខរបស់បង... តែប៉ុណ្ណឹង វិញ្ញាណរបស់អូន នឹងបានស្ងប់មិនខាន។ ម្យ៉ាងទៀត
អូនធ្វើនេះគឺដើម្បីឱ្យបងក៏នឹងមានឱកាសជួប គូបណ្តូលចិត្តរបស់បង វិញតែប៉ុណ្ណោះ.....

- អត់ទេ ! រចនា! អូនមិនស្លាប់ទេ!.. បងមិនអាចបណ្តោយអោយអូនស្លាប់បានទេ
រចនា... បងស្រលាញ់អូន... អូនបើកភ្នែកឡើង !! អូនកុំទៅណាចោលបង... រចនា... (បុរសយើងទ្រហោរយំផង
ស្រវាអោបនាងយ៉ាងណែនផ្ទាប់ដើមទ្រូងផង)

នាគ្រានេះ ខេមឫទ្ធិរន្ធត់តក់ស្លុតក្នុងចិត្តអ្វីម្ល៉េះទេ។ នាយមានអារម្មណ៍ថា
ឈឺចាប់ក្នុងដើមទ្រូងដូចត្រូវគេទូងដំធើទារុណកម្មយ៉ាងធ្ងន់ធ្ងរបំផុត ។ នាយញ័រ ដៃញ័រជើង ហ៊ឹងត្រចៀក លែងយល់អ្វីហើយ
ក្រៅតែពីអង្រួនដាស់រចនាឱ្យ រលឹកស្មារតីមកវិញ :

CHANBOKEO.COM

- រចនាអូន! បងគិតខុសហើយ... បងជាបុរសកំសាក មានចិត្តរារែក... មិនគិតអ្វី ធ្វើអ្វីដោយការប្រើសតិ... បងសោកស្តាយណាស់ កំពូលដួងចិត្តរបស់បង... គ្រានេះ បើសិនជាបងត្រូវបាត់បង់រូបអូនទៅ... បងនឹងមិនអភ័យទោសដល់ខ្លួនរបស់បង ឡើយ ។ កាលបើគ្មានប្រូអូន ជីវិតបងក៏គ្មានន័យនឹងរស់នៅតទៅទៀតដែរ... រចនា! បើកភ្នែកឡើងមក៏... មើលមុខបងណាអូន... ហើយស្តាប់បងនិយាយប្រាប់ អូនសាជាថ្មី ថាបងស្រលាញ់អូន... បងស្រលាញ់អូនតែម្នាក់គត់ ហើយគ្មាននារីណា
អាចបេះយកដួងចិត្តរបស់បងចេញពីសេចក្តីស្នេហាដ៏ធំធេងចំពោះអូនបានទេ....

អភ័យទោសផង....

អភ័យទោសផងស្នេហាបងអើយ គ្រានេះស្តាយក្រោយដែលបងគិតខុស
ព្រោះតែរារែកគ្មានភាពស្មគ្រ័ស្មោះ ឥឡូវត្រូវរស់លង់ភពសោកា ។
ដំណក់លោហិតផ្តិតជាប់ដៃបង ជាឈាមចំណងលាងចិត្តស្នេហា
កល្យាណពលីដើម្បីរៀមរ៉ា ពេលនេះធិតាមរណាចោលបង ។
ស្តាយណាស់ស្តាយគួរមិនបានត្រៀមគិត ម្ល៉ោះហើយជីវិតជួបភាពសៅហ្មង
កំហុសបងមួយព្រួយដល់ទងវង្ស គ្រួសារនាងផងមិនដឹងយ៉ាងណា ។
ជាតិនេះមានបាបមិនអាចសង្គ្រោះ បងពិតមានទោសគួរតែមរណា
ឱ! អង្គឥន្ទព្រហ្មសូមលោកមេត្តា ប្រោសមុំធិតាឱ្យចាកគ្រោះភ័យ ។
អភ័យទោសផងទងវង់បងអើយ ទទួចអូនហើយសូមឱកាសថ្មី
បើអូនផុតគ្រោះបងរស់នឹងស្រី មិនបែរដោះដៃលុះក្ស័យបងស្មោះ ។

គួរអនិច្ចាណាស់!! រចនាកាន់តែមានអាការៈទន់ខ្សោយណាស់ទៅហើយ ។ នាងហើបមាត់និយាយម្តបៗ មកកាន់បុរសយើង ។ នាយក៏ឱនយកត្រចៀកស្តាប់ តែមិនឮសំដីអ្វីទាំងអស់ ។ ទឹកភ្នែកជាច្រើនតំណក់ក៏ប្រជ្រៀតគ្នាហូរស្រក់មកលើ ផ្ទៃមុខរបស់ខេមឫទ្ធិ ដែលកំពុងតែទទូចអង្វរសុំព្រលឹងរចនាឱ្យវិលវិញយ៉ាងខ្លោច ផ្សារសាជាថ្មី ។ ណាយយើងសំលឹងមុខនាង ហើយត្រិះរិះក្បាលមិនអស់មិនហើយ នឹងស្តាយដែលនាយមិនអាចបង្វិលពេលវេលាអោយវិលក្រោយបាន ដើម្បីខាខាំង មិនឱ្យរចនាសំរេចចិត្តធ្វើបាប ខ្លួននាងដូច្នេះ....
- បងខេមឫទ្ធិ... បងលែងស្រលាញ់មល្លិកាហើយមែនទេហ៎???

ខេមឫទ្ធិភ្ញាក់កន្ត្រាក់កាលបើឮសំលេងនារីម្នាក់ស្រដីមករកនាយ ។ មាណពក៏ ងើបមុខឡើងងាករកម្ចាស់សំលេង ក៏បានយល់ព្រះរាជធិតាសុរភីមល្លិកាផុសជ្រងោ នៅចំពោះមុខ :
- រាជធិតាមល្លិកា.... (ខេមឫទ្ធិលាន់មាត់)

ភ្លាមនោះ រាជធិតាហុចព្រះហស្តព្រះនាងមករកខេមឫទ្ធិ :
- បងខេមឫទ្ធិ! អូនស្រលាញ់បង... អូនចង់នៅរួមរស់ជាមួយបងណាស់.. អូនរង់ ចាំបងជាយូរយារណាស់មកហើយ... តើពេលណាបងផ្តល់ចំលើយមកអូន...?. បង ខេមឫទ្ធិ... សូមបងចាប់ដៃអូនអោយប៉ះនឹងដៃរចនាទៅ នោះយើងនឹងបានប្តូរ វិញ្ញាណគ្នាហើយណាបង.... ហើយអូនក៏នឹងក្លាយជាមនុស្សវិញដែរ....

CHANBOKEO.COM

មាណពសំលឹងមើលរាជធិតា រួចបែរសំលឹងរចនា... ។ ពេលនេះនាយមាន ការតក់ស្លុតរន្ធត់ក្នុងចិត្តណាស់ តើនាយត្រូវគិតបែបណា.... បើនាយជ្រើសរើសយក រាជធិតាមល្លិកា នាយនឹងបាត់បង់រចនា....។ បើជ្រើសរើសរចនា រាជធិតានឹងត្រូវ រងទុក្ខក្នុងបណ្តាសាយ៉ាងឈឺចាប់បន្តទៅទៀតគ្មានថ្ងៃស្រាន្ត ។ រំពេចនោះស្រាប់តែ មានសំលេងស្ត្រីម្នាក់ទៀតពោលឡើងថា :

- ឈ្ងើយចុះ ទុកអោយម៉ាក់ជាអ្នកស្លាប់វិញ!! ដើម្បីប្តូរវិញ្ញាណរំដោះរាជធិតា ឱ្យនាងបានជួបកូនប្រុសម្តាយដែលម្តាយស្រលាញ់ជាទីបំផុតនោះវិញសាជាថ្មី !!

- អ្នកម្តាយ !! ( ខេមឫទ្ធិបែរឃើញហើយលាន់មាត់ )

អ្នកស្រីមណីក៏បង្វិលកង់រទេះពិការនាំខ្លួនអ្នកស្រីចូលមកដល់ ថែមទាំងមាន ប្រសាសន៍បន្តថា :

- ម្តាយជាជនពិការ រស់នៅសំរាប់តែជាបន្ទុកសំរាប់កូនតែម្យ៉ាង បើអោយម្តាយ ស្លាប់ដើម្បីរំដោះទុក្ខសោករបស់កូនសំលាញ់.. ម្តាយគួរស៊ូប្តូរទៅចុះ ។

ថាចប់អ្នកស្រីក៏លើកកូនកាំបិតឡើងបំរុង នឹងចាក់សំលាប់ខ្លួន ស្រាប់តែខេម ឫទ្ធិទំលាក់រចនាចុះហើយរត់ទៅចាប់ដៃម្តាយជាប់ ។ បន្ទាប់ពីនាយទាញយក កាំបិតចេញបានហើយ បុរសយើងក៏ក្រាបក្បាលដល់ដីសំពះម្តាយ :

- អត់ទេ! អ្នកម្តាយដ៏មានគុណរបស់កូន...! សូមលោកកុំធ្វើដូច្នោះអី... កូនពិតជាត្រូវទទួលរងបាបកម្មធ្ងន់ណាស់...

- កូនប្រុសម្តាយ... តើអោយម្តាយនៅរស់ដើម្បីអ្វីទៅ បើកូនម្តាយត្រូវស្លាប់ចោល ម្តាយទៅហើយ មិនថាជាខេមឫទ្ធិឬជារចនាទេ ម្តាយស្រលាញ់កូនទាំងពីរណាស់ ណ៎ាកូនម្តាយ... បាត់នរណាម្នាក់ពីជីវិតម្តាយមិនបានឡើយ ។

ភ្លាមនេះ រាជធិតាមានសវនីយ៍មកនាយបន្តថា :

- បងខេមឫទ្ធិ ! អូនស្រលាញ់បង... ចង់រួមរស់ជាមួយបង ដូចដែលយើងធ្លាប់ បានសច្ចានឹងគ្នា... ពេលនេះ បងប្រែក្បត់សន្យាមិនបានទេ...

ពេលនោះ មាណពមានអារម្មណ៍ថាខ្លួនកំពុងតែត្រូវបណ្តាសាយ៉ាងធ្ងន់ធ្ងរ បំផុតក្នុងជីវិត ។ លុះមាណពដាក់ភ្នែកទៅឃើញរចនាមានឈាមហូរពីមាត់កាន់តែ ខ្លាំង ហើយមានស្មារតីក៏ថមថយទៅ នាយក៏ស្រវាលើកកាយនាងឡើងហើយ ស្រដីថា :

- រចនា... បងមិនអាចបណ្តោយអោយអូនស្លាប់បានទេ.. កំពូលជីវិតបង... បងក៏ មិនអាចរស់នៅដោយខ្វះរូបអូនបានដែរ...

ថាចប់នាយក៏បីកាយរចនាឈានបោះជំហានបែរថយក្រោយ ស្រាប់តែរាជ ធិតា មល្លិកាពោលវាចាសួរបន្ថែមថា :

- បងខេមឫទ្ធិ! ម្តេចក៏បងទៅចោលអូន? ឬក៏បងមិនចង់អោយដួងព្រលឹងអូន មានរូបកាយ មានជីវិតមកវិញទេហ៏ឬអ្វី....?

ខេមឫទ្ធិទុចង៉ក់ ស្រាប់តែរចនាបន្លឺវាចាទាំងដង្ហក់ខ្យល់ ថា :

- បងខេមឫទ្ធិ... បណ្តោយអោយអូនស្លាប់ចុះ... ព្រះរាជធិតារងទុក្ខមកជា យូរហើយ... គួរណាស់តែមានឱកាសក្លាយជាមនុស្សវិញ... ចំពោះរចនា... រចនា ស្រលាញ់បងណាស់... ហើយក៏ សុខចិត្តលះបង់ជីវិតដើម្បីសុភមង្គលរបស់បង ជានិច្ច... ពេលអូនស្លាប់ទៅ សូមបង នឹកដល់អូនផងណ៎ា ម្ចាស់ចិត្តអូន...

- អត់ទេ... អត់ទេ... រចនា! អូនមិនស្លាប់ទេ....អូនមិនអាចទៅណាចោលបងទេ.. បងស្រលាញ់អូនណាស់ រចនា... បងស្រលាញ់អូន... កុំទៅណាចោលបង! រចនា!!

- បានន័យថា បងឈប់ស្រលាញ់អូនហើយឬបងខេមឫទ្ធិ? ( រាជធិតាសួរកាត់)

CHANBOKEO.COM

ខេមឫទ្ធិស្រក់ទឹកភ្នែកច្រោក សំលឹងទៅរាជធិតាហើយមានវាចាយ៉ាងម៉ឺង ម៉ាត់ថា :

- រាជធិតា... អោយទូលបង្គំសូមអភ័យទោសផង... ការពិតទូលបង្គំមិនដឹងថា កាលពីអតិតជាតិ ទូលបង្គំបានសច្ចាអ្វីខ្លះជាមួយព្រះនាងទេ... តែពេលនេះ ទូលបង្គំ ជាមនុស្សបច្ចុប្បន្ន... មិនអាចបណ្តោយអោយអ្នកមានគុណនិងនារីដែលទូលបង្គំ ស្រលាញ់ជាទីបំផុតក្នុងជីវិត ត្រូវឃ្លាតចាកពីទូលបង្គំបានទេ... ទូលបង្គំសូមអភ័យ ទោស... ទោះបីទូលបង្គំមានបំណងចង់បំពេញតាមពាក្យសន្យាថ្វាយព្រះនាងយ៉ាងណាក៏ដោយ ក៏ទូលបង្គំមិនអាចបណ្តោយអោយមនុស្សពីរនាក់ស្លាប់បាត់បង់ជីវិត ដើម្បីបំពេញបំណន់សន្យារបស់ទូលបង្គំបានដែរ... ពិតជាមិនបានទេ...!! ពិតជាមិន បានទេ...!!!

ថាហើយ ខេមឫទ្ធិបីយករូបកាយរចនាចាកចេញទៅយ៉ាងលឿនដូចហោះ ទុកបណ្តោយអោយរាជធិតាឈរដង្ហោយពីក្រោយខ្នងល្វើយៗ ....

- បងខេមឫទ្ធិ!! ត្រលប់មករកអូនវិញ!! បងខេមឫទ្ធិ...

តែគ្រានេះ ខេមឫទ្ធិលែងឮសវនីយ៍របស់រាជធិតាតទៅទៀតហើយ ក្រៅពី ដង្ហោយហៅរកតែដួងព្រលឹងរចនា អោយត្រលប់មករកកាយរបស់នាងវិញ តែ ម្យ៉ាងប៉ុណ្ណោះ :

000000000000000000000000000

នៅក្នុងមន្ទីរពេទ្យមួយនៅសៀមរាប :

ខេមឫទ្ធិដើរទៅដើរមកមុខបន្ទប់ព្យាបាលអាសន្ន សំដែងអាការៈអន្ទះសា...

- រចនា!! សូមអោយអូនបានផុតគ្រោះភ័យផង (នាយយើងលើកដៃបែបន់)

អ្នកស្រីមណីអង្គុយក្បែរនោះក៏ទាញដៃអាវនាយអោយអង្គុយចុះ :

- រំងាប់អារម្មណ៍ខ្លះទៅកូនសំលាញ់ម្តាយ...

មាណពងើបមុខឡើង ពោលថា :

- អ្នកម្តាយ... ពេលនេះ កូនមានអារម្មណ៍ថាខុសធ្ងន់ណាស់ចំពោះអូនរចនា...

- ហ៊ឺ!! ជួនកាល មនុស្សយើងមិនស្គាល់ចិត្តគ្នាទេ លុះត្រាមានគ្រាអាសន្នដូច្នេះ ទើបយើងដឹងចិត្តគ្នាទៅវិញទៅមកណាំកូន...

- តែក៏ជាមេរៀនជីវិតគួរអោយរន្ធត់ចិត្តណាស់អ្នកម្តាយ...

- មែនហើយកូន... ដូច្នេះថ្ងៃក្រោយ មានការអ្វីក្នុងចិត្ត... យើងកុំលាក់នឹងគ្នាធ្វើអ្វី នាំតែធ្វើអោយមានការយល់ច្រលំមិនយល់ចិត្តគ្នា នោះវាគ្រោះថ្នាក់ណាស់កូន ។

- បាទអ្នកម្តាយ...!!

រំពេចនោះ លោកវេជ្ជបណ្ឌិតក៏ដើរចេញមក :

- ភរិយារបស់លោកផុតគ្រោះថ្នាក់ហើយ...

គ្រាន់តែឮដូច្នោះ ខេមឫទ្ធិរលីងរលោងទឹកភ្នែក ដោយក្តីរំភើបត្រេកអររក ពាក្យអ្វីមកបរិយាយមិនបានឡើយ ។ នាយស្ទុះទៅអោបអ្នកស្រីមណីដោយដួង ចិត្តរំភើបរកថាមិនត្រូវ....

0000000000000000000000

នៅក្នុងបន្ទប់អ្នកជំងឺ...

CHANBOKEO.COM

ខេមឫទ្ធិនៅអង្គុយក្បែរគ្រែ សំលឹងមុខរចនាដែលគេងលក់ស្ងប់ស្ងាត់ :

- រចនាអូន... អភ័យទោសអោយបងផង ដែលបងជាមនុស្សរារែក សំរេចចិត្តអ្វី មិនច្បាស់លាស់ បណ្តាលអោយអូនទទួលការសោកសៅក្នុងចិត្តដោយសារតែបង...

នាយយកដៃទៅអង្អែលខ្នងដៃនាងបន្តិចៗ ស្រាប់តែនាងភ្ញាក់បើកភ្នែកឡើង ហើយឧទានខ្សាវៗថា :

- បងខេមឫទ្ធិ....

មាណពស្ទុះងើបឈរឡើង :

- បងនៅក្បែរនេះទេ... រចនា... បានអូនផុតគ្រោះថ្នាក់ បងពិតជាត្រេកអររកអ្វី ផ្ទឹមគ្មានទេ....

រចនាងាកមើលមកនាយភ្លឹះៗ ហើយ យកដៃស្ទាបផ្ទៃមុខខេមឫទ្ធិ :

- ពេលនេះ... តើអូនកំពុងស្រម័យឬក៏អូនកំពុងប្រទះការពិត ថាបងមករករចនា វិញ...

មាណពចាប់ដៃនាងកាន់ឡើង :

- ជាការពិតណាំអូន... ឆាប់ជាសះស្បើយវិញណាំ.. អាលត្រលប់ទៅផ្ទះយើងវិញ

រចនាញញឹមកាលបើបានឮដូច្នោះ ស្រាប់តែទំលាក់ទឹកមុខភ្លាមហើយសួរថា :

- រួចចុះព្រះរាជធិតា... តើបងគិតយ៉ាងណាវិញ ?

ខេមឫទ្ធិយកម្រាមដៃមកផ្ទប់បបូរមាត់នាងមិនអោយនិយាយ :

- ចាំអូនជាសះស្បើយ បងប្រាប់អូនណាំ!

រចនាធ្វើមុខងឿងឆ្ងល់ តែក៏មិនសួរអ្វីដែរ ត្បិតនៅអស់កំលាំង ក៏ធ្មេចនេត្រា លង់លក់ទៅវិញក្រោមអំណាចថ្នាំព្យាបាលរបស់មន្ទីរពេទ្យ ។

oooooooooooooooooooooooooo

ប៉ុន្មានថ្ងៃក្រោយមក...

- បងខេមឫទ្ធិ... បងនាំអូនមកប្រាង្គត្រៃលក្ខណ៍នេះធ្វើអ្វី??

- អូនអុជធូបសិនទៅ ចាំបងប្រាប់...

រចនាឮហើយ ក៏ស្រវាអុជធូបថ្វាយបង្គំតាមនាយភ្លាម ។ រំពេចនោះ តាងវ៉ាង និងអ្នកស្រីមណី បាននាំព្រះសង្ឃចំនួន១២ អង្គមកដល់ល្មម ព្រមជាមួយ មិត្តសហការីរបស់ខេមឫទ្ធិ និងអ្នកភូមិអ្នកស្រុកជាច្រើន។ រចនានឹកឆ្ងល់ណាស់ ក៏លាន់មាត់ឡើង :

- បងធ្វើអ្វីចំលែកទៀតហើយ មែនទេហ៎?

តែខេមឫទ្ធិមិនឆ្លើយទេ គ្រាន់តែញញឹមដាក់នាង រួចហើយលើកដៃប្រណម្យ ឡើង ព្រមទាំងមានវាចាថា :

- បរពិត្ររាជធិតាសុរភីមល្លិកា! បើវិញ្ញាណរបស់ព្រះនាងនៅក្បែរៗនេះ សូមព្រះ នាងទទួលដឹងឮផង ថាថ្ងៃនេះ វេលានេះ ទូលបង្គំសូមមកធ្វើពិធីក្រាបបង្គំលា បំណន់ និងពាក្យសន្យាដែលទូលបង្គំធ្លាប់ទូលថ្វាយកាលពីអតិតជាតិចំពោះព្រះនាង ហើយក៏សូមនិមន្តព្រះសង្ឃបង្សុកូលអនុមោទនា បញ្ជូនកុសលដល់វិញ្ញាណក្ខន្ធ័ របស់ព្រះនាង ដើម្បីឱ្យដួងព្រលឹងបានទៅកាន់សុគតិភពផង ។

រចនាភ្ញាក់ក្រញាង កាលបើឮវាចារបស់ខេមឫទ្ធិដូច្នោះ ។ នាងត្រេកអរផង រំភើបផងហួសប្រមាណកាលបើបានដឹងថា មាណពបានសំរេចចិត្តជ្រះស្រលះ មិន នៅលិចលង់នឹងស្រមោលស្នេហាអតិតកាលទៀតឡើយ ។ រំពេចនោះ ខេមឫទ្ធិ ក៏ពោលបន្តទៅទៀតថា :

CHANBOKEO.COM

- យើងទាំងពីរនាក់ រួមទាំងពលរដ្ឋក្នុងមហាបុរី មានមោទនភាពយ៉ាងខ្លង់ ខ្ពស់ចំពោះរាជធិតា ដែលបានបូជាជីវិតដើម្បីរក្សាមហានគររបស់យើងនាគ្រាមួយ នៃអតិតកាល ។ យើងទាំងឡាយដែលជាបច្ឆាបុត្រនៃមហានគរ សូមចងចាំនិងគោរពបូជានូវវិរភាពរបស់ព្រះនាង ចំពោះប្រទេសជាតិរហូតតរៀងទៅ...

ភ្លាមនោះ ស្រាប់តែដួងវិញ្ញាណរបស់រាជធិតាបានផុសផ្លោអណ្តែតឡើងនៅ ក្លោងទ្វារប្រាង្គ ព្រមជាមួយដួងព្រលឹងអ្នកទាំងឡាយដែលខេមឫទ្ធិធ្លាប់បានជួប កន្លងមក ដូចជាព្រះចៅមហានគរ លោកមេទ័ពនិងភរិយា ព្រឹទ្ធជនតាងវ៉ាង អ្នកម្នាងខេមរី ជាដើម ។ ព្រះសង្ឃទាំង១២ព្រះអង្គ ក៏ចាប់ផ្តើមសូត្រ ធម៌ឡើងលាន់ឮរងំកាត់ព្រៃ។ ប៉ុន្តែ គួរអោយចំលែកណាស់ លើកនេះព្រះរាជធិតាបែរជាគង់នៅស្ងៀមស្ងាត់លែងមានសវនីយ៍អ្វីទៀតហើយ ។ មួយស្របក់ក្រោយ មក ស្រាប់តែស្រមោលដួងវិញ្ញាណរបស់រាជធិតាសុរភីមល្លិកា និងវិញ្ញាណទាំង ឡាយក៏រលាយរូបអន្តរធាន ហើយក្លាយទៅផ្កាយដែលមានពន្លឺយ៉ាងភ្លឺផ្លេក ពណ្ណរាយ រួចហើយក៏ហោះហើរឡើងទៅវេហាស៍ឆ្ងាយទៅៗ រហូតដល់បាត់ពី កន្ទុយភ្នែក ។ ទាំងអស់គ្នាក៏ងើយសំលឹងមើលតាមលុះត្រាតែផ្កាយអស់ពន្លឺរស្មី ។ បន្ទាប់មក អ្នកស្រីមណីក៏ហៅតាងវ៉ាង ឱ្យនិមន្តព្រះសង្ឃត្រលប់ទៅវត្តវិញ ដើម្បីទុកអោយ គូស្នេហ៍ទាំងទ្វេហាមានឱកាសនិយាយគ្នាតែពីរនាក់ ។

00000000000000000000000

ខេមឫទ្ធិដឹកដៃរចនាមកដល់មាត់ស្រះដែលមានផ្កាឈូករីករហង់យ៉ាងរមនា :

- រចនា! អូនឃើញផ្កាឈូកទាំងនោះទេ?

- ចាស ! រីកស្រស់ស្អាតណាស់បង !

- ហើយតើអូនដឹងទេថា អូនគឺជាផ្កាឈូកមួយទង ដែលរីកនៅក្នុងបេះដូង របស់បង...?

រចនាសំលឹងមុខមាណពយើង ហើយតបវិញថា :

- អូនពិតជាមានតម្លៃដល់ម្លឹងចំពោះបងមែនហ្អែស ?

- មែនហើយ ! អូនជាផ្កាដែលមានចិត្តបរិសុទ្ធ មិនខុសពីផ្កាឈូកដែលគេបូជាព្រះ នោះឡើយ គឺអូនហ៊ានពលីដើម្បីបងនិងរាជធិតា គួរឱ្យគោរពទឹកចិត្តអូនណាស់...

- នោះក៏ព្រោះដើម្បីសេចក្តីសុខរបស់បុគ្គលដែលអូនស្រលាញ់តែប៉ុណ្ណោះ!!

ខេមឫទ្ធិឮហើយក៏លូកដៃត្រកងកាយនាងពីក្រោយ :

- បងគិតថា ជាតិនេះ បងមានសំណាងខ្ពស់ណាស់ដែលមានរូបអូនជាគូជីវិត...

- ចុះបងមិននឹកអាល័យរាជធិតារបស់បងទេហ៎?

- អាណិតតែមិនអាល័យទេ ត្បិតនោះគឺគ្រាន់តែជាស្រមោលនៃស្នេហាមួយនា អតិតកាលតែប៉ុណ្ណោះ... ស្នេហាដែលបងមិនទាំងចាំផង ថាបងបានធ្វើអ្វី ស្បថអ្វី សន្យាអ្វីខ្លះ?

- ចុះហេតុអ្វីបងហ៊ានស្ម័គ្រប្ូជាជីវិតដើម្បីព្រះនាង?

- អ្នកណាថា...? គឺពេលនោះបងកំពុងតែចង់សាកចិត្តអូនតើហ៎...

រចនាឮហើយ... ក៏ឈរភាំង :

- ចាស? បងមានប្រសាសន៍ថាម៉េច?

ខេមឫទ្ធិសើចខឹកៗ រួចឆ្លើយតបវិញថា :

CHANBOKEO.COM

- បងប្រាប់អូនហើយតើ ថាជីវិតបងស្ថិតនៅបច្ចុប្បន្ន មិនអាចត្រលប់ទៅអតិត កាលវិញបានទេ ប៉ុណ្ណឹងអូនមិនយល់ទេហ៎?

រចនាក៏ញញឹមឡើង :

- អូនសែនរំភើបចិត្តណាស់ កាលបើបងជ្រើសរើសយកជីវិតបច្ចុប្បន្ន មិនវិលទៅ វង្វេងជាមួយស្រមោលអតិតកាលដ៏គ្មានគោលដៅនោះតទៅទៀត ។

- បានន័យថា អូនយល់ព្រមក្លាយជាគូរួមដំណើរជីវិតជាមួយបងហើយមែនទេហ៎..

លើកនេះ រចនាសើចខឹក១ម្តង :

- បងសួរអីហ្នឹង??... បងមិនទាន់ដឹងចិត្តអូន ឬក៏បងធ្វើពើមិនដឹង??

ខេមឫទ្ធីលើកបិត្រកងរចនាឡើង :

- មិនដឹងទេ... បងចង់ឮអូនប្រាប់បងណា៎

- អូនប្រាប់បងរួចហើយតើ...

- ប្រាប់ពីអង្កាល់អត់ឮទេ.... ប្រាប់បងម្តងទៀតមក៏

- អត់ទេ... ឈប់ប្រាប់ហើយ... !!!

រចនាខ្មាញ់ណាស់ក៏លូកដៃក្តិច ។ ខេមឫទ្ធិក៏លាន់សំណើចរអឹកឡើង ជាសូរ សៀងសុភមង្គលដ៏ផ្អែមល្ហែមមួយ.... ដែលរចនាយើងកំពុងរង់ចាំស្តាប់ជាយូរមក ហើយ ។

បេះដូងតែមួយ...

ប. មើលហ្ន៎ !ផ្កាឈូករីកស្រស់រហង់ ហាក់ភក្ត្រ៍ផូផង់នៃម្ចាស់ជីវិត
ផ្កាឈូករេរាំ សោភាប្រណិត ដូចស្នេហ៍វរមិត្ររីកក្នុងបេះដូង ។

ស. ជើងមេឃសែនឆ្ងាយកាយសែនស្រណោះ វេហាស៍ធំខ្ពស់ហួសបើនឹងឈោង
តើគួរជឿទេពាក្យស្បថប្រុសបង ឬគ្រាន់ចំណងអោយមុំសោកា ។

ប. ពៅអើយ មើលហ្ន៎ព្រះសូរ្យយាងរះ ចែងចាំងឱភាសរង្សីភ្លឺថ្លា
ដូចចិត្តបងស្ម័គ្រ័លើពៅជីវ៉ា ពណ្ណរាយចិន្តាឥតថ្ងៃបែកបែរ ។

ប.ស. យើងសច្ចាស្ម័គ្រ័រួមរក្សមេត្រី ជាគូលុះក្ស័យមិនប្តូរប្រួលប្រែ
សូមព្រះយាងប្រោសប្រណីក្តីស្នេហ៍ ដល់គូទាំងទ្វេ ឋិតឋេរវៀងអើយ ។

oo oo

oo

CHANBOKEO.COM

# វគ្គទី៨

# សុបិនបន្តសាច់រឿង

- ខេមឫទ្ធិ ! ភ្ញាក់ឡើង...

- តាងវ៉ាង!! យន្តហោះដល់ណាហើយហ្នឹង?

- ១៥នាទីទៀត ដល់ វាលចំណតសៀមរាបហើយ..

- ហ៊ឹម!!

- ស្វាបធំម្លេះសំលាញ់ គ្រាន់តែជិះយន្តហោះពីសាំងកាប៉ូមកសៀមរាបតែពីរម៉ោង ប៉ុណ្ណឹង គេងលក់អោយស្រម៉ុកខុរតែម្តង សង្ស័យតែឯងកំពុងតែយល់សប្តិឃើញ ទេពទេវីអប្សរាទេន៎ះ ។

- ហ្អាស? ម៉េចក៏ឯងដឹង...?

- ថីក៏មិនដឹង... មើលហ្ន៎ ! តាំងពីចេញដំណើរពីរដ្ឋមិនីសូតាមក គ្នាឃើញតែឯង អានសៀវភៅអំពីខែត្រសៀមរាបមួយក្បាលនេះ ហើយគន់សំលឹងរូបទេវីអប្សរា មិនឈប់ឈរសោះ  សង្ស័យតែកំពុងលង់ស្នេហ៍ទេពទេវីក្នុងសៀវភៅនោះហើយ មើលទៅ....

ខេមឫទ្ធិសើចខឹក១ :

- លង់ស្នេហ៍យ៉ាងណាក៏មិនអាចទៅរួចដែរសំលាញ់

- ម៉េចអញ្ចឹង?

- ព្រោះទេពទេវីមាននៅសល់ត្រឹមតែដួងព្រលឹងប៉ុណ្ណោះ... គ្នាវិញប្រាថ្នាសុំ រៀបការជាមួយនារីធម្មតា១ នាបច្ចុប្បន្នទៅវិញចុះ គ្រាន់បើជាង ។

- អឺ!! និយាយត្រូវ... ចំណែកគ្នាវិញ បើកុំតែមានប្រពន្ធហើយ កុំអីគិតសំលឹងរក មួយដែរហើយ... អូហ៍ និយាយអីចឹង...

ឯងមានសំលឹងឃើញនារីណាហើយឬនៅ

មុននឹងចេញដំណើរមកប្រទេសខ្មែរនេះ?

- អត់ស្មោះហើយ... ខ្ញុំបែកពីស្រុកទេស ទៅនៅរដ្ឋមិនីសូតា សហរដ្ឋអាមេរិក ជិត១០ឆ្នាំហើយ ទើបតែមានឱកាសមកលេង ស្រុកកំណើតវេលានេះឯង  ។

- នែ៎ខេមឫទ្ធិដឹងទេ? នៅស្រុកយើង មានក្រមុំស្រស់ស្អាតណាស់.. សង្ស័យតែឯង រកគូព្រេងឃើញ នៅស្រុកខ្មែរគ្រានេះហើយ....

ឮដូច្នេះ ខេមឫទ្ធិនឹកខ្មាស់មុខឡើងក្រហមងាំង ។

- គ្នាមកលេងស្រុក មិនមែនមករកប្រពន្ធឯណា?

- នរណាទៅដឹង.. អោយតែគូព្រេងដល់... វាក់អ៊ើ... បាក់ចិត្តស្លូក...

- ចេះតែថាហើយ តាងវ៉ាងឯងនេះ ។

តាងវ៉ាងសើចខឹក១ ហើយនិយាយបន្តទៅទៀតថា :

CHANBOKEO.COM

- នែះ... សូមសួរមួយទៀតបានទេ?

- សួររឿងអ្វីទៅ?

- កាលពីចេញដំណើរមក... ឯងអង្គុយមើលរូបអប្សរាក្នុងសៀវភៅ ស្រាប់តែឯង គេងលក់ ហើយមមើស្រែកហៅ ឈ្មោះស្រី១ដល់ទៅពីរនាក់... នែ៎ តើនាងជា នរណាដែរទៅ?

- ថាម៉េច? ខ្ញុំមមើហៅឈ្មោះមនុស្សស្រីដល់ទៅពីរនាក់?

- មែនហើយ... ដំបូងហៅ មល្លិកា...ដល់ក្រោយមកស្រាប់តែដូរហៅរចនាវិញ ។ តើឯងយល់សប្តិឃើញគូព្រេងរបស់ឯងមែនទេហ៎?

- ចេះតែថាហើយ កុំលេងអញ្ចឹងមើស៎

- មែនណា៎ ខ្ញុំឮជាក់ច្បាស់ថាឯងហៅឈ្មោះទាំងពីរនោះពិតមែន...

ខេមឫទ្ធិនឹកខ្មាស់មិត្តរបស់ខ្លួនិតតែខ្លាំង តែទោះជាយ៉ាងណា នាយក៏មិនព្រម សារភាពដែរថា ខ្លួនបានយល់សប្តិឃើញនារីសោភាដល់ទៅពីររូបនោះឡើយ ។ ភ្លាមនោះ តាងវ៉ាងក៏ពោលបន្តថា :

- ហើយចុះពីណាគេទៅ ឈ្មោះរចនា ឬមល្លិកា ទៅហ្ន៎? ខ្ញាដឹងច្បាស់ថាឈ្មោះនេះ ច្រើនតែជាឈ្មោះរបស់នារីខ្មែរ.. មិនមែននារីអាមេរិកទេ... នែ៎ស... កុំលាក់មើល៍.. នរណាគេពីរនាក់ហ្នឹង...? ជាគូកំណាន់ចិត្តរបស់ដែលឯងត្រូវជ្រើសរើសយកមួយ ជាគូគ្រងមែនទេហ៎?

- ប្រាប់ហើយតើហ៎ ថាខ្ញុំអត់ដែលស្គាល់ទេ...!!!!

តាងវ៉ាងនៅតែញញឹម សំលឹងមុខ ខេមឫទ្ធិធ្វើឫកពារហាក់ដូចជាមិនអស់ចិត្ត ដដែល ។ ខេមឫទ្ធិឃើញតាងវ៉ាងដេញដោលពេក ក៏សំរួលតិរិយាបថធ្វើធម្មតា១ មិនហ៊ានស្រដីតបបន្តទៀតឡើយ ខ្លាចបែកការណ៍ ។

ដំណើរមាតុភូមិនិវត្តន៍

យន្តហោះបោះពួយជ្រែកអាកាសា    រន្ធត់ឱរា ភ័យអរ១
ច្រើនឆ្នាំឃ្លាឃ្លាតមាតុភូមិអង្គរ    ថ្ងៃនេះចេញចរវិលសាជាថ្មី ។
យន្តហោះលឿនក្រៃកាត់ស្បែរហោស៍    មិនស្មើចិត្តានឹកដែនបុរី
ខ្លួននៅអាកាសចិត្តចុះដល់ដី    ជួបញាតិប្រុសស្រីទឹកដីម៉ែខ្ញុំ ។
មិនដឹងត្រូវសើចយំសោកព្រួយភ័យ    ត្រេកអរឬអ្វីពេលវិលជួបជុំ
ឃើញភក្ត្រ័សន្តានផៅផងឧត្តម    ឱ!បេះដូងខ្ញុំរន្ធត់ខ្លាំងក្រៃ ។
សូរឃោសនសព្ទ័ផ្សាយលើយន្តហោះ    ដំណើរឈានបោះសៀមរាបបុរី
និវត្តន៍ដល់ហើយមាតុភូមិទឹកដី    ចិត្តអើយអរភ័យត្រូវជួបអ្វីខ្លះ?

បន្តិចក្រោយមក យន្តហោះក៏ចុះដល់ដី.....

អ្នកដំណើរក៏ចុះចាកចេញម្តងមួយ១...

តាងវ៉ាងមិនអស់ចិត្តទេ ក៏ដេញដោលសួរបន្តអត់ឈប់ :

- សង្ស័យណាស់... ថាគូព្រេងរបស់ឯងច្បាស់ជានារីណាម្នាក់ក្នុងចំណោមពីរនាក់ ដែលឯងយល់សប្តិឃើញអំបាញ់នោះមិនខានទេ ។

CHANBOKEO.COM

- តាងរ៉ាងអើយ!! បើពិតដូច្នោះមែន ឯងច្បាស់ជាក្លាយទៅជាភ្ញៀវទីមួយដែលខ្ញុំ មកអញ្ជើញអោយចូលរួមពិធីមិនខាន (ខេមឫទ្ធិចំអន់នាយវិញ)

បន្តិចក្រោយមក ទាំងពីរនាក់ក៏លើកឥវ៉ាន់ដាក់រទេះចេញទៅក្រៅ ស្រាប់តែ ប្រទះមនុស្សមួយហ្វូង ។ តាងរ៉ាងងាកមកប្រាប់ខេមឫទ្ធិថា :

- គេទាំងនោះជាបងប្អូនរបស់ខ្ញុំពីបាត់ដំបង ។ ចុះឯងមានពីណាមកទទួលទេ?

- អត់មានទេហ៎.. ខ្ញុំគិតថារកតាក់ស៊ីជិះទៅរកសណ្ឋាគារ... ចាំស្អែកទើបធ្វើដំណើរ បន្តទៅស្រុកទៀត ។

- អូហ៍ ទៅហៅតាក់ស៊ីធ្វើអ្វី... ម៉ោះ ចាំខ្ញុំពឹងសាច់ញាតិខ្ញុំវិញ។

វំពេចនោះឮសំលេងសុភាពស្ត្រីម្នាក់ស្រែកហៅពីចំងាយ ។

- បងតាងរ៉ាង...

តាងរ៉ាងឃើញហើយក៏ងាកប្រាប់មាណពយើង :

- នេះគឺប្រពន្ធរបស់គ្នាណា៎ ។

ខេមឫទ្ធិក៏លើកដៃសំពះឡើង ។ ភរិយាតាងរ៉ាងក៏សំពះតបវិញ រួចហើយក៏ ស្រែកហៅអោយសាច់ញាតិដែលមកជាមួយ ជួយលើកដាក់ឥវ៉ាន់ទៅក្នុងឡាន។

វំពេចនោះ ស្រាប់តែខេមឫទ្ធិដាក់ភ្នែកទៅឃើញនារីម្នាក់ ស្លៀកពាក់សុភាពសមជា និស្សិត នៅឈរពីក្រោយភរិយារបស់តាងរ៉ាង ។ នាយក៏ចាប់ភ្លឹកថា នាងក៏កំពុង សំលឹងមករកនាយដូចគ្នាដែរ តែក៏គេចក្រសែភ្នែកទៅវិញកាលបើ ប្រទះនឹងកែវ ភ្នែករបស់នាយ ។ អ្វីដែលគួរអោយចាប់ភ្លឹកបំផុតនោះ គឺនាងមានមុខមាត់ដូច នារីម្នាក់ដែលនាយយល់សប្តិឃើញកាលពីនៅលើយន្តហោះនោះបេះបិត។ មាណព នឹកអស្ចារ្យតែក្នុងចិត្តម្នាក់ឯង ។

បន្តិចក្រោយមក ភរិយាតាងរ៉ាងក៏ស្រដីឡើង :

- រចនា.. ឆាប់មកជំរាបសួរបងឯងទាំងពីរទៅ !!

មែនហើយ រចនាគឺជានារីសោភាម្នាក់នោះ ។ ម្តងនេះខេមឫទ្ធិ ភ្ញាក់ក្រញាង ស្លុតចិត្តរិតតែខ្លាំង ហើយគិតក្នុងចិត្តថា :

- ព្រះអើយ! សូម្បីតែឈ្មោះក៏ដូចគ្នានឹងនារីដែលខ្ញុំជួបក្នុងសុបិននោះដែរ ! ឬក៏ នាងជាតួមួយក្នុងចំណោមពីរនាក់ដែលខ្ញុំនឹងត្រូវជ្រើសរើសជាគូ? ហើយ... តើពេល នេះ រូបខ្ញុំកំពុងយល់សប្តិ តរឿង ឬក៏កំពុងយល់សប្តិរឿងថ្មីមួយទៀតទៅហ្ន៎?

កំពុងតែគិតស្លុងភ្លឹកស្មារតី ស្រាប់តែមាណវីក៏លើកដៃសំពះជំរាបសួរនាយ ។ ខេមឫទ្ធិភ្ញាក់ព្រើត លើកដៃប្រណម្យតបវិញទាំងភ្ញាក់ស្រលាំងកាំង ។ រីឯតាងរ៉ាង វិញ កាលបើក្រលេកឃើញរចនាហើយ ក៏លាន់មាត់ឡើង :

- ពុទ្ធោ ហ្នឹងគឺរចនា ប្អូនស្រីពៅរបស់អូននោះមែនទេហ៎ ? បែកគ្នាតែពីរឆ្នាំស្រាប់ តែពេញវ័យស្រស់ស្អាតធ្វើឱ្យបងមើលលែងស្គាល់តែម្តង វិះច្រលំថាជាតារាភាព យន្ត ឬតារាកាភាអូខេហើយតើ ។

- ចា៎មែនហើយបង !! (ភរិយាតាងរ៉ាងស្រដីតបវិញ)

រចនាមិននិយាយអ្វីទេ គ្រាន់តែញញឹមនៅអឹមអៀនតែប៉ុណ្ណោះ ប្រហែលជា នាងនឹកខ្មាសនឹងខ្សែភ្នែករបស់ខេមឫទ្ធិដែលសំលឹងនាងមិនពព្រិចនោះក៏មិនដឹង ។

តាមផ្លូវ តាងរ៉ាងសង្កេតឃើញខេមឫទ្ធិលួចសំលឹងរចនាមិនដាក់ភ្នែកសោះ ក៏ អោនខ្សិបដាក់នាយថា :

- ឃើញទេហ៎ ? គ្នាថាហើយថា.... ឯងមកលេងស្រុកខ្មែរដើងនេះ ប្រហែលជា ជាជួបនឹងគូព្រេងហើយ...

CHANBOKEO.COM

ឮដូច្នោះ ខេមឫទ្ធិខ្មាសរឹងខ្លួនតែម្ដង តែមិនហ៊ានស្ដីតបអ្វីវិញ ត្បិតនាយហាក់ មានអារម្មណ៍ថាដូចជាចំលែកយ៉ាងណាមិនដឹង ហើយនាយនឹកឆ្ងល់ក្នុងចិត្តមិនដាច់ ស្រេច ថា :

- ហេតុអ្វីក៏យើងយល់សប្តិឃើញរចនាកញ្ញាសោភានេះកើតហ្ន៎ បើយើងមិនដែល ស្គាល់នាងពីមុនមកផង.? ឬក៏ដូចពាក្យតាងវ៉ាងនិយាយ ថាគូព្រេងយើងជិតមក ដល់ហើយ.... ពុទ្ធោអើយ..!!! យ៉ាងណាក៏យ៉ាងណាទៅ... ខ្ញុំលែងគិតហើយ ។ ពេលនេះ ខ្ញុំសុំដើរលេងបន្តិចសិន.. សព្វថ្ងៃ ឮល្បីថានៅសៀមរាបសប្បាយណាស់ ! បើសិនមានដៃគូដើរលេងជាមួយ នោះប្រហែលជាឡូយអស្ចារ្យហើយ!! ប៉ុន្តែ.... តើបាននរណាធ្វើជាដៃគូរបស់ខ្ញុំទៅ?... អ្នកនាងរចនា ឬក៏នារីដទៃផ្សេងទៀត? ហ៊ឺ! ដូចជាពិបាកចិត្តណាស់លោកអើយ!! មិនដឹងថា យប់នេះ ខ្ញុំយល់សប្តិ បន្តសាច់ រឿងថែមទៀត ឬក៏យ៉ាងណាទៅវិញ ? ឱ! ព្រះនាងសុរភីមល្លិកាទេវីអប្សរា មហានគរអើយ!!! មេត្តាជួយតម្រង់ផ្លូវជីវិតរបស់ខ្ញុំសាជាថ្មីផងបានទេហ៎ ?

# ចប់

CHANBOKEO . COM

# ឈ្មោះកំណាព្យទាំងឡាយនៅក្នុងរឿងអប្សរា


| | |
|---|---|
| ១. ដែនរមណី | ទំព័រ ៨ |
| ២. ឯណាម្ចាស់សៀង | ទំព័រ១២ |
| ៣. ស្ដាយក្លិនស្នេហ៍ | ទំព័រ១៦ |
| ៤. លាមួយគ្រាសិន | ទំព័រ២៩ |
| ៥. ថ្នាលស្នេហ៍ភិរម្យ | ទំព័រ៣៧ , ៣៩ |
| ៦. មួយរាត្រីដ៏មានន័យ | ទំព័រ៥៧ |
| ៧. ចាំ | ទំព័រ៧៣ |
| ៨. ផ្កាម្លិះក្រពុំ | ទំព័រ៧៩ |
| ៩. ដានស្នេហ៍ឆ្នេរខ្សាច់ | ទំព័រ៨២ |
| ១០. ចិញ្ចៀនបញ្ចាំចិត្ត | ទំព័រ៨៩ |
| ១១. អភ័យទោសផង | ទំព័រ៩៦ |
| ១២. បេះដូងតែមួយ | ទំព័រ១០៦ |
| ១៣. ដំណើរមាតុភូមិនិវត្តន៍ | ទំព័រ១០៩ |


CHANBOKEO . COM

ដោយអ្នកស្រីកែវ ចន្ទ័បូរណ៍

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

ខែកញ្ញា ១៩៩៩